ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា

ជំនការយុទ្ធសាស្ត្រ

ស្តីពី

កម្មាំងសេវាសង្គមនៅកម្ពុជា ២០២២-២០៣១

ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ០៦៩ ស.អ.យ.

ថ្ងៃ សុក្រ ៩កើត ខែ ផល្គុន ឆ្នាំ ឆ្លូ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២២

ប្រកាស

ស្តីពី

ការដាក់ឱ្យប្រើប្រាស់សៀវភៅផែនការយុទ្ធសាស្ត្រ ស្តីពី កម្លាំងសេវាសង្គមនៅកម្ពុជា ២០២២-២០៣១

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញសេចក្តីសម្រេចលេខ០៣៦ ស.អ.យ/ស.ស.រ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់កម្លាំងសេវាសង្គមកិច្ច
- យោងការងារចាំបាច់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ /ទូរសារ: (៨៥៥) ២៣ ៧២៦ ០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

សម្រេច

ប្រការ ១._

ត្រូវបានដាក់ឱ្យប្រើប្រាស់សៀវភៅផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជា ២០២២-២០៣១**» ដែលចុះថ្ងៃ ព្រហស្បតិ៍ ៤រកៀត ...ខែ ឧសភា ...ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ...១០... ខែ ឧសា ...ឆ្នាំ២០២២។

ប្រការ ២._

ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត រដ្ឋបាលឃុំ សង្កាត់ អាជ្ញាធរដែនដី សមាគម និងអង្គការមិនមែនរាជរដ្ឋាភិបាល អាចប្រើប្រាស់សៀវភៅនេះ ដើម្បីលើកកម្ពស់ប្រព័ន្ធកិច្ចគាំពារសង្គមឱ្យទទួលបានប្រសិទ្ធភាពខ្ពស់ ក្នុងការបង្កើនចំនួនកម្លាំងសេវាសង្គមនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់សមត្ថភាពកម្លាំងសេវាសង្គមឱ្យមានគុណវុឌ្ឍិពិតប្រាកដទាំងចំណេះដឹង ជំនាញ និងអាកប្បកិរិយា ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីផ្តល់សេវាសុខុមាលភាពសង្គមជូនដល់ប្រជាជនទូទៅ ពិសេសជនរងគ្រោះ និងងាយរងគ្រោះនៅកម្ពុជាប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌។

ប្រការ ៣._

សៀវភៅផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជា ២០២២-២០៣១**» នេះ មានសារៈសំខាន់ ដើម្បីយកទៅប្រើប្រាស់ជាផែនទីតម្រង់ផ្លូវឱ្យគ្រឹះស្ថានអប់រំ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស ដៃគូអភិវឌ្ឍ និងអង្គភាពពាក់ព័ន្ធចូលរួមអនុវត្ត ផែនការយុទ្ធសាស្ត្រនេះឱ្យទទួលបានជោគជ័យ។

ប្រការ ៤._

បទប្បញ្ញតិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៥._

នាយកខុទ្ធកាល័យរដ្ឋមន្ត្រី អគ្គនាយនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានជាតិសង្គមកិច្ច មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត អង្គភាពក្រោមឱវាទក្រសួង ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលឃុំ សង្កាត់ អាជ្ញាធរដែនដី សមាគម និងអង្គការមិនមែនរាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដែលផ្តល់សេវាសង្គមគ្រប់រូបត្រូវទទួលបន្ទុក អនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ទៀ សុត

ចម្លងជូនៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ធកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ធកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងផែនការ
-ក្រសួងអប់រំ យុវជន និងកីឡា
-ក្រសួងសុខាភិបាល
-ក្រសួងកិច្ចការនារី
-ក្រុមប្រឹក្សាជាតិតាំពាសង្គម
-គ្រប់សាលារាជធានី ខេត្ត
ឯកសារ-កាលប្បវត្តិ
-ដើម្បីជ្រាប-
-គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ស.អ.យ
-គ្រប់មន្ទីរ ស.អ.យ រាជធានី ខេត្ត
-ដូចប្រការ៥ -ដើម្បីអនុវត្ត-

អារម្ភកថា

ការងារសង្គមកិច្ចនៅក្នុងកម្ពុជាចាប់ផ្តើមមានស្ថាប័នដឹកនាំដំបូងមានឈ្មោះ «ក្រសួងព័ត៌មាន និងសង្គមកិច្ច» នៅឆ្នាំ១៩៤៧ និងបានផ្លាស់ប្តូរឈ្មោះស្ថាប័ននិងឈ្មោះថ្នាក់ដឹកនាំជាបន្តបន្ទាប់ទៅតាមសម័យកាលនៃរបបដឹកនាំនីមួយៗ ដែលបច្ចុប្បន្ននេះមានឈ្មោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានឯកឧត្តម **វង សូត** ជារដ្ឋមន្ត្រីនៅក្នុងរាជរដ្ឋាភិបាលអាណត្តទី៦ នៃរដ្ឋសភាដែលមានសម្តេចអគ្គមហាសេនាបតី **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ នៅប៉ុន្មានទសវត្សរ៍កន្លងមកនេះវិស័យសង្គមកិច្ចមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅកម្ពុជាទាក់ទងទៅនឹងអ្នកផ្តល់ជំនួយតាមបែបទម្លាប់ និងការផ្តល់សេវាសង្គមកិច្ច។ ចាប់តាំងពីមានវត្តមានរបស់អ៊ុនតាក់បុគ្គលិក «កម្លាំងសេវាសង្គម» របស់សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល បានដើរតួនាទីជាអ្នកផ្តល់សេវាសង្គមកិច្ចដ៏សំខាន់នៅក្នុងវិស័យជាច្រើន ខណៈពេលដែលកម្ពុជាបានចាប់ផ្តើមកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ សុខុមាលភាពសង្គម និងអភិវឌ្ឍធនធានមនុស្ស។

ការធ្វើផែនទីកម្លាំងសេវាសង្គមនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិកបានគូសបញ្ជាក់ថាមានភាពខុសប្លែកគ្នាគួរឱ្យកត់សម្គាល់នៅក្នុងតំបន់អាស៊ានទាក់ទងនឹងប្រភេទសេវាសង្គមដែលត្រូវបានអភិវឌ្ឍ របៀបដែលការងារសង្គមត្រូវបានកំណត់ និងវិសាលភាពដែលការងារសង្គមបានអភិវឌ្ឍជាអាជីព។ ភាពខុសគ្នានៃការកំណត់បុគ្គលិកសង្គម និងកម្លាំងសេវាសង្គមធ្វើឱ្យមានការលំបាកក្នុងការយល់ដឹងអំពីទំហំនៃកម្លាំងសេវាសង្គមដែលបានដាក់ពង្រាយនៅក្នុងប្រទេសនីមួយៗ ហើយភាសាដែលត្រូវបានប្រើដើម្បីពិពណ៌នាអំពីអ្នកដែលធ្វើការនៅក្នុងសេវាសង្គម ឬនៅក្នុងសេវាតាមវិស័យដូចជាសុខភាព និងការអប់រំក៏រួមចំណែកធ្វើឱ្យកាន់ច្រឡំនៃស្ថានភាពកម្លាំងសេវាសង្គមផងដែរ។ ការពង្រឹងកម្លាំងសេវាសង្គមមានសារៈសំខាន់ក្នុងការធ្វើឱ្យសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាព និងចំណុចដៅដែលនៅសល់រយៈពេល១០ឆ្នាំទៀត ចំណែកឯដំណើរការពង្រឹងកម្លាំងសេវាសង្គមនៅតំបន់អាស៊ានគឺត្រូវការពេលវេលា។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការយូនីសេហ្វបានធ្វើការត្រួតពិនិត្យឡើងវិញលើការអនុវត្តការងារសង្គមកិច្ចដោយផ្តោតលើសុខុមាលភាពកុមារ និងសុខុមាលភាពសាធារណៈ នៅឆ្នាំ២០១៤ បានបង្ហាញថាកម្ពុជាមានអត្រាបុគ្គលិកសង្គម ១/១២ ៥០០នាក់ ជាមធ្យមនិងភាគច្រើនមិនទទួលបានការបណ្តុះបណ្តាលជាផ្លូវការក្នុងនាមជាបុគ្គលិកសង្គម។ អត្រាបុគ្គលិកសង្គមនេះមិនទាន់ឆ្លើយតបទៅនឹងសមាមាត្ររវាងបុគ្គលិកសង្គមនឹងប្រជាជននៅឡើយទេ ដែលកម្ពុជាគួរឱ្យតែមានបុគ្គលិកសង្គម ១នាក់ ធៀបនឹងប្រជាជន ៣៥០០នាក់(១/៣៥០០) អាចប្រហាក់ប្រហែលជាមួយប្រទេសក្នុងសមាគមអាស៊ាន និងប្រទេសមួយចំនួនក្នុងពិភពលោក។

កម្លាំងសេវាសង្គមដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រ និងលើកកម្ពស់សុខុមាលភាពរបស់កុមារ គ្រួសារ ក្រុមងាយរងគ្រោះនិងក្រុមរងគ្រោះ ដោយកាត់បន្ថយភាពក្រីក្រ កំណត់និងគ្រប់គ្រងហានិភ័យ និងសម្របសម្រួលការទទួលសេវា និងការផ្តល់សេវាគាំពារសង្គមកិច្ច ដើម្បីធានាថាបុគ្គលទាំងនោះទទួលបានសេវាសុខុមាលភាពដែលពួកគេត្រូវការ។ កម្លាំងសេវាសង្គមដែលមានចំណេះដឹង ជំនាញ និងក្រមសីលធម៌ជ្ជីវ:

គឺជាគន្លឹះក្នុងការលើកកម្ពស់យុត្តិធម៌សង្គម កាត់បន្ថយការរើសអើង ការប្រឈម និងការផ្លាស់ប្តូរអាកប្បកិរិយាដែលមានគ្រោះថ្នាក់និងបទដ្ឋានសង្គម ការពារនិងឆ្លើយតបចំពោះអំពើហិង្សា ការរំលោភបំពាន ការធ្វេសប្រហែស និងការកេងប្រវ័ញ្ចនិងការបែកបាក់គ្រួសារ។ ការអភិវឌ្ឍកម្លាំងសេវាសង្គមគឺជាកត្តាសំខាន់មួយក្នុងការធ្វើឱ្យសម្រេចបាននូវបរិយាបន្នសង្គមសម្រាប់កុមារ ជនពិការ និងក្រុមដែលបាត់ឱកាស។

ផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ២០២២-២០៣១**» គឺជាផែនការដំបូងដែលមានគោលដៅរយៈពេលដប់ឆ្នាំដោយផ្តោតលើការពង្រឹងសមត្ថភាព និងបង្កើនចំនួនកម្លាំងសេវាសង្គមជាពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិដូចបានបង្ហាញនៅក្នុងគោលដៅជាក់លាក់ក្នុងការបង្កើនកម្លាំងសេវាសង្គមនៃឯកសារទម្លីករណ៍ ស្តីពី «**ការវិនិយោគលើកម្លាំងសេវាសង្គមនៅកម្ពុជា**»។ ផែនការយុទ្ធសាស្ត្រនេះគ្របដណ្តប់លើគោលដៅយុទ្ធសាស្ត្រជាអាទិភាពចំនួន៣មាន៖ (១)ផែនការកម្លាំងសេវាសង្គម (២)ការអភិវឌ្ឍកម្លាំងសេវាសង្គម និង(៣)ការគាំទ្រកម្លាំងសេវាសង្គម ដើម្បីធ្វើឱ្យសម្រេចបាននូវទស្សនវិស័យ បេសកកម្ម និងលទ្ធផលរំពឹងទុកដែលបានលើកឡើងនៅក្នុងផែនការយុទ្ធសាស្ត្រនេះ។

ខ្ញុំសូមកោតសរសើរដល់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការយូនីសេហ្វ អង្គការក្លែនអន្តរជាតិ អង្គការ Save the Children អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងអ្នកពាក់ព័ន្ធនានាដែលបានខិតខំចូលរួមកសាងផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ២០២២-២០៣១**»។ ទន្ទឹមនឹងនេះខ្ញុំជឿជាក់យ៉ាងមុតមាំថា គ្រប់ភាគីពាក់ព័ន្ធទាំងអស់នឹងអនុវត្តនូវផែនការយុទ្ធសាស្ត្រនេះ ឱ្យទទួលបានជោគជ័យប្រកបដោយស្មារតីទទួលខុសត្រូវ។

ថ្ងៃព្រហស្បតិ៍ ១០កើត ខែ ភាទ្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ ១២ ឆ្នាំ២០២២

រដ្ឋមន្ត្រី

ទៀ សុផា

មាតិកា

អារម្ភកថា i
មាតិកា iii
អក្សរកាត់ v
ពាក្យគន្លឹះប្រើប្រាស់នៅក្នុងផែនការយុទ្ធសាស្ត្រ ivi
១. សេចក្តីផ្តើម ១
១.១. ស្តង់ដារអន្តរជាតិនៃការងារសន្តិសុខ ១
១.២.ការងារសន្តិសុខនៅក្នុងតំបន់អាស៊ាន ២
១.៣. ការងារសន្តិសុខនៅកម្ពុជា ២
១.៤. ការវិនិយោគលើកម្លាំងសេវាសន្តិសុខ ៣
១.៤.១.គម្លាតគោលនយោបាយ ៣
១.៤.២.លទ្ធផលវិជ្ជមាននៃសេវាគ្រប់គ្រងករណី ៥
១.៤.៣.ការកង្វះកម្លាំងសេវាសង្គមនៅកម្ពុជា ៦
១.៥. ការកំណត់ប្រភេទកម្លាំងសេវាសន្តិសុខ ៧
១.៦. តួនាទីនិងមុខងាររបស់កម្លាំងសេវាសន្តិសុខ ៨
១.៦.១.តួនាទី និងមុខងារកម្លាំងសេវាសង្គមកម្រិតមីក្រូ (Micro) ៨
១.៦.២.តួនាទី និងមុខងារកម្លាំងសេវាសង្គមកម្រិតកណ្តាល (Mezzo) ៨
១.៦.៣.តួនាទី និងមុខងារកម្លាំងសេវាសង្គមកម្រិតមាក្រូ (Macro) ៨
១.៧. ប្រព័ន្ធអតិបាលកិច្ចកម្លាំងសេវាសន្តិសុខ ១០
១.៧.១.ស្ថាប័ននីយកម្មវិជ្ជាជីវៈសង្គមកិច្ច ១១
១.៧.២.វិជ្ជាជីវៈនីយកម្មកម្លាំងសេវាសង្គមកិច្ច ១២
១.៨. ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រជាមួយនឹងឯកសារពាក់ព័ន្ធ ១២
១.៩. ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសន្តិសុខ ១៣
១.១០. ទម្រង់ផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសន្តិសុខ ១៣
២.១. ឥឌ្ឍនភាព ១៤
២.២. បញ្ហាប្រឈម ១៨
៣. ទស្សនៈវិស័យ បេសកកម្ម និងគោលដៅយុទ្ធសាស្ត្រ ២១
៣.១. ទស្សនៈវិស័យ ២១
៣.២. បេសកកម្ម ២១
៣.៣. គោលបំណងគោលនយោបាយ ២១

៣.៤. គោលដៅយុទ្ធសាស្ត្រ ២១
គោលដៅយុទ្ធសាស្ត្រទី១៖ ផែនការកម្លាំងសេវាសង្គម ២២
គោលដៅយុទ្ធសាស្ត្រទី២៖ ការអភិវឌ្ឍកម្លាំងសេវាសង្គម ២៤
គោលដៅយុទ្ធសាស្ត្រទី៣៖ ការគាំទ្រកម្លាំងសេវាសង្គម ២៧
៤. ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ៣១
៥. យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន និងតម្រូវការថវិកា ៣២
៥.១. យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន ៣២
៥.២. តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ៣២
៦. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ៣៣
៦.១. ការត្រួតពិនិត្យតាមដាន ៣៣
៦.២. ការវាយតម្លៃ ៣៤
៧. សេចក្តីសន្និដ្ឋាន ៣៤
ឧបសម្ព័ន្ធ ៣៤

អក្សរកាត់

APSWC	សមាគមអ្នកវិជ្ជាជីវៈសង្គមកិច្ចកម្ពុជា
ASEAN	សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍
BSST	ការបណ្តុះបណ្តាលសេវាសង្គមកិច្ចមូលដ្ឋាន
CCWC	គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំសង្កាត់
IFSW	សហព័ន្ធការងារសង្គមកិច្ចអន្តរជាតិ
IASSW	សមាគមសាលាសង្គមកិច្ចអន្តរជាតិ
MoH	ក្រសួងសុខាភិបាល
MoWA	ក្រសួងកិច្ចការនារី
MoJ	ក្រសួងយុត្តិធម៌
MoI	ក្រសួងមហាផ្ទៃ
MoCS	ក្រសួងមុខងារសាធារណៈ
MoIn	ក្រសួងព័ត៌មាន
MoEYS	ក្រសួងអប់រំ យុវជន និងកីឡា
MoSVY	ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
MSST	ការបណ្តុះបណ្តាលគ្រប់គ្រងសេវាសង្គមកិច្ច
NGOs	អង្គការមិនមែនរដ្ឋាភិបាល
NISA	វិទ្យាស្ថានជាតិសង្គមកិច្ច
RUPP	មហាវិទ្យាល័យភូមិន្ទភ្នំពេញ
PSST	ការបណ្តុះបណ្តាលសេវាសង្គមកិច្ចជំនាញ
SPI	វិទ្យាស្ថានសន្តប៉ូល
SSW	កម្លាំងសេវាសង្គមកិច្ច

ពាក្យគន្លឹះប្រើប្រាស់នៅក្នុងផែនការយុទ្ធសាស្ត្រ

ការងារសង្គមកិច្ច៖ គឺជាវិជ្ជាជីវៈមួយដែលលើកកម្ពស់ឱ្យមានការផ្លាស់ប្តូរនៅក្នុងសង្គម ការដោះស្រាយបញ្ហានៅក្នុងទំនាក់ទំនងមនុស្ស និងការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សំដៅលើកកម្ពស់សុខុមាលភាព។ ដោយប្រើប្រាស់ទ្រឹស្តីនៃឥរិយាបថរបស់មនុស្ស និងប្រព័ន្ធសង្គម ការងារសង្គមកិច្ចចូលធ្វើអន្តរាគមន៍នៅពេលណាមួយ ដែលមនុស្សប្រាស្រ័យទាក់ទងជាមួយបរិយាកាសជុំវិញខ្លួនរបស់ពួកគេ។ គោលការណ៍សិទ្ធិមនុស្ស និងយុត្តិធម៌សង្គម គឺជាមូលដ្ឋានគ្រឹះនៃការងារសង្គមកិច្ច។[1]

កម្លាំងសេវាសង្គម៖ គឺសំដៅដល់ជនទាំងឡាយណា ទាំងមន្ត្រីរាជការ បុគ្គលិកសមាគម និងអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងរូបវន្តបុគ្គល ទោះជាអ្នកអាជីព អ្នកអាជីពរង ឬអ្នកមានជំនាញច្បាស់លាស់ផ្នែកការងារសង្គមកិច្ច ដោយយកកម្រៃ ឬមិនយកកម្រៃ ធ្វើការដើម្បីធានាបាននូវការអភិវឌ្ឍសុខុមាលភាពរបស់អតិថិជន។ កម្លាំងសេវាសង្គមត្រូវមានគុណតម្លៃស្នូលរបស់ខ្លួនបីយ៉ាងរួមមាន ការគោរពសិទ្ធិនិងសេចក្ដីថ្លៃថ្នូររបស់មនុស្ស យុត្តិធម៌សង្គម និងសុចរិតភាពវិជ្ជាជីវៈ។ កម្លាំងសេវាសង្គមមានប្រភេទដូចខាងក្រោម[2]៖

- **អ្នកអាជីពសង្គមកិច្ច៖** ជាអ្នកដែលមានជំនាញវិជ្ជាជីវៈក្នុងការផ្តល់សេវាសង្គមកិច្ចទាំងមូល។ អ្នកអាជីពសង្គមកិច្ចត្រូវមានសញ្ញាបត្រសង្គមកិច្ចដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងមានអាជ្ញាប័ណ្ណទទួលស្គាល់ដោយស្ថាប័នជំនាញសាធារណៈផ្នែកសង្គមកិច្ច។

- **អ្នកអាជីពសង្គមកិច្ចរង៖** ជាអ្នកដែលធ្វើការអមជាមួយ ឬជួយការងាររបស់អ្នកអាជីពសង្គមកិច្ច។ អ្នកអាជីពសង្គមកិច្ចរង ត្រូវបានបណ្តុះបណ្តាលឱ្យបំពេញមុខងារជាក់លាក់មួយចំនួន ប៉ុន្តែមិនតម្រូវឱ្យមានការបញ្ជាក់ ឬផ្តល់អាជ្ញាប័ណ្ណទទួលស្គាល់ដោយស្ថាប័នជំនាញសាធារណៈផ្នែកសង្គមកិច្ច ដូចអ្នកអាជីពសង្គមកិច្ចនោះទេ តែក្នុងមុខងារខ្លះតម្រូវឱ្យមានសញ្ញាបត្រឯកទេស។

- **អ្នកសង្គមកិច្ចបឋម៖** គឺជាអ្នកដែលកំពុងធ្វើការក្នុងផ្នែកសង្គមកិច្ច ឬជាអ្នកស្ម័គ្រចិត្ត ដែលភាគច្រើនធ្វើការនៅសហគមន៍ ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសពីអ្នកអាជីពសង្គមកិច្ច ឬអ្នកអាជីពសង្គមកិច្ចរង។ អ្នកសង្គមកិច្ចបឋម បម្រើដល់តម្រូវការរបស់អតិថិជន រួមទាំងកុមារ និងគ្រួសារជាពិសេសនៅក្នុងកន្លែងដែលប្រព័ន្ធសុខុមាលភាពសង្គមមិនទាន់បានបង្កើត ឬមានកម្រិតនៅឡើយ។

- **អ្នកសង្គមកិច្ចសម្ព័ន្ធ៖** គឺជាអ្នកដែលផ្តល់សេវាសង្គម ប៉ុន្តែត្រូវបានផ្សារភ្ជាប់ជាមួយនឹងវិស័យផ្សេងទៀតដូចជា ការអប់រំ សុខភាព ឬយុត្តិធម៌។ ឧទាហរណ៍រួមមាន គិលានុបដ្ឋាយិកា មេធាវី វេជ្ជបណ្ឌិត និងគ្រូបង្រៀន និងអ្នកផ្សេងទៀត។ បុគ្គលិកសម្ព័ន្ធសង្គមកិច្ចអនុវត្តមុខងារជាច្រើនដែលធ្វើឱ្យប្រសើរឡើង ការគាំទ្រ ឬសម្របសម្រួលមុខងារដែលអនុវត្តដោយកម្លាំងសេវាសង្គមផ្សេងទៀត។

---

[1] យោងតាមការកំណត់និយមន័យដោយសមាគមសាលាសង្គមកិច្ចអន្តរជាតិ IASSW និងសហព័ន្ធបុគ្គលិកសង្គមកិច្ចអន្តរជាតិ IFSW

[2] សេចក្ដីព្រាងអនុក្រឹត្យ ស្ដីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់កម្លាំងសេវាសង្គម

គោលការណ៍កម្លាំងសេវាសង្គម៖ កម្លាំងសេវាសង្គម ត្រូវគោរពសិទ្ធិជាមូលដ្ឋាន និងសេចក្តីថ្លៃថ្នូរពីកំណើតរបស់បុគ្គលគ្រប់រូប ហើយបង្ហាញនូវការយកចិត្តទុកដាក់ដោយឥតលំអៀងខ្ពស់ ដើម្បីគាំទ្រ និងការពារបុគ្គលគ្រប់រូប ទាំងសុខភាពផ្លូវកាយ សុខភាពផ្លូវចិត្ត និងសុខុមាលភាព។ កម្លាំងសេវាសង្គមត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍សំខាន់ៗ ដូចខាងក្រោម[3]៖

- ត្រូវគោរព និងលើកកម្ពស់សិទ្ធិរបស់អតិថិជនក្នុងការសម្រេចចិត្តដោយខ្លួនឯង ដោយមិនគិតពីយេនឌ័រ ជំនឿសាសនា មនោគមន៍វិជ្ជា ស្ថានភាពសេដ្ឋកិច្ច និងជម្រើសនៃជីវិតរបស់ពួកគេដរាបណាការសម្រេចចិត្តទាំងនោះមិនប៉ះពាល់ ឬគំរាមកំហែងដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់ផ្សេងទៀតឡើយ។
- ត្រូវលើកកម្ពស់ការចូលរួមរបស់ប្រជាជនក្នុងការទទួលសេវាដោយស្ម័គ្រចិត្ត ដើម្បីឱ្យពួកគាត់ទទួលបាននូវសិទ្ធិ និងអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងធ្វើសកម្មភាពដែលមិនប៉ះពាល់ដល់ជីវិត និងផលប្រយោជន៍របស់ពួកគាត់ ឬរបស់អ្នកដទៃ។
- ត្រូវយកចិត្តទុកដាក់ទៅលើបុគ្គលម្នាក់ៗ ដោយផ្តោតទៅលើទិដ្ឋភាពរួមដូចជា គ្រួសារ សហគមន៍ សង្គម និងបរិស្ថានរស់នៅ។
- ត្រូវសិក្សាកំណត់រកភាពខ្លាំងរបស់បុគ្គល ក្រុម និងសហគមន៍ ដើម្បីអភិវឌ្ឍភាពខ្លាំងរបស់ពួកគេ។
- ត្រូវទទួលស្គាល់ និងគោរពនូវភាពចម្រុះនៃជាតិពន្ធុ និងវប្បធម៌ យកចិត្តទុកដាក់លើភាពខុសៗគ្នារបស់បុគ្គល គ្រួសារ ក្រុម និងសហគមន៍។

ក្រមសីលធម៌កម្លាំងសេវាសង្គម៖ កម្លាំងសេវាសង្គម ត្រូវគោរពនូវសិទ្ធិ គុណតម្លៃ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដោយមិនប្រកាន់អំពី ជំនឿ សាសនា ភាសា ភេទ អាយុ ធនធាន វប្បធម៌ ពូជសាសន៍ ពណ៌សម្បុរ ឋានៈសង្គម និន្នាការនយោបាយ និងស្ថានភាពឯទៀតនៃការផ្តល់សេវា ដើម្បីធានាថាអតិថិជន និងភាគីពាក់ព័ន្ធទទួលបានព័ត៌មាន និងចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត។ កម្លាំងសេវាសង្គមត្រូវមានក្រមសីលធម៌ដូចជា[4]៖

- មិនត្រូវធ្វើបុរេវិនិច្ឆ័យអតិថិជនដោយគ្មានមូលដ្ឋាននៃការវាយតម្លៃពីអ្នកវិជ្ជាជីវៈ ដើម្បីកុំឱ្យជះឥទ្ធិពលមិនល្អដល់ការអនុវត្តសេវាសង្គមកិច្ច។
- ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈក្នុងលំក្ខខ័ណ្ឌដែលបានកំណត់ដោយច្បាប់ និងបទបញ្ញត្តិនានាដើម្បីឧត្តមប្រយោជន៍របស់អតិថិជន។
- ត្រូវប្តេជ្ញាចិត្តធានាយុត្តិធម៌សង្គម និងសិទ្ធិមនុស្សតាមរយៈការលើកកម្ពស់ ការអនុវត្តច្បាប់ គោលនយោបាយ បទដ្ឋានគតិយុត្តផ្សេងៗ និងលំក្ខខ័ណ្ឌសង្គមប្រកបដោយសមធម៌ និងសមភាព គោរពនិងទទួលស្គាល់ភាពចម្រុះគ្នា បង្កើនភាពអង់អាចដល់បុគ្គល គ្រួសារ និងសហគមន៍ ធ្វើការវិភាគបញ្ហា តម្រូវការសង្គម និងធ្វើផែនការឆ្លើយតប។
- មិនត្រូវផ្តល់ការសម្របសម្រួលណាមួយ ដែលនាំឱ្យខ្លួនប្រព្រឹត្តផ្ទុយនឹងច្បាប់ និងបទបញ្ជាឡើយ។
- ត្រូវជៀសវាងការប្រព្រឹត្តអំពើទាំងឡាយណា ដែលធ្វើឱ្យអាប់ឱនដល់កិត្តិយស និងវិជ្ជាជីវៈរបស់ខ្លួន។

[3] សេចក្តីព្រាងអនុក្រឹត្យ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់កម្លាំងសេវាសង្គម

[4] សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់កម្លាំងសេវាសង្គម

- ត្រូវអនុវត្តការងាររបស់ខ្លួនប្រកបដោយវិជ្ជាជីវៈ និងមានការទទួលស្គាល់ពីស្ថាប័នជំនាញវិជ្ជាជីវៈ សង្គមកិច្ចរបស់រាជរដ្ឋាភិបាល។
- ត្រូវស្វ័យសិក្សា ស្រាវជ្រាវសម្រិតសម្រាំង បង្កើនចំណេះដឹងរបស់ខ្លួន និងចូលរួមគ្រប់សកម្មភាពអភិវឌ្ឍសមត្ថភាព ជំនាញវិជ្ជាជីវៈថ្មីៗជាប្រចាំ និងមានការគាំទ្រផ្នែកបច្ចេកទេសដើម្បីធានាបាននូវសង្គតិភាពនៃការផ្តល់សេវាប្រកបដោយគុណភាព គណនេយ្យភាព តម្លាភាព និងទាន់ពេលវេលាសម្រាប់ខ្លួនឯង និងអតិថិជនឱ្យទទួលបាននូវសុខុមាលភាព។
- ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ ក្នុងការអនុវត្តមុខងាររបស់ខ្លួន និងការផ្តល់សេវាដល់អតិថិជន ដើម្បីធានាថា គ្មានការប្រើអំណាច កេងប្រវ័ញ្ច រំលោភបំពាន បំពានសិទ្ធិ ទំនាស់ផលប្រយោជន៍ និងសកម្មភាពទាំងឡាយណាដែលផ្ទុយនឹងច្បាប់រដ្ឋ។
- ត្រូវប្រើឥរិយាបថ និងពាក្យសម្តីដោយប្រុងប្រយ័ត្ន និងគិតដល់ប្រតិយាតនៃពាក្យសម្តីរបស់ខ្លួនចំពោះអតិថិជន និងសាធារណៈជនក្នុងការផ្តល់ព័ត៌មានអំពីការផ្តល់សេវាទាំងសាធារណៈ ទាំងឯកជនតាមគ្រប់មធ្យោបាយផ្សព្វផ្សាយ។

១. សេចក្តីផ្តើម

១.១. ស្តង់ដារអន្តរជាតិនៃការងារសង្គមកិច្ច

សហព័ន្ធការងារសង្គមកិច្ចអន្តរជាតិ (IFSW) និងសមាគមសាលាសង្គមកិច្ចអន្តរជាតិ (IASSW) ផ្តល់នូវសមត្ថភាពសម្រាប់បុគ្គលិកសង្គមកិច្ចសង្កត់ធ្ងន់លើតម្រូវការ និងផ្តល់ព័ត៌មានលម្អិតដើម្បីលើកកម្ពស់ស្តង់ដារវិជ្ជាជីវៈសម្រាប់ការអប់រំការងារសង្គមកិច្ច។[5] ស្របពេលដែលកម្ពុជាមានគោលនយោបាយ បរិបទវប្បធម៌និងសង្គម ទិដ្ឋភាពទូទៅនៃនិយមន័យការងារសង្គមកិច្ចសកល និងគោលការណ៍សំខាន់ៗ អាចដើរតួនាទីជាគោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍស្តង់ដារវិជ្ជាជីវៈការងារសង្គមកិច្ច។ ការបង្កើតឡើងតាមរយៈដំណើរការដែលមានការចូលរួមយ៉ាងជិតស្និទ្ធរវាង IFSW និង IASSW និយមន័យចុងក្រោយនៃការងារសង្គមកិច្ចគឺ៖

ការងារសង្គមកិច្ចគឺជាវិជ្ជាជីវៈផ្អែកលើការអនុវត្ត និងវិន័យសិក្សាដែលជំរុញការផ្លាស់ប្តូរនិងការអភិវឌ្ឍសង្គម ការរួបរួមគ្នាក្នុងសង្គមនិងការផ្តល់សិទ្ធិអំណាច និងការជួយមនុស្ស។ គោលការណ៍នៃយុត្តិធម៌សង្គម សិទ្ធិមនុស្ស ការទទួលខុសត្រូវជាសមូហភាព និងការគោរពចំពោះភាពចម្រុះគឺជាចំណុចស្នូលនៃការងារសង្គមកិច្ច។ គាំទ្រដោយទ្រឹស្តីនៃការងារសង្គមកិច្ច វិទ្យាសាស្ត្រសង្គម មនុស្សជាតិ និងចំណេះដឹងជនជាតិដើម ការងារសង្គមកិច្ចភ្ជាប់មនុស្ស និងរចនាសម្ព័ន្ធដើម្បីដោះស្រាយបញ្ហាប្រឈមក្នុងជីវិត និងលើកកម្ពស់សុខុមាលភាព។[6]

គោលការណ៍ស្នូលនៃស្តង់ដារពិភពលោកសម្រាប់ការអប់រំ និងការបណ្តុះបណ្តាលការងារសង្គមកិច្ចគឺ «ការគោរពតម្លៃ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស មិនធ្វើឱ្យគ្រោះថ្នាក់ គោរពភាពចម្រុះ លើកស្ទួយសិទ្ធិមនុស្ស និងយុត្តិធម៌សង្គម»។[7] មូលដ្ឋានចំណេះដឹងនៃការងារសង្គមកិច្ចគឺ «កម្មសិក្សាអន្តរក្រសួង» ផ្អែកលើទ្រឹស្តី វិទ្យាសាស្ត្រ និងការស្រាវជ្រាវរួមបញ្ចូលការអភិវឌ្ឍសហគមន៍ គរុកោសល្យសង្គម រដ្ឋបាល នរវិទូ បរិស្ថានវិទ្យា សេដ្ឋកិច្ច ការអប់រំ ការគ្រប់គ្រង ការថែទាំ វិកលវិទ្យា ចិត្តវិទ្យា សុខភាពសាធារណៈ និងសង្គមវិទ្យា។[8]

មានឥទ្ធិពលខ្លាំងនៃគំរូសង្គមលោកខាងលិចនៃការអនុវត្តការងារសង្គមកិច្ចលើស្តង់ដារអន្តរជាតិនៃការងារសង្គមកិច្ច។ ដោយសារតែការងារសង្គមកិច្ចត្រូវបានបង្កើតឡើងដំបូងជាអាជីពនៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងនៅបណ្តាប្រទេសអឺរ៉ុបខាងលិចដទៃទៀត សព្វថ្ងៃសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេសមានសមាគមវិជ្ជាជីវៈរឹងមាំនៅថ្នាក់ជាតិដែលជះឥទ្ធិពលដល់ IFSW និងIASSW។[9] ការអភិវឌ្ឍរីកចម្រើននៅបណ្តាប្រទេសទាំងនេះក៏មានក្រមសីលធម៌ និងបទដ្ឋានដែលបានកំណត់សម្រាប់ការអនុវត្តដូចដែលបានពិពណ៌នានៅក្នុងសមាគមជាតិការងារសង្គមកិច្ចរបស់សហរដ្ឋអាមេរិក និងអង្គភាពទទួលស្គាល់ការអប់រំ (ក្រុមប្រឹក្សាអប់រំការងារសង្គមសហរដ្ឋអាមេរិក និងក្របខណ្ឌសមត្ថភាព)។ ប្រទេសទាំងនេះបាន

[5] Harachi, Tracy W., 2014.
[6] IFSW, "Global Definition of Social Work", 2014, <https://www.ifsw.org/what-is-social-work/global-definition-of-social-work/>, accessed July 11, 2018
[7] Ibid.
[8] Ibid.
[9] Roby, Jini L., and Rotabi, Karen S., 2017.

កំណត់យ៉ាងច្បាស់នូវដំណើរការវាយតម្លៃកម្មវិធីសម្រាប់សាលាការងារសង្គមកិច្ចដែលត្រូវបានតាក់តែងតាមស្តង់ដារនៃការអនុវត្តសមត្ថភាព និងជំនាញ។[10] ទោះបីជាមានឥទ្ធិពលរបស់លោកខាងលិចខ្លាំងនៅក្នុងគំរូនៃការអនុវត្តការងារសង្គមកិច្ចក៏ដោយ ស្តង់ដារពិភពលោកសម្រាប់ការអប់រំ និងការបណ្តុះបណ្តាលការងារសង្គមកិច្ចត្រូវបានកោតសរសើរនៅពេលដែលបានប្រើជាគោលការណ៍ណែនាំសំខាន់នៃវិជ្ជាជីវៈការងារសង្គមកិច្ច។ គោលនយោបាយ និងបទដ្ឋានអនុវត្តនៅក្នុងបណ្តាប្រទេសអាស៊ានដទៃទៀតបង្ហាញថាមានភាពបត់បែនក្នុងការសម្របសម្រួលក្របខណ្ឌអនុវត្តអន្តរជាតិទៅក្នុងបរិបទសមូហភាពនៃតំបន់អាស៊ាន។

១.២. ការងារសង្គមកិច្ចនៅក្នុងតំបន់អាស៊ាន

នៅក្នុងតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ មានបរិបទនិងគំនិតផ្តួចផ្តើមផ្នែកសុខុមាលភាពសង្គមជាច្រើនទាក់ទងនឹងបរិបទនយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ ទោះបីជាយ៉ាងណាក៏ដោយមានកិច្ចខិតខំប្រឹងប្រែងសំខាន់ៗនៅក្នុងការបង្កើតបទដ្ឋានអនុវត្តរួមគ្នា។ គិតត្រឹមឆ្នាំ២០១៤ មានតែប្រទេសហ្វីលីពីន និងសឹង្ហបូរីប៉ុណ្ណោះដែលមានបទដ្ឋាន សម្រាប់កម្មវិធីអប់រំសង្គមកិច្ច។ ប្រទេសម៉ាឡេស៊ី ហ្វីលីពីន ឥណ្ឌូនេស៊ី សឹង្ហបូរី ថៃ និង វៀតណាម បានបង្កើតចំណាត់ថ្នាក់ការងារ ដែលមានការគ្រប់គ្រងត្រួតពិនិត្យត្រឹមត្រូវ។ ប្រទេសម៉ាឡេស៊ី ហ្វីលីពីន និងសឹង្ហបូរីមានកម្មវិធីចុះបញ្ជី និង/ឬអាជ្ញាប័ណ្ណ ហើយសមាគមវិជ្ជាជីវៈត្រូវបានបង្កើតឡើងនៅក្នុងប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សឹង្ហបូរី និងថៃ។[11] ក្នុងស្ថានភាពស្រដៀងគ្នានេះ ប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការបង្កើតការអប់រំសង្គមកិច្ច និងការរៀបចំការងារសង្គមកិច្ចឱ្យទៅជាវិជ្ជាជីវៈ ក្រោមកិច្ចសហប្រតិបត្តិការពីការិយាល័យប្រចាំប្រទេសនៃអង្គការយូនីសេហ្វ។[12] ការបង្កើតបទដ្ឋានសង្គមកិច្ច នៅក្នុងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ បានជួយដល់ប្រទេសកម្ពុជា ក្នុងការរៀបចំនិងពង្រឹងបទដ្ឋានអនុវត្តផ្នែកសង្គមកិច្ច និងការបង្កើតវិជ្ជាជីវៈផ្នែកសង្គមកិច្ច។

១.៣. ការងារសង្គមកិច្ចនៅកម្ពុជា

កាលពីអតីតកាលនៅកម្ពុជា គ្រូខ្មែរ និងស្ថាប័នសាសនា ព្រមទាំងស្ថាប័នដទៃទៀតបានដើរតួនាទីមួយដ៏សំខាន់ក្នុងការដោះស្រាយបញ្ហាសង្គម រហូតដល់ឆ្នាំ១៩៤៧ ទើបចាប់ផ្តើមមានស្ថាប័នដឹកនាំការងារសង្គមកិច្ច ហើយបានផ្លាស់ប្តូរឈ្មោះស្ថាប័ន និងឈ្មោះថ្នាក់ដឹកនាំជាបន្តបន្ទាប់ទៅតាមសម័យកាលនីមួយៗ។ កន្លងមកមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅក្នុងសង្គមកម្ពុជាទាក់ទងទៅនឹងអ្នកផ្តល់ជំនួយតាមបែបទម្លាប់ និងការផ្តល់សេវាសង្គមកិច្ចនាពេលបច្ចុប្បន្ន។ ចាប់តាំងពីមានវត្តមានរបស់អ៊ុនតាក់ បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល បានដើរតួនាទីជាអ្នកផ្តល់សេវាសង្គមកិច្ចដ៏សំខាន់នៅក្នុងវិស័យជាច្រើន ខណៈពេលដែលកម្ពុជាបានចាប់ផ្តើមធ្វើការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពរបស់ខ្លួន។ ការងារសង្គមកិច្ច គឺជាការងារមួយថ្មីស្រឡាងនៅប្រទេសកម្ពុជា និងមិនទាន់ត្រូវបានកំណត់វិសាល

[10] Vitali, Sharon. The Acquisition of Professional Social Work Competencies, 2011
[11] Roby, Jini L., and Rotabi, Karen S., 2017.
[12] Costello, S & Aung, U. T. Developing social work education in Myanmar. International Social Work, 2015; UNICEF. UNICEF Annual Report, Lao People's Democratic Republic, 2015

ភាពការងារនេះនៅឡើយ។ ការងារសង្គមកិច្ចមិនគ្រាន់តែជាសកម្មភាពសប្បុរសធម៌ ឬចេតនាល្អតែប៉ុណ្ណោះទេ ប៉ុន្តែគឺជាសកម្មភាព និងអន្តរាគមន៍ដែលមានប្រភពមូលដ្ឋានផ្អែកលើចំណេះដឹង និងការស្រាវជ្រាវ។

ទាក់ទងទៅនឹងកម្មវិធីអប់រំការងារសង្គមកិច្ចដែលផ្តល់សញ្ញាបត្រជាផ្លូវការនៅប្រទេសកម្ពុជាមានកម្មវិធីចំនួន៤រួមមាន៖ បរិញ្ញាបត្រចំនួន ៣ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១ មានរហូតដល់ថ្នាក់បណ្ឌិតផ្នែកសង្គមកិច្ចវិទ្យានៅសកលវិទ្យាភូមិន្ទភ្នំពេញនៅឆ្នាំ២០២១ ដែលជាការវិវត្តន៍ថ្មីបន្ថែមទៀតលើការអភិវឌ្ឍ ការអប់រំវិជ្ជាជីវៈសង្គមកិច្ច។ រួមគ្នាជាមួយកម្មវិធីសង្គមកិច្ចនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិសង្គមកិច្ច និងវិទ្យាស្ថានសន្តប៉ូល គឺជាមាគ៌ាសិក្សាចំនួនបីឆ្ពោះទៅរកការងារសង្គមកិច្ចនៅក្នុងប្រទេសកម្ពុជា។ រហូតមកដល់ពេលនេះកម្មវិធីនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ហាក់ដូចជាស្ថាប័នតែមួយគត់មានសមត្ថភាព និងស្តង់ដារដែលបានកំណត់សម្រាប់ការបណ្តុះបណ្តាលផ្នែកសង្គមកិច្ចវិទ្យា។[13] លើសពីនេះគ្មានយន្តការថ្នាក់ជាតិផ្តល់ការត្រួតពិនិត្យដល់កម្មវិធី និងបុគ្គលិកសង្គមកិច្ចដែលគួរតែមានស្តង់ដារឯកភាពសម្រាប់អនុវត្តអន្តរាគមន៍សង្គមនៅទូទាំងប្រទេស។[14] លើសពីនេះទៀតខណៈពេលដែលអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមានជនបរទេសមានវិជ្ជាជីវៈ និងគុណតម្លៃសម្រាប់ការបណ្តុះបណ្តាល ត្រួតពិនិត្យ និងផ្តល់ការគាំទ្រដល់ក្រុមការងារសង្គមកិច្ច ក៏ដូចជាជួយដល់ករណីលំបាក។[15]

ទោះបីជាកន្លងមកមានកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងការងារសង្គមកិច្ចនៅកម្ពុជាក៏ដោយ ក៏នៅមានចំណុចខ្សោយមួយចំនួននៅក្នុងប្រព័ន្ធសុខុមាលភាពសង្គម និងការងារសង្គមកិច្ចបច្ចុប្បន្ន។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបានការវិភាជថវិកាប្រចាំឆ្នាំ និងធនធានមនុស្សនៅមានកម្រិត។ ការពង្រីកសេវាសង្គមកិច្ចរបស់រដ្ឋាភិបាលជាពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅតែប្រឈមមុខនឹងបញ្ហាធនធានមនុស្សដោយសាររដ្ឋាភិបាលបានកំណត់ចំនួនការជ្រើសរើសមន្ត្រីថ្មី ជារៀងរាល់ឆ្នាំសម្រាប់ជំនួសបុគ្គលិកដែលត្រូវចូលនិវត្តន៍។[16] នេះគួសបញ្ជាក់ពីសារៈសំខាន់ក្នុងការរៀបចំបង្កើតស្ថាប័នវិជ្ជាជីវៈការងារសង្គមកិច្ច និងជាពេលវេលាដ៏សំខាន់ក្នុងការតស៊ូមតិសម្រាប់បង្កើនធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស និងការអភិវឌ្ឍសមត្ថភាពកម្លាំងសេវាសង្គមនៅកម្ពុជា ជាពិសេសនៅថ្នាក់ក្រោមជាតិ ដូចដែលបានបង្ហាញនៅក្នុងការវាយតម្លៃតំបន់នាពេលថ្មីៗនេះ ស្តីពី «កម្លាំងសេវាសង្គមនៅកម្ពុជា»។

១.៤. ការវិនិយោគលើកម្លាំងសេវាសង្គម

១.៤.១.គម្លាតគោលនយោបាយ

ប្រព័ន្ធការងារសង្គមដើរតួនាទីជាសមាសធាតុសំខាន់នៃប្រព័ន្ធសំណាញ់សុវត្ថិភាពសង្គម ហើយបុគ្គលិកសង្គមគឺស្ថិតនៅជួរមុខក្នុងការការពារអតិថិជនដោយអនុវត្តគោលនយោបាយ និងផ្តល់សេវា។ លើសពីនេះទៀតតម្រូវការជំនាញការងារសង្គម និងធនធានមនុស្សត្រូវបានទទួលស្គាល់នៅក្នុងគោល

[13] Roby, Jini L., and Rotabi, Karen S., 2017.
[14] Ibid.
[15] Turton, Shaun, 2014.
[16] Global Social Service Workforce Alliance: *Multi-Country Review of Social Service Workforce in the East Asia and Pacific Region (draft), April 2019*

នយោបាយផ្សេងៗគ្នា។ ច្បាប់ ស្តីពី «យុត្តិធម៌អនីតិជន (២០១៦)» ដែលបានផ្តោតលើកម្មវិធីបង្វែរ។ ដើម្បីអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព មន្ត្រីរាជរដ្ឋាភិបាលត្រូវគោរពគោលការណ៍សិទ្ធិកុមារ និងមានសមត្ថភាពធ្វើការជាមួយអនីតិជន និងពង្រឹងការអនុវត្តច្បាប់។ គោលនយោបាយជាតិ ស្តីពី «មនុស្សវ័យចាស (២០១៧-២០៣០)» បានលើកឡើងពីការព្រួយបារម្ភអំពីសុខភាពនិងសុខុមាលភាពមនុស្សវ័យចាស់ និងកម្លាំងសេវាសង្គមមើលថែទាំ។ មន្ត្រីនៅក្នុងផ្នែកនេះគួរតែយល់ច្បាស់អំពីប្រធានបទ ស្តីពី ការអភិវឌ្ឍ អាយុកាល ការរំលោភបំពានមនុស្សវ័យចាស់ ប្រព័ន្ធថែទាំសុខភាព និងតម្រូវការរបស់មនុស្សវ័យចាស់ដែលមានពិការភាព។ គោលនយោបាយជាតិ ស្តីពី «ប្រព័ន្ធកិច្ចការពារកុមារ (២០១៩-២០២៩)» បានកំណត់គោលដៅកសាងធនធានមនុស្ស និងពង្រឹងសមត្ថភាពអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត នៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធកិច្ចការពារកុមារ ជាពិសេសនៅឃុំ សង្កាត់ និងភូមិ ដោយកំណត់យុទ្ធសាស្ត្រកសាងធនធានមនុស្ស ការអប់រំផ្សព្វផ្សាយ និងការបណ្តុះបណ្តាលផ្នែកសង្គមកិច្ចវិទ្យា និងការកៀរគរធនធានហិរញ្ញវត្ថុ។ គោលនយោបាយ ស្តីពី «ការថែទាំជំនួសចំពោះកុមារ (២០០៦)» បានកំណត់លើការថែទាំសម្រាប់កុមារកំព្រា និងកុមារដែលងាយរងគ្រោះឯទៀតដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើត។ ការថែទាំជំនួសចំពោះកុមារមានពីរប្រភេទគឺការថែទាំក្នុងមណ្ឌល និងការថែទាំក្រៅមណ្ឌលឬការថែទាំនៅតាមសហគមន៍ ឬគ្រួសារ។ ការថែទាំជំនួសចំពោះកុមារតម្រូវឱ្យមានកម្លាំងសេវាសង្គមដើម្បីផ្តល់សេវាថែទាំ និងការគ្រប់គ្រងករណី។

ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦-២០២៥) បង្ហាញពីសារៈសំខាន់លើកិច្ចគាំពារសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព។ ទន្ទឹមនឹងនេះត្រូវជំរុញការអភិវឌ្ឍធនធានមនុស្ស និងកំណើនសេដ្ឋកិច្ចជាតិ។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមមានគោលបំណងបង្រួបបង្រួម បញ្ចូលគ្នា និងពង្រឹងយន្តការដែលមានស្រាប់ និងពង្រីកមូលដ្ឋានគាំពារសង្គមដើម្បីឆ្លើយតបទៅនឹងកត្តាទាំងអស់ក្នុងវដ្តជីវិត។ ពិនិត្យមើលជាពិសេសលើសសរស្តម្ភជំនួយសង្គមរាជរដ្ឋាភិបាលកម្ពុជានឹងពង្រីកកិច្ចការពារមនុស្សវ័យចាស់ ជនពិការ ស្ត្រីមានផ្ទៃពោះនិងកុមារនៅក្នុងមធ្យមសក្សាចំណេះទូទៅសាធារណៈ។ ដូច្នេះកម្លាំងសេវាសង្គមមានសារៈសំខាន់ណាស់ក្នុងការធានាឱ្យមានប្រសិទ្ធិភាព និងការអនុវត្តគោលនយោបាយនេះ តាមរយៈការចូលរួមចំណែកក្នុងការកំណត់អត្តសញ្ញាណអ្នកទទួលផលនិងតាមដានត្រួតពិនិត្យករណីជាក់លាក់ចំពោះអតិថិជន និងការភ្ជាប់ទំនាក់ទំនង ជាមួយសេវាកម្មផ្សេងទៀត។ សមធម៌ និងសាមគ្គីភាពក្នុងសង្គម គឺជាគោលការណ៍សំខាន់នៅពីក្រោយគោលនយោបាយនេះដែលអាចទទួលបានការគាំទ្រពីការជ្រើសរើសបុគ្គលិកសង្គមកិច្ច។ លើសពីនេះទៅទៀតមានច្បាប់ជាច្រើន ស្តីពី បញ្ហាសង្គមដូចជា អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស និងការស្ទុះកូនចិញ្ចឹមដែលអាចទទួលបានអត្ថប្រយោជន៍ពីការមានបុគ្គលិកសង្គមចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយ និងការផ្តល់សេវាកម្ម។

ដោយសារគោលនយោបាយ និងបញ្ហាសង្គមទាំងអស់នេះត្រូវការជំនាញនិងចំណេះដឹងពីការងារសង្គមកិច្ចហើយនឹងទទួលបានអត្ថប្រយោជន៍ពីការមានបុគ្គលិកសង្គមកិច្ចចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយ និងការផ្តល់សេវា។ ទោះយ៉ាងណា បច្ចុប្បន្ននេះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង

យុវនីតិសម្បទា មិនមានការកំណត់ចំនួនជាអាទិភាពដើម្បីជ្រើសរើសអ្នកមានបទពិសោធន៍ការងារសង្គមកិច្ច ដែលនាំឱ្យការផ្តល់សេវាសង្គមកិច្ចនៅមានកម្រិត។ ដូច្នេះ ជាការចាំបាច់សម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដើម្បីជ្រើសរើសបុគ្គលិកសង្គមកិច្ច ដែលជាផ្នែកមួយនៃរចនាសម្ព័ន្ធមន្ត្រីរាជការរបស់ក្រសួងសម្រាប់ពង្រឹងការអនុវត្តគោលនយោបាយគាំពារសង្គម និងកិច្ចការពារកុមារទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការការពារអំពើហឹង្សាលើកុមារ និងបញ្ហាការពារកុមារដទៃទៀតទាមទារឱ្យមានការសហការគ្នារវាងវិស័យជាច្រើនរបស់រដ្ឋាភិបាល សង្គមស៊ីវិលសហគមន៍ និងក្រុមគ្រួសារ។ លក្ខណៈពហុជំនាញនៃវិជ្ជាជីវៈការងារសង្គមកិច្ច អាចលើកកម្ពស់សេវាកម្មរបស់ក្រសួងសុខាភិបាល ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងអប់រំ យុវជន និងកីឡាប្រសិនបើផ្តល់តាមរយៈបរិយាកាសសហការ។[17] ដូច្នេះក៏មានភាពចាំបាច់ក្នុងការពង្រឹងសញ្ញាណមួយដែលមានវិជ្ជាជីវៈសង្គមកិច្ចធ្វើការងារអន្តរកម្មតាមលក្ខណៈបុគ្គលិកដើម្បីបង្កើនចំនួនបុគ្គលិកសង្គមកិច្ច។

១.៤.២.លទ្ធផលវិជ្ជមាននៃសេវាគ្រប់គ្រងករណី

ការវិនិយោគលើកម្លាំងសេវាសង្គម មានផលចំណេញខាងសេដ្ឋកិច្ច និងសុខុមាលភាពសង្គម នៅពេលមានការគ្រប់គ្រងករណីបានត្រឹមត្រូវចំពោះអតិថិជននៅតាមសហគមន៍ ហើយមានភ័ស្តុតាងបញ្ជាក់ថានៅពេលកម្លាំងសេវាសង្គមទទួលបានការបណ្តុះបណ្តាល និងការគាំទ្រគ្រប់ជ្រុងជ្រោយនឹងមានលទ្ធភាពចូលរួមដោះស្រាយបញ្ហារបស់អតិថិជន។[18] តួនាទីចម្បងរបស់កម្លាំងសេវាសង្គម គឺការប្រាស្រ័យទាក់ទង និងវាយតម្លៃទៅលើជនរងគ្រោះ និងងាយរងគ្រោះដើម្បីកំណត់ហានិភ័យ ជួយក្រុមគ្រួសាររកដំណោះស្រាយចំពោះបញ្ហារបស់ពួកគេ បញ្ជូនទៅសេវាសង្គម ហើយចុងក្រោយដើម្បីកែលម្អជីវិតរបស់អតិថិជនតាមរយៈសេវាគ្រប់គ្រងករណី។ លើសពីនេះទៅទៀតកម្លាំងសេវាសង្គមកំពុងតែលើកកម្ពស់ការផ្លាស់ប្តូរសង្គម និងពង្រឹងសិទ្ធិអំណាចដល់ប្រជាជនដើម្បីលើកកម្ពស់សុខុមាលភាពរបស់ពួកគេ។ ទំនួលខុសត្រូវ និងផលប៉ះពាល់ដ៏ធំធេងដែលកម្លាំងសេវាសង្គមមានលើកុមារ ធ្វើឱ្យពួកគេក្លាយជាការវិនិយោគដ៏សំខាន់មួយសម្រាប់អនាគតរបស់ប្រទេស ខណៈដែលក្រុមគ្រួសារប្រឈមមុខនឹងភាពងាយរងគ្រោះខាងសេដ្ឋកិច្ច និងសង្គម ហើយការងាររបស់បុគ្គលិកសង្គមតែងតែត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាទាំងនេះ។

កម្លាំងសេវាសង្គមនៅកម្ពុជា បានទទួលការបណ្តុះបណ្តាលការគ្រប់គ្រងករណីដើម្បីគាំទ្រដល់អាទិភាពនៃការធ្វើសមាហរណកម្មជនរងគ្រោះ។ កម្លាំងសេវាសង្គមបាននាំមុខក្នុងការអនុវត្តគោលនយោបាយជាតិស្តីពី ប្រព័ន្ធកិច្ចការពារកុមារ និងគោលនយោបាយ ស្តីពី ការថែទាំជំនួសចំពោះកុមារ និងគាំទ្រដល់ដំណើរការធ្វើសមាហរណកម្ម តាមរយៈភាពជាដៃគូរវាងបុគ្គលិកសង្គមរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងបុគ្គលិកសង្គមរបស់អង្គការមិនមែនរដ្ឋាភិបាល គិតត្រឹមចុងខែសីហាឆ្នាំ ២០២១ បុគ្គលិកសង្គមទាំង ២៩ នាក់[19] បានគាំទ្រដល់ការធ្វើសមាហរណកម្មកុមារចំនួន ៧៨៩នាក់ នៅទូទាំងប្រទេស និងកំពុងតែបន្តគាំទ្រដល់កុមារនិងគ្រួសារបន្ថែមទៀត។ ក្រៅពីការគ្រប់គ្រងករណី និងការបង្រួប

[17] Harachi, T. W, 2014.
[18] UNICEF, 2017.
[19] The number of social workers working under the joint-partnership has always been 30, but currently there is one vacancy for in DoSVY Phnom Penh so only 29 social workers were in position and were interviewed.

បង្រួមគ្រួសារ កម្លាំងសេវាសង្គមក៏បានធ្វើការផ្លាស់ប្តូរឥរិយាបទវិជ្ជមានចំពោះអតិថិជន និងក្រុមគ្រួសារដែលពួកគេធ្វើការជាមួយផងដែរ។ ឯកសារជាច្រើនបានចង្អុលបង្ហាញពីផលវិជ្ជមានគួរឱ្យកត់សម្គាល់សម្រាប់ការវិនិយោគលើកម្លាំងសេវាសង្គម។ ផលចំណេញខ្ពស់មួយផ្នែកឆ្លុះបញ្ចាំងពីការពិតដែលថាកម្មវិធីទាំងនេះមិនត្រឹមតែផ្តល់នូវផលវិជ្ជមានក្នុងរយៈពេលខ្លីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផលប៉ះពាល់រយៈពេលវែងផងដែរដែលមិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់បុគ្គលម្នាក់ៗប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងជួយដល់សង្គម និងសេដ្ឋកិច្ចផងដែរ។

១.៤.៣.ការកង្វះកម្លាំងសេវាសង្គមនៅកម្ពុជា

ចាប់តាំងពីការបង្កើតកម្មវិធីការងារសង្គមនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិសង្គមកិច្ច វិទ្យាស្ថានសន្តប៉ូល ឥឡូវនេះមានបុគ្គលិកសង្គមកាន់តែច្រើនជាមួយនឹងការបណ្តុះបណ្តាលកម្រិតខ្ពស់ បើប្រៀបធៀបនឹងអតិកាល ហើយមាននិស្សិតចុះឈ្មោះចូលរៀនប្រមាណ ២០០នាក់ក្នុងមួយឆ្នាំៗ។ ទោះយ៉ាងណាប្រទេសកម្ពុជានៅតែកង្វះខាតកម្លាំងសេវាសង្គមទូទាំងវិស័យ។ នៅឆ្នាំ២០១៥ សកលវិទ្យាល័យភូមិន្ទភ្នំពេញ និងកម្មវិធីអប់រំផ្សេងទៀតបានចាប់ផ្តើមធ្វើឱ្យសញ្ញាបត្រផ្នែកសង្គមកិច្ចវិទ្យាមានអត្ថប្រយោជន៍កាន់តែខ្លាំងឡើងសម្រាប់មនុស្សគ្រប់គ្នា[20] ដូច្នេះកម្លាំងសេវាសង្គមដែលមានសមត្ថភាព និងការបណ្តុះបណ្តាលកាន់តែច្រើននឹងមាននៅក្នុងទីផ្សារការងារ។ ទោះបីបញ្ហានេះអាចជួយបង្កើនការបណ្តុះបណ្តាលដល់និស្សិតលើកិច្ចការសង្គមដើម្បីពង្រីកសក្តានុពលរបស់ពួកគេឱ្យបានច្រើនបំផុត និងដោះស្រាយកង្វះកម្លាំងសេវាសង្គម និងបង្កើតប្រព័ន្ធជ្រើសរើសមន្ត្រីរាជការសម្រាប់កម្លាំងសេវាសង្គម។

សមាមាត្ររវាងកម្លាំងសេវាសង្គមនឹងប្រជាជនគឺជាកស្តុតាងដ៏ត្រឹមត្រូវមួយ ដែលបង្ហាញថាមានតម្រូវការកម្លាំងសេវាសង្គមដែលមានជំនាញវិជ្ជាជីវៈច្រើននៅក្នុងប្រទេសកម្ពុជា។ គម្លាតសមាមាត្រនៃចំនួនកម្លាំងសេវាសង្គមនឹងប្រជាជននៅកម្ពុជាចាំបាច់ត្រូវកាត់បន្ថយដើម្បីសម្រេចបាននូវទិដ្ឋភាពនៃការអភិវឌ្ឍវិជ្ជាជីវៈសង្គមកិច្ច។ នៅក្នុងផ្នែកនេះសមាមាត្ររវាងបុគ្គលិកនឹងប្រជាជននៃបណ្តាប្រទេសដែលបានជ្រើសរើសនៅក្នុងទ្វីបអាស៊ី និងក្រៅទ្វីបអាស៊ីត្រូវបានចុះបញ្ជីជាមួយនឹងក្តីសង្ឃឹមនៃការទទួលបានសមាមាត្រកម្លាំងសេវាសង្គមនឹងប្រជាជនដ៏ល្អបំផុតនៅក្នុងបរិបទកម្ពុជា។[21] យោងតាមការពិនិត្យរួមគ្នាដែលធ្វើឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការយូនីសេហ្វបានបង្ហាញថា បច្ចុប្បន្ននៅកម្ពុជាជាមធ្យមអត្រាកម្លាំងសេវាសង្គមនឹងប្រជាជនគឺបុគ្គលិកសង្គមកិច្ច ១/១២ ៥០០នាក់ ហើយភាគច្រើនមិនទទួលបានការបណ្តុះបណ្តាលជាផ្លូវការក្នុងនាមជាអ្នកសង្គមកិច្ចទេ។ អត្រាបុគ្គលិកសង្គមនេះមិនទាន់ឆ្លើយតបទៅនឹងសមាមាត្ររវាងបុគ្គលិកសង្គមនិងប្រជាជននៅឡើយទេ ដែលកម្ពុជាគួរឱ្យតែមានបុគ្គលិកសង្គម១នាក់ ធៀបនឹងប្រជាជន ៣៥០០នាក់(១/៣៥០០)អាចប្រហាក់ប្រហែលជាមួយប្រទេសក្នុងសមាគមអាស៊ាន និងប្រទេសមួយចំនួនក្នុងពិភពលោក។

---

[20] Shaun Turton, "Program eyes NGO aspirants", https://www.phnompenhpost.com/national/program-eyes-ngo-aspirants, 2014.

[21]សហរដ្ឋអាមេរិក ១/៥០៣នាក់(George Washington University Health Workforce Institute, "Profile of the Social Work Workforce", 2017) ចិន ១/៩៧៦នាក់ (The University of Chicago, "A Bridge to China", 2015) សិង្ហបូរី ១/៣៤៤៨នាក់ (Social Work Accreditation and Advisory Board, "Annual Report 2016", 2016 វៀតណាម ១/១៤៨៤នាក់(Tracy W. Harachi, "Review social work practice: An Emphasis on Public Social and Child Welfare",2014)។

១.៥. ការកំណត់ប្រភេទកម្លាំងសេវាសង្គម

បច្ចុប្បន្នមិនទាន់មានស្តង់ដារនិយមន័យ និងគ្មានការផ្តល់ចំណាត់ថ្នាក់សម្រាប់មន្ត្រីរាជការដោយក្រសួងមុខងារសាធារណៈចំពោះកម្លាំងសេវាសង្គមនៅកម្ពុជាឡើយ។ ចំពោះការកំណត់ស្តង់ដារនិយមន័យ និងចំណាត់ថ្នាក់កម្លាំងសេវាសង្គមមានសារៈសំខាន់ណាស់ ដើម្បីប្រើប្រាស់ស្តង់ដារនិយមន័យ និងចំណាត់កម្លាំងសេវាសង្គមដែលត្រូវ ប្រើប្រាស់នៅក្នុងផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសង្គមមានដូចខាងក្រោម៖

- **អ្នកអាជីពសង្គមកិច្ច៖** ជាអ្នកដែលមានជំនាញវិជ្ជាជីវៈក្នុងការផ្តល់សេវាសង្គមទាំងមូល។ អ្នកអាជីពសង្គមកិច្ចត្រូវមានសញ្ញាបត្រសង្គមកិច្ចដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងមានអាជ្ញាប័ណ្ណទទួលស្គាល់ដោយស្ថាប័នជំនាញសាធារណៈផ្នែកសង្គមកិច្ច។
- **អ្នកអាជីពសង្គមកិច្ចរង៖** ជាអ្នកដែលធ្វើការអមជាមួយ ឬ ជួយការងាររបស់អ្នកអាជីពសង្គមកិច្ច។ អ្នកអាជីពសង្គមកិច្ចរង ត្រូវបានបណ្តុះបណ្តាលឱ្យបំពេញមុខងារជាក់លាក់មួយចំនួន ប៉ុន្តែមិនតម្រូវឱ្យមានការបញ្ជាក់ ឬផ្តល់អាជ្ញាប័ណ្ណទទួលស្គាល់ដោយស្ថាប័នជំនាញសាធារណៈផ្នែកសង្គមកិច្ចដូចអ្នកអាជីពសង្គមកិច្ចនោះទេ តែក្នុងមុខងារខ្លះតម្រូវឱ្យមានសញ្ញាបត្រឯកទេស។
- **អ្នកសង្គមកិច្ចបឋម៖** ជាអ្នកដែលកំពុងធ្វើការក្នុងផ្នែកសង្គមកិច្ច ឬ ជាអ្នកស្ម័គ្រចិត្ត ដែលភាគច្រើនធ្វើការនៅតាមសហគមន៍ ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសពីអ្នកអាជីពសង្គមកិច្ច ឬអ្នកអាជីពសង្គមកិច្ចរង។ អ្នកសង្គមកិច្ចបឋម បម្រើដល់តម្រូវការរបស់អតិថិជន រួមទាំងកុមារ និងគ្រួសារ ជាពិសេសនៅក្នុងកន្លែងដែលប្រព័ន្ធសុខុមាលភាពសង្គមមិនទាន់បានបង្កើត ឬមានកម្រិតនៅឡើយ។
- **អ្នកសង្គមកិច្ចសម្ព័ន្ធ៖** គឺជាអ្នកដែលផ្តល់សេវាសង្គម ប៉ុន្តែត្រូវបានផ្សារភ្ជាប់ជាមួយនឹងវិស័យផ្សេងទៀតដូចជាការអប់រំ សុខភាព ឬយុត្តិធម៌។ ឧទាហរណ៍រួមមាន គិលានុបដ្ឋាយិកា មេធាវី វេជ្ជបណ្ឌិត និងគ្រូបង្រៀននិងអ្នកផ្សេងទៀត។ បុគ្គលិកសម្ព័ន្ធសង្គមកិច្ចអនុវត្តមុខងារជាច្រើនដែលធ្វើឱ្យប្រសើរឡើង ការគាំទ្រ ឬសម្របសម្រួលមុខងារដែលអនុវត្តដោយកម្លាំងសេវាសង្គមផ្សេងទៀត។

ការកំណត់ប្រភេទ តួនាទី និងការកិច្ចកម្លាំងសេវាសង្គមខាងលើគឺផ្អែកលើឯកសារចេញផ្សាយជាផ្លូវការដូចជា៖ ការពិនិត្យឡើងវិញលើការអនុវត្តការងារសង្គមកិច្ចឆ្នាំ២០១៤ គោលការណ៍ណែនាំ ស្តីពី «សមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ២០១៩» សេចក្តីណែនាំ ស្តីពី ការពង្រឹងកម្លាំងសេវាសង្គមដើម្បីការពារកុមារឆ្នាំ២០១៩ សេចក្តីប្លែងការណ៍អាស៊ាន ស្តីពីការលើកកម្ពស់ការងារសង្គមឆ្នាំ២០១៩។

តារាងទី១៖ មន្ត្រីរាជការ និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល (NGOs) ចាត់ថ្នាក់អាជីព

ល.រ	មន្ត្រីរាជការ និងបុគ្គលិក NGOs	ចំណាត់ថ្នាក់អាជីព
១	មន្ត្រីរាជការក្រសួង ស្ថាប័ន និងបុគ្គលិក NGOs ដែលមានសញ្ញាបត្រឧត្តមសិក្សាផ្នែកសង្គមកិច្ច	អ្នកអាជីពសង្គមកិច្ច
២	មន្ត្រីរាជការក្រសួង ស្ថាប័ន មន្ត្រីការិ.សង្គមកិច្ចនិងសុខុមាលភាពសង្គម ក្រុង ស្រុក ខ័ណ្ឌ និងបុគ្គលិក NGOs មិនមានសញ្ញាបត្រផ្នែកសង្គមកិច្ច ប៉ុន្តែមានជំនាញការងារសង្គមកិច្ច	អ្នកអាជីពសង្គមកិច្ចរង

៣	មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិដែលកំពុងធ្វើការងារសង្គមកិច្ចដូចជា គ.ក.ន.ក និងអ្នកស្នគ្រចិត្ត	អ្នកសង្គមកិច្ចបឋម
៤	មន្ត្រីរាជការ និងបុគ្គលិក NGOs ដែលកំពុងធ្វើការពាក់ព័ន្ធនឹងការងារសង្គមកិច្ច ដូចជាវិស័យអប់រំ សុខាភិបាល យុត្តិធម៌ ។ល។	អ្នកសង្គមកិច្ចសម្ព័ន្ធ

១.៦. តួនាទីនិងមុខងាររបស់កម្លាំងសេវាសង្គម

ការងារសង្គមកិច្ច គឺជាផ្នែកសំខាន់មួយនៃប្រព័ន្ធសុខមាលភាពសង្គម និងយុត្តិធម៌ សម្រាប់មនុស្សពេញវ័យ គ្រួសារ និងកុមារ ជាពិសេសការអនុវត្តចំពោះកុមារ និងគ្រួសារ កម្លាំងសេវាសង្គមធ្វើការនៅក្នុងប្រព័ន្ធកិច្ចការពារកុមារ យុត្តិធម៌សម្រាប់កុមារ សុខភាពផ្លូវចិត្ត និងការផ្លាស់ប្តូរបទដ្ឋានសង្គម។ តារាងទី២ បង្ហាញជាលក្ខណៈអន្តរជាតិនៃកម្លាំងសេវាសង្គមធ្វើអន្តរាគមន៍នៅកម្រិតផ្សេងៗគ្នា ពីបុគ្គលទៅបុគ្គល ក្រុមគ្រួសារ ក្រុម សហគមន៍ និងកម្រិតសង្គម។ ទោះបីជាការអនុវត្តការងារសង្គមកិច្ចមួយចំនួនអាចត្រួតលើគ្នាជាមួយនឹងវិជ្ជាជីវៈដទៃទៀតក៏ដោយ លក្ខណៈពិសេសនៃការងារសង្គមគឺថាទាំងអស់នេះត្រូវបានបញ្ចូលគ្នា ហើយការងារសង្គមនាំឱ្យពួកគេមានវិធីសាស្ត្រប្លែកមួយដែលផ្តោតលើបុគ្គលម្នាក់ៗនៅក្នុងបរិបទសង្គមរបស់ពួកគេ និងអាចគាំទ្រដល់ប្រជាជនតាមរយៈការផ្តល់ប្រឹក្សាយោបល់ ការគ្រប់គ្រងករណី ការរៀបចំសហគមន៍ និងការតស៊ូមតិដែលរួមចំណែកដល់ការគាំពារសង្គម។

១.៦.១.តួនាទី និងមុខងារកម្លាំងសេវាសង្គមកម្រិតមីក្រូ (Micro)

នៅកម្រិតមីក្រូ កម្លាំងសេវាសង្គមអនុវត្តផ្តល់សេវាដោយផ្ទាល់ដល់អតិថិជន។ ការងារនេះរួមបញ្ចូលទាំងការងារបង្ការដូចជាការផ្តល់សេវាគាំទ្រផ្នែកចិត្តសាស្ត្រ និងសម្ភារដូចជា សម្លៀកបំពាក់ ស្បៀងអាហារ និងកញ្ចប់អនាម័យ ការកំណត់ករណីនៃការរំលោភបំពានលើកុមារ ការគ្រប់គ្រងករណី ការប្រឹក្សាយោបល់ ការបញ្ជូន និងការសម្របសម្រួលនៃសេវាសំខាន់ៗមួយចំនួនក្នុងការតាមដានករណីអំពើហឹង្សា ការរំលោភបំពាន ការធ្វេសប្រហែស និងការកេងប្រវ័ញ្ច។ អ្នកស្នគ្រចិត្តកម្រិតសហគមន៍ និងអ្នកធ្វើការផ្នែកសង្គមកិច្ចតែងតែធ្វើការនៅកម្រិតមីក្រូ។

១.៦.២.តួនាទី និងមុខងារកម្លាំងសេវាសង្គមកម្រិតកណ្តាល (Mezzo)

នៅកម្រិតកណ្តាល ដៃគូសង្គមកិច្ចជាមួយក្រុម និងអង្គការកម្រិតសហគមន៍ដើម្បីប្រមូលធនធាន និងតស៊ូមតិដើម្បីការផ្លាស់ប្តូរវប្បធម៌ ឬស្ថាប័ន។ ការងារភាគច្រើនជាមួយបទដ្ឋានវប្បធម៌ដូចជាអន្តរាគមន៍ដើម្បីដោះស្រាយអំពើហឹង្សាប្រឆាំងនឹងយែនឌ័រកើតឡើងនៅកម្រិតនេះ។ កម្លាំងសេវាសង្គមដែលធ្វើការនៅកម្រិតកណ្តាលត្រូវតែបំពាក់ដោយជំនាញអន្តរបុគ្គល និងភាពចាប់អារម្មណ៍ខាងវប្បធម៌ ដើម្បីធ្វើការជាមួយប្រជាជន និងការប្រែប្រួលវប្បធម៌ដើម្បីធ្វើការជាមួយមនុស្សផ្សេងគ្នា។

១.៦.៣.តួនាទី និងមុខងារកម្លាំងសេវាសង្គមកម្រិតមាក្រូ (Macro)

នៅកម្រិតទូលំទូលាយនៃការអនុវត្ត កម្លាំងសេវាសង្គមនៅកម្រិតម៉ាក្រូមិនធ្វើការដោយផ្ទាល់ជាមួយនឹងអតិថិជនទេ។ ទោះយ៉ាងណាក៏ដោយកម្លាំងសេវាសង្គមអាចដោះស្រាយបញ្ហាធំៗដែលជះឥទ្ធិពលដល់សហគមន៍ដោយការប្រមូលផ្តុំសហគមន៍ទាំងមូល ការតស៊ូមតិសម្រាប់គោលនយោបាយ ការបង្កើត

កម្មវិធី អន្តរាគមន៍ និងចូលរួមក្នុងការស្រាវជ្រាវ។ អ្នកគ្រប់គ្រងការងារសង្គមកិច្ចដែលត្រួតពិនិត្យទីភ្នាក់ងារសេវាសង្គមអាចជាអ្នកធ្វើការផ្នែកសង្គមកិច្ចកម្រិតម៉ាក្រូ។

តារាងទី២ៈ តួនាទី និងមុខងាររបស់កម្លាំងសេវាសង្គម[22]

កម្រិត	ការផ្តោតសំខាន់នៃការងារ	តួនាទី និងមុខងារ	តួនាទីទូទៅ
កម្រិតមីក្រូ (Micro)	- បុគ្គល និងក្រុមគ្រួសារដែលងាយរងគ្រោះ ឬមានហានិភ័យឬធ្លាប់មានបញ្ហាទាក់ទងនឹងអំពើហិង្សាលើកុមារ	- កំណត់អត្តសញ្ញាណកុមារនិងក្រុមគ្រួសារដែលមានហានិភ័យ និងយោងទៅប្រព័ន្ធផ្លូវការ - ធ្វើការជាមួយយន្តការការពារកុមារសហគមន៍ - ភ្ជាប់ទៅសេវាកម្ម និងតាមដានវឌ្ឍនភាព - ការគ្រប់គ្រងករណី ការចុះសួរសុខទុក្ខនៅផ្ទះ សេវាកម្មផ្ទាល់ (ការប្រឹក្សា ការគាំទ្រចិត្តសាស្ត្រ ការគាំទ្រផ្នែកសេដ្ឋកិច្ច។ល។)	- បុគ្គលិកថែទាំកុមារ និងយុវជន - បុគ្គលិកការពារកុមារសហគមន៍ - អ្នកគ្រប់គ្រងករណី - មន្ត្រីការពារកុមារ - មន្ត្រីសិទ្ធិកុមារ - បុគ្គលិកសុខាភិបាលសហគមន៍ - បុគ្គលិកសង្គម - អ្នកព្យាបាលរោគ
កម្រិតកណ្តាល (Mezzo)	- អតិថិជនគោលដៅ/ក្រុមអ្នកទទួលផល - យន្តការការពារកុមារសហគមន៍ - ក្រុមសហគមន៍ផ្តោតលើបញ្ហាសង្គមផ្សេងៗ ដូចជាការអនុវត្ត ប្រកបដោយគ្រោះថ្នាក់ អាហារូបត្ថម្ភកុមារ - ការស្នាក់នៅប្រកបដោយសុវត្ថិភាព	- ផ្តល់ព័ត៌មាន និង/ឬធនធានទៅក្រុមដែលមានហានិភ័យ - សម្របសម្រួលដំណើរការជួយខ្លួនឯង - ចាប់ដៃគូជាមួយសហគមន៍ដើម្បីធានាបាននូវមធ្យោបាយបញ្ជូន - សម្របសម្រួល និងបម្រើការលើគណៈកម្មាធិការការពារកុមារសហគមន៍ - ទំនាក់ទំនងជាមួយមេដឹកនាំប្រពៃណី	- សមាជិកគណៈកម្មាធិការការពារកុមារសហគមន៍ - អ្នកតស៊ូមតិកុមារ - មន្ត្រីអភិវឌ្ឍសហគមន៍/អ្នកស្ម័គ្រចិត្ត
កម្រិតមាក្រូ (Macro)	- សហគមន៍ទាំងមូល - ការគ្រប់គ្រងទីភ្នាក់ងារ/កម្មវិធី - ការបណ្តុះបណ្តាលនិងការណែនាំ	- ការលើកកម្ពស់ការយល់ដឹង - ការកៀរគរសហគមន៍រួមទាំងឪពុកម្តាយកុមារ និងមនុស្សវ័យជំទង់ - ដឹកនាំ/គ្រប់គ្រងភ្នាក់ងារ និងកម្មវិធីសេវាកម្មសង្គមដោយផ្ទាល់	- អ្នករៀបចំសហគមន៍ - អ្នកតស៊ូមតិគោលនយោបាយ - មន្ត្រីនីតិវិធី - អ្នកគ្រប់គ្រងទីភ្នាក់ងារ - អ្នកគ្រប់គ្រងកម្មវិធី

[22] Business Case of Social Work for Improved Access to Social Services in Cambodia 2019

កម្រិត	ការផ្តោតសំខាន់នៃការងារ	តួនាទី និងមុខងារ	តួនាទីទូទៅ
	- ការផ្តល់កិច្ចគាំទ្រ (ដោយភ្នាក់ងារ ឬការអនុវត្តផ្ទាល់) - ប្រព័ន្ធទិន្នន័យ - ពិនិត្យឡើងវិញការគ្រប់គ្រង - ធ្វើអន្តរកម្មជាមួយប្រព័ន្ធផ្សព្វផ្សាយ - គ្រប់គ្រងចក្ខុវិស័យនិងការផ្លាស់ប្តូរយុទ្ធសាស្ត្រ - ចូលរួមក្នុងដំណើរការតាក់តែងគោលនយោបាយ ឬច្បាប់ - ការវាយតំលៃកម្មវិធី - ការសម្របសម្រួលថ្នាក់ជាតិ	- ដឹកនាំការបណ្តុះបណ្តាលនៅតាមសហគមន៍ ភ្នាក់ងារសេវាកម្ម ឬនៅក្នុងស្ថាប័នអប់រំ - ផ្តល់ការត្រួតពិនិត្យទីភ្នាក់ងារ ឬជាអ្នកត្រួតពិនិត្យដល់និស្សិត - រចនា/គ្រប់គ្រងទិន្នន័យ - ត្រួតពិនិត្យនិងវាយតម្លៃ	- អ្នកដឹកនាំ - អ្នកបណ្តុះបណ្តាល/គ្រូ - មន្ត្រីត្រួតពិនិត្យ និងវាយតម្លៃ/អ្នកស្រាវជ្រាវ - អ្នកគ្រប់គ្រង - អ្នកគ្រប់គ្រងកម្លាំងសេវាសង្គមថ្នាក់ជាតិ - អ្នកការពារការបែងចែកថវិកា

១.៧.ប្រព័ន្ធអតិបាលកិច្ចកម្លាំងសេវាសង្គម

ការផ្តល់អាជ្ញាប័ណ្ណ និងការទទួលស្គាល់អ្នកវិជ្ជាជីវៈសង្គមកិច្ច គឺជាយន្តការដ៏ចម្បង និងមានសារៈសំខាន់សម្រាប់វិជ្ជាជីវៈនីយកម្មសង្គមកិច្ច ដើម្បីធានាថា និស្សិតដែលបានបញ្ចប់ការសិក្សាសង្គមកិច្ចវិទ្យា និងអ្នកផ្តល់សេវាសង្គមកិច្ច និងជំនួយសង្គមទាំងក្នុងស្ថាប័នរដ្ឋ អង្គការដៃគូ និងវិស័យឯកជន មានគុណវុធ្ឍិគ្រប់គ្រាន់ក្នុងការអន្តរាគមន៍ ស្របតាមប្រព័ន្ធវាយតម្លៃ និងការបណ្តុះបណ្តាលត្រឹមត្រូវតាមនិយាមការជាតិនិងអន្តរជាតិ។ ផ្អែកតាមការអនុវត្តនៅសហរដ្ឋអាមេរិចបានបង្ហាញថា ការទទួលខុសត្រូវនៃក្រុមប្រឹក្សាសហរដ្ឋអាមេរិកស្តីពីការអប់រំសង្គមកិច្ចវិទ្យាដែល"បង្កើតបទដ្ឋានសម្រាប់ការទទួលស្គាល់ ដែលកំណត់អំពីការរៀបចំសមត្ថភាព និងការធានាថា កម្មវិធីអប់រំសង្គមកិច្ចវិទ្យាស្របទៅតាមបទដ្ឋានទាំងនេះ ការិយាល័យផ្តល់ការទទួលស្គាល់ចំពោះសង្គមកិច្ចវិទ្យា ត្រួតពិនិត្យមើលដំណើរការនៃការផ្តល់ការទទួលស្គាល់ដែលមានច្រើនដំហាន ដែលពាក់ព័ន្ធនឹងស្វ័យសិក្សាអំពីកម្មវិធីអប់រំនេះ ការចុះពិនិត្យដល់កន្លែង និងការពិនិត្យរបស់គណៈកម្មាការផ្តល់ការទទួលស្គាល់"[23]

[23] Council on Social Work Education, "About CSWE Accreditation", 2018.

ដើម្បីទទួលបានអាជ្ញាប័ណ្ណ អ្នកប្រកបអាជីពវិជ្ជាជីវៈសង្គមកិច្ចដែលជាកម្លាំងសេវាសង្គម ត្រូវឆ្លងកាត់នូវការប្រលង និងនីតិវិធីកំណត់ពីគុណវុធ្ឍិដែលរៀបចំដោយស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលទទួលខុសត្រូវក្នុងការផ្តល់អាជ្ញាប័ណ្ណ។[24] នៅក្នុងដំណាក់កាលក្រោយៗទៀតនៃវិជ្ជាជីវៈនេះ អាចមានការប្រលងដើម្បីទទួលបានអាជ្ញាប័ណ្ណប្រភេទមួយផ្សេងទៀតសម្រាប់អ្នកអនុវត្តផ្នែកគ្លីនិកកម្រិតខ្ពស់ ដែលមានសញ្ញាបត្រអនុបណ្ឌិត និងយ៉ាងហោចណាស់មានបទពិសោធន៍រយៈពេលបីទៅបួនឆ្នាំ ក្នុងការអនុវត្តដោយផ្ទាល់ដូចជាបច្ចេកទេស និងគំរូនៃការពិគ្រោះយោបល់ផ្សេងៗគ្នា។ ការប្រលងដើម្បីទទួលបានអាជ្ញាប័ណ្ណគួរតែឆ្លុះបញ្ចាំងពីបទដ្ឋានដែលត្រូវបានកំណត់សម្រាប់ការអនុវត្តដោយផ្ទាល់ក្នុងកម្រិតខ្ពស់។[25]

ផ្អែកតាមស្រាវជ្រាវរបស់អ្នកជំនាញបង្ហាញថា ការប្រលងរបស់ប្រទេស ដែលប្រើប្រាស់គោលការណ៍ណែនាំកាន់តែតឹងរឹងសម្រាប់ការផ្តល់អាជ្ញាប័ណ្ណអ្នកសង្គមកិច្ចវិទ្យាមាននៅក្នុងប្រទេសណូវ៉ែហ្សេឡង់។ តាមរយៈការផ្លាស់ប្តូរច្បាប់នៅឆ្នាំ២០១៩ អ្នកសង្គមកិច្ចវិទ្យាទាំងអស់ដែលកំពុងអនុវត្តវិជ្ជាជីវៈនេះនៅពេលនេះត្រូវចុះបញ្ជីជាមួយក្រុមប្រឹក្សាកិបាលចុះបញ្ជីអ្នកសង្គមកិច្ចវិទ្យាជាតិនៅត្រឹមឆ្នាំ២០២១ ដោយសារការចុះបញ្ជីដោយស្ម័គ្រចិត្តលែងបំពេញកម្រិតនៃលក្ខខណ្ឌវិជ្ជាជីវៈនៅក្នុងវិស័យនេះទៀតហើយ។[26] ផ្នែកមួយនៃអត្ថប្រយោជន៍ដែលរដ្ឋាភិបាលណូវ៉ែលហ្សេឡង់បានគូសបញ្ជាក់ចំពោះការផ្លាស់ប្តូរនេះគឺថាការផ្លាស់ប្តូរនេះនឹងអនុញ្ញាតឱ្យអ្នកសង្គមកិច្ចវិទ្យាពង្រឹងវិជ្ជាជីវៈរបស់ខ្លួន ជួយដល់ការរៀបចំផែនការកម្លាំងការងារនិងអនុញ្ញាតឱ្យមានអន្តរាគមន៍ផ្នែកប្រតិបត្តិការកាន់តែល្អប្រសើរ។[27]

ការរៀបចំស្ថាប័ននីយកម្មវិជ្ជាជីវៈសង្គមកិច្ច និងវិជ្ជាជីវៈនីយកម្មកម្លាំងសេវាសង្គមកិច្ច គឺជាយន្តការចម្បងក្នុងការទទួលស្គាល់ជាផ្លូវការនូវវិជ្ជាជីវៈសង្គមកិច្ច ដើម្បីធានាបាននូវការលើកកម្ពស់ ការកសាង និងអភិវឌ្ឍសមត្ថភាពកម្លាំងសេវាសង្គមដែលជាតួអង្គប្រតិបត្តិការផ្ទាល់ក្នុងការផ្តល់ទាំងសេវាសង្គម និងជំនួយសង្គមប្រកដដោយប្រសិទ្ធភាពស្របតាមការវិវត្តន៍របស់កម្ពុជានាបច្ចុប្បន្ននៅលើឆាកជាតិ និងអន្តរជាតិ។ ដំណើរការនៃការរៀបចំនេះមានដូចខាងក្រោម៖

១.៧.១.ស្ថាប័ននីយកម្មវិជ្ជាជីវៈសង្គមកិច្ច

- រៀបចំបង្កើតនូវឯកសារគតិយុត្តពាក់ព័ន្ធនានា
- រៀបចំដាក់បញ្ចូលនូវមុខងារសង្គមកិច្ចទៅក្នុងប្រព័ន្ធការងាររបស់ស្ថាប័ន
- រៀបចំផែនការ និងតម្រូវការការបណ្តុះបណ្តាល
- រៀបចំពង្រឹង សមាគមវិជ្ជាជីវៈ
- រៀបចំបង្កើតក្រមសីលធម៌វិជ្ជាជីវៈ។[28]

---

[24] MoSVY "Social Work Standards for Generalist Practice",
[25] Karen Rotabi and Jini Roby, "Social Work Standards for Advanced Direct Practice", 2018.
[26] Social Workers Registration Board, "Legislation",2019.
[27] New Zealand Government, "Social work sector – improving professionalism through managing mandatory registration", 2019.
[28] Wilensky, L.H. (1964). The professionalization of everyone? *American Journal of Sociology, 70*(2), 137-158

១.៧.២.វិជ្ជាជីវៈនីយកម្មកម្លាំងសេវាសង្គមកិច្ច

- ធ្វើការសិក្សាពីតម្រូវការ និងការផ្លាស់ប្តូរបរិបទសង្គមផ្តោតលើកម្លាំងសេវាសង្គម
- រៀបចំឯកសារគតិយុត្តពាក់ព័ន្ធនានា ស្វែងរកការគាំទ្រផ្នែកគោលនយោបាយសម្រាប់វិជ្ជាជីវៈ
- រៀបចំយន្តការក្នុងការបណ្តុះបណ្តាល
- បង្កើតក្រមសីលធម៌វិជ្ជាជីវៈ និងបទដ្ឋាននានា
- បង្កើតយន្តការស្វ័យគ្រប់គ្រងអំពី ការចុះឈ្មោះ និងការផ្តល់អាជ្ញាប័ណ្ណ[29]
- ពង្រឹងសមាគមវិជ្ជាជីវៈសង្គមកិច្ច

ទោះបីជាការរៀបចំនៅក្នុងប្រទេសនីមួយៗអាចមានលក្ខណៈខុសៗគ្នាក្តី ប៉ុន្តែសម្រាប់ប្រទេសកម្ពុជា នាពេលបច្ចុប្បន្នគឺស្ថិតនៅក្នុងដំណាក់កាលទី៥ នៃស្ថាប័ននីយកម្មវិជ្ជាជីវៈសង្គមកិច្ច។ សមាគមអ្នកវិជ្ជាជីវៈសង្គមកិច្ចកម្ពុជា(APSWC)ត្រូវបានបង្កើតរួចហើយនៅក្នុងឆ្នាំ២០១៤។ សមាគមនេះ ក៏ព្យាយាមបង្កើតការត្រួតពិនិត្យគុណវុធិ ក្រមសីលធម៌វិជ្ជាជីវៈ និងការទទួលស្គាល់ចំពោះវិជ្ជាជីវៈនេះ។ ទោះបីជាយ៉ាងណា ដើម្បីធានាបាននូវការគាំទ្រ ការទទួលស្គាល់ និងការបង្កើននូវចំនួននៃកម្លាំងសេវាសង្គម តម្រូវឱ្យមាននូវការរៀបចំយន្តការនៃការរៀបចំ និងទទួលស្គាល់ច្បាស់លាស់ដូចជា ច្បាប់ គោលនយោបាយ និងបទដ្ឋាននៃការអនុវត្តផ្សេងៗសម្រាប់វិជ្ជាជីវៈនេះ។

ផ្អែកតាមបរិបទខាងលើ និងឯកសារទម្លីករណ៍ ស្តីពី «**ការវិនិយោគលើកម្លាំងសេវាសង្គមនៅកម្ពុជា**» បានដើរតួនាទីជាឧបករណ៍ដ៏សំខាន់មួយ ដើម្បីពង្រឹង និងគាំទ្រសម្រាប់វិជ្ជាជីវៈសង្គមកិច្ចនៅក្នុងប្រទេសកម្ពុជា។ ដើម្បីធានានូវការផ្តល់សេវាបែបបរិយាប័ន្នយេនឌ័រ និងការរៀបចំយន្តការអភិបាលកិច្ចកម្លាំងសេវាសង្គមចាំបាច់ត្រូវពិចារណាលើសមតុល្យផ្នែកយេនឌ័រ នៅក្នុងការជ្រើសរើសអ្នកវិជ្ជាជីវៈសង្គមកិច្ច។

១.៨. ទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រជាមួយនឹងឯកសារពាក់ព័ន្ធ

ផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ ២០២២-២០៣១**» ដែលមានសង្គតិភាពជាមួយនឹងផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម «ផ្តោតលើកិច្ចការពារកុមារ» ឆ្នាំ ២០២១-២០២៥ ផែនការយុទ្ធសាស្ត្រវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិឆ្នាំ ២០១៩-២០២៣ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ២០៣០ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ គោលនយោបាយជាតិ ស្តីពី «មនុស្សវ័យចាស់ឆ្នាំ ២០១៧-២០៣០» គោលនយោបាយជាតិ ស្តីពី «ប្រព័ន្ធកិច្ចការពារកុមារឆ្នាំ ២០១៩-២០២៩ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦ និងក្របខណ្ឌគុណវុធិជាតិកម្ពុជាឆ្នាំ២០១៤ ឯកសារទម្លីករណ៍ស្តីពីការវិនិយោគលើកម្លាំងសេវាសង្គមនៅកម្ពុជា និងឯកផ្សេងទៀត។

[29] Jini Roby & Karen Smith Rotabi, 2017

ផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជា ២០២២-២០៣១**» គឺជាផែនទីតម្រង់ផ្លូវឱ្យគ្រឹះស្ថានអប់រំ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស ដៃគូអភិវឌ្ឍ និងអង្គភាពពាក់ព័ន្ធចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសង្គម ឆ្នាំ២០២២-២០៣១ ឱ្យសម្រេចបាននូវគោលដៅយុទ្ធសាស្ត្រ ចង្អោមសកម្មភាព និងចំណុចដៅនៃសូចនាករដែលបានកំណត់ឱ្យទទួលបានជោគជ័យ។

១.៩. ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសង្គម

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការក្លែនអន្តរជាតិ និងអង្គការយូនីសេហ្វបានជ្រើសរើសទីប្រឹក្សាបច្ចេកទេសដើម្បីរៀបចំផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសង្គម ឆ្នាំ ២០២២-២០៣១ មានរយៈពេល៥៦ថ្ងៃធ្វើការ ដែលបានចាប់ផ្តើមពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២១ ដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២១ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រនេះ។[30] ជំហានដើម្បីរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ ស្តីពី កម្លាំងសេវាសង្គមនៅកម្ពុជាដូចខាងក្រោម៖

- រៀបចំផែនការអភិវឌ្ឍផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ២០២២-២០៣១។
- ពិនិត្យឡើងវិញនូវឯកសារគោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធជាតិនិងអន្តរជាតិនានារួមទាំងផែនការ ឬកម្មវិធីអភិវឌ្ឍកម្លាំងសេវាសង្គម សម្រាប់ធ្វើជាទិន្នន័យបន្ទាប់បន្សំ (Secondary data)។
- ប្រមូលទិន្នន័យតាមរយៈការធ្វើសម្ភាសន៍ផ្ទាល់ បំពេញកម្រងសំណួរ និងចក្ខុវិស័យរបស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិករបស់ក្រសួង-ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលនានាសម្រាប់ធ្វើជាទិន្នន័យបឋម (Primary data)។
- វិភាគទិន្នន័យទាំងពីរដើម្បីកំណត់គោលដៅយុទ្ធសាស្ត្រ ចង្អោមសកម្មភាព និងសកម្មភាព រួមទាំងសូចនាករវាស់វែង និងធ្វើការចងក្រងសេចក្តីព្រាងសូន្យផែនការយុទ្ធសាស្ត្រ។
- រៀបចំកិច្ចប្រជុំក្រុមការងារ និងសិក្ខាសាលានៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិជាបន្តបន្ទាប់ដើម្បីប្រមូលធាតុចូលសម្រាប់កែសម្រួលសេចក្តីព្រាងសូន្យ ទី១ ២ និងទី៣ នៃផែនការយុទ្ធសាស្ត្រ។
- ពិនិត្យ និងកែសម្រួលសេចក្តីព្រាងចុងក្រោយនៃផែនការយុទ្ធសាស្ត្រ ស្តីពីកម្លាំងសេវាសង្គមឆ្នាំនៅកម្ពុជា២០២២-២០៣១ ដាក់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិនិត្យ និងសម្រេច។

១.១០. ទម្រង់ផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសង្គម

ផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជា ឆ្នាំ២០២២-២០៣១**» ចែកជា ៨ ផ្នែក៖ ផ្នែកទី១៖ សាវតា និងបរិបទ រៀបរាប់ពីគម្លាតគោលនយោបាយ ផលប៉ះពាល់វិជ្ជមាននៃការគ្រប់គ្រងកណ្តាលនិងកង្វះបុគ្គលិកសង្គម ការកំណត់ប្រភេទកម្លាំងសេវាសង្គម តួនាទីនិងមុខងារកម្លាំងសេវាសង្គម ប្រព័ន្ធអភិបាលកិច្ចកម្លាំងសេវាសង្គម ទំនាក់ទងរវាងផែនការយុទ្ធសាស្ត្រជាមួយឯកសារពាក់ព័ន្ធ ដំណើរការ

[30] ពេលវេលាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនេះត្រូវបានពន្យាពេលដោយសារការរីករាលដាលនៃជំងឺកូវីត-១៩

រៀបចំផែនការយុទ្ធសាស្ត្រ និងទម្រង់ផែនការយុទ្ធសាស្ត្រ ផ្នែកទី២៖ វឌ្ឍនភាព និងបញ្ហាប្រឈម រៀបរាប់អំពីវឌ្ឍនភាព និងបញ្ហាប្រឈម ផ្នែកទី៣៖ ទស្សនៈវិស័យ បេសកកម្ម និងគោលដៅយុទ្ធសាស្ត្រ រៀបរាប់ពីទស្សនៈវិស័យ បេសកកម្ម គោលបំណងគោលនយោបាយ និងគោលដៅយុទ្ធសាស្ត្រ ផ្នែកទី៤៖ ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ផ្នែកទី៥៖ យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន និងតម្រូវការថវិកា រៀបរាប់អំពីយុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន និងតម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ ផ្នែកទី៦៖ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ រៀបរាប់ពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃ និង ផ្នែកទី៧៖ សេចក្តីសន្និដ្ឋានរួមទាំងឧបសម្ព័ន្ធ។

២. វឌ្ឍនភាព និងបញ្ហាប្រឈម

២.១.វឌ្ឍនភាព

រាជរដ្ឋាភិបាលបានចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាចំណុចអាទិភាពមួយដែលត្រូវយកចិត្ត ទុកដាក់បំផុតក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម សំដៅសម្រេចឱ្យបាននូវគោលដៅរយៈពេលមធ្យម និងរយៈពេលវែងរបស់កម្ពុជា ពោលគឺប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅ ឆ្នាំ២០៥០។ ដើម្បីសម្រេចគោលដៅខាងលើមានគ្រឹះស្ថានអប់រំ រួមមាន សកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិសង្គមកិច្ច និងវិទ្យាស្ថានសន្តប៉ូលបានអប់រំ និងបណ្តុះបណ្តាលនិស្សិតកម្រិតឧត្តមសិក្សា និងក្រោយឧត្តមសិក្សាផ្នែកសង្គមកិច្ចវិទ្យា បានចំនួន៤០៨នាក់ រហូតមកដល់បច្ចុប្បន្ន ក្នុងនោះសកលវិទ្យាល័យភូមិន្ទភ្នំពេញមាននិស្សិតចំនួន ១៩៨នាក់ បានបញ្ចប់ថ្នាក់ បរិញ្ញាបត្រផ្នែកសង្គមកិច្ចវិទ្យា និងចំនួន៨២នាក់ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកសង្គមកិច្ច វិទ្យាស្ថានជាតិ សង្គមកិច្ចមាននិសិត្សបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកសង្គមកិច្ចវិទ្យាចំនួន ៩៣នាក់ និងវិទ្យាស្ថានសន្តប៉ូលមាន និសិត្សបញ្ចប់បរិញ្ញាបត្រសង្គមកិច្ចវិទ្យាចំនួន ៣៥នាក់ ដែលកំពុងបម្រើការនៅក្នុងវិស័យសង្គមកិច្ច។ ទន្ទឹមនឹងនេះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការយូនីសេហ្វ សហការជាមួយ អង្គការសេវាសង្គមកម្ពុជា និងអង្គការចិត្តសង្គមអន្តរវប្បធម៌បានបណ្តុះបណ្តាលមន្ត្រីក្រសួង និងមន្ត្រីមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី-ខេត្ត នៅចន្លោះឆ្នាំ២០០០ ដល់ ឆ្នាំ២០១០ មាន កម្មវិធីបីកម្រិតគឺ៖ ១.ការបណ្តុះបណ្តាលសេវាសង្គមកិច្ចមូលដ្ឋាន ២.ការបណ្តុះបណ្តាលសេវាសង្គមកិច្ច ជំនាញ និង៣.ការបណ្តុះបណ្តាលគ្រប់គ្រងសេវាសង្គមកិច្ចចំនួន ១៦០១នាក់។[31] ដើម្បីនិរន្តរភាពយូរ អង្វែងកម្មវិធីបណ្តុះបណ្តាលនេះត្រូវបានប្តូរទៅជាវិទ្យាស្ថានជាតិសង្គមកិច្ច។ បន្ថែមពីនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមិនមែនរដ្ឋាភិបាលបានធ្វើការបណ្តុះបណ្តាលមន្ត្រី ឬ បុគ្គលិកលើជំនាញការងារសង្គមកិច្ចទៅតាមតម្រូវការ។

បន្ថែមពីនេះការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានធ្វើឡើង ដោយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការពាក់ព័ន្ធដទៃទៀតដែលមាន លក្ខណៈដាច់ដាដុំៗនិង មានការលំបាកក្នុងគ្រប់គ្រង។ ក្នុងន័យនេះដើម្បីឱ្យការកសាង និងអភិវឌ្ឍធនធាន

[31] ជាលទ្ធផលមន្ត្រីចំនួន ៧១៨ នាក់បានបញ្ចប់វគ្គ (BSST) ៨៤៧នាក់បានបញ្ចប់វគ្គ(PSST)និង៣៦នាក់បានបញ្ចប់វគ្គ(MSST)។

មនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិមានលក្ខណៈជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ រាជរដ្ឋាភិបាលបានសម្រេចបង្កើតសាលាជាតិរដ្ឋបាលមូលដ្ឋាន[32]ដាក់ស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ។ សាលាជាតិរដ្ឋបាលមូលដ្ឋានមានតួនាទីអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ សិស្ស និសិត្ស និងអ្នកពាក់ព័ន្ធដទៃទៀត ព្រមទាំងសិក្សាស្រាវជ្រាវអំពីអភិបាលកិច្ច ការអភិវឌ្ឍមូលដ្ឋាន ការលើកកម្ពស់ស្វ័យភាពមូលដ្ឋាន និងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះដើម្បីផ្តល់ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៃក្រសួងមហាផ្ទៃទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយប្រសិទ្ធភាពមានលក្ខណៈប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ សាលាជាតិរដ្ឋបាលមូលដ្ឋានបានរៀបចំ និងផ្តល់នូវកម្មវិធីបណ្តុះបណ្តាលកាតព្វកិច្ចចំនួន៦ប្រភេទរួមមាន៖ ១/.វគ្គគ្រប់គ្រងជាន់ខ្ពស់ ២/.វគ្គគ្រប់គ្រងកម្រិត២ ៣/.វគ្គគ្រប់គ្រងកម្រិត១ ៤/.វគ្គវិក្រឹត្យការជំនាញ ៥/.វគ្គវិក្រឹត្យការមូលដ្ឋាន និង៦/.វគ្គលេខាធិការរដ្ឋបាល។ ក្នុងនោះគោលដៅដែលត្រូវទទួលការអភិវឌ្ឍសមត្ថភាពគឺមន្ត្រីរាជការស៊ីវិលដែលមានមុខដំណែងនៅក្នុងរចនាសម្ព័ន្ធនៃទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិដោយរួមបញ្ចូលទាំងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ព្រមទាំងមន្ត្រីរាជការស៊ីវិលដែលមិនមានមុខដំណែង និងមន្ត្រីកម្មសិក្សាទាំងនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ចាប់តាំងពីដំណើរការវិស័យសង្គមកិច្ចកន្លងមក កម្ពុជាមិនទាន់មានបទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចនៅឡើយទេ ទើបនៅឆ្នាំ២០១៧ ក្រោមកិច្ចសហការជាមួយគម្រោងថែទាំកុមារជាអាទិភាពចម្បងនៃអង្គការ Save the Children និងដោយមានការយល់ដឹងអំពីសារៈសំខាន់នៃបទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចសម្រាប់ជាសូចនាករវាស់វែងគុណតម្លៃ ចំណេះដឹង និងជំនាញកម្លាំងសេវាសង្គមទាំងនៅក្នុង និងក្រៅក្របខណ្ឌរដ្ឋាភិបាល ទើបក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានផ្តួចផ្តើមសិក្សាស្រាវជ្រាវ និងចងក្រងបទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចនេះឡើង។ បទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចមានពីរគឺ៖ ១/.បទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចសម្រាប់អ្នកអនុវត្តទូទៅ[33]និង២/.បទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចកម្រិតឯកទេសដែលនៅក្នុងនោះមានបទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចសម្រាប់អ្នកដឹកនាំនិងគ្រប់គ្រងវិស័យសង្គមកិច្ច និងបទដ្ឋានវិជ្ជាជីវៈសង្គមកិច្ចសម្រាប់អ្នកសង្គមកិច្ចបែបគ្លីនិក។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានចេញប្រកាសលេខ ៤៤៣ ស.អ.យ./ប្រ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជា ដើម្បីជាឧបករណ៍វាស់វែងកម្រិតសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គម

[32] អនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦

[33] បានកំណត់នូវវិធានសម្រាប់អនុវត្តវិជ្ជាជីវៈសង្គមកិច្ច និងប្រើជាឯកសារ៖ ១.សម្រាប់ការអភិវឌ្ឍបទដ្ឋានបណ្តុះបណ្តាលវិស័យសង្គមកិច្ចវិទ្យា ២.មគ្គុទេសក៍មួយដ៏មានប្រយោជន៍សម្រាប់ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនដែលពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលនិងកសាងសមត្ថភាព ស្របតាមតម្រូវការនៃស្ថាប័នរបស់ខ្លួន ៣.ប្រើប្រាស់ជាវិធានគោលសម្រាប់ផ្តល់អាជ្ញាប័នដល់អ្នកផ្តល់សេវាសង្គមកិច្ច។

លើផ្នែកគុណតម្លៃ[34]និងក្រមសីលធម៌ ចំណេះដឹង[35] និងជំនាញ[36] ដែលជាតម្រូវការចាំបាច់ក្នុងការអនុវត្ត ការងារសង្គមកិច្ចនៅគ្រប់កម្រិត។ អ្នកដែលមានអាជីពអនុវត្តការងារសង្គមគ្រប់រូបនៅកម្ពុជា ត្រូវប្រតិបត្តិ តាមគោលការណ៍ណែនាំនេះ ដែលជាឧបករណ៍សម្រាប់អនុវត្តល្អ។ និងជាកិច្ចគាំពារសម្រាប់អ្នកប្រើប្រាស់ និងអ្នកផ្តល់សេវា។ គោលការណ៍ណែនាំនេះមានវិសាលភាពអនុវត្តចំពោះអង្គភាព ឬស្ថាប័ន ដែលផ្តល់ សេវាសង្គម[37] និងអ្នកផ្តល់សេវាសង្គមគ្រប់រូបទាំងអ្នកមាន និងអ្នកមិនទាន់មានសញ្ញាបត្រសង្គមកិច្ចវិទ្យា ដែលធ្វើការផ្ទាល់ជាមួយអតិថិជន[38](បុគ្គល គ្រួសារ និងក្រុម) នៅកម្ពុជា។ បន្ថែមពីនេះក្រសួងបានដាក់ ចេញនូវផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គមឆ្នាំ២០២១-២០២៥[39]ដោយផ្តោតលើ ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈជំនាញសង្គមកិច្ច ក្នុងគោលបំណងពង្រឹងសមត្ថភាពកម្លាំងសេវាសង្គម ឱ្យមានកម្រិតចំណេះដឹង និងកម្រិតជំនាញពិតប្រាកដប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីផ្តល់សេវា សង្គមកិច្ចជូនអតិថិជនដែលជាជនរងគ្រោះ និងងាយរងគ្រោះធានាបាននូវប្រសិទ្ធភាពខ្ពស់។ ក្រសួងបាន សហការជាមួយគ្រឹះស្ថានអប់រំ ស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលបានរៀបចំសេចក្តីព្រាង អនុក្រឹត្យ ស្តីពី «**ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់កម្លាំងសេវាសង្គម**» មានគោលដៅកំណត់អំពីក្រមសីលធម៌ វិជ្ជាជីវៈសម្រាប់កម្លាំងសេវាសង្គមនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ក្រមសីលធម៌ សេចក្តីថ្លៃថ្នូរ ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវារបស់កម្លាំងសេវាសង្គមរួមមាន អ្នកអាជីពសង្គមកិច្ច អ្នកអាជីព សង្គមកិច្ចរង អ្នកសង្គមកិច្ចបឋម និងអ្នកសង្គមកិច្ចសម្ព័ន្ធ។

រាជរដ្ឋាភិបាលបានចេញច្បាប់ ស្តីពី «យុត្តិធម៌អនីតិជនឆ្នាំ២០១៦» គោលនយោបាយជាតិ ស្តីពី «មនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០» គោលនយោបាយជាតិ ស្តីពី «ប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ ២០១៩-២០២៩» ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ និងឯកសារពាក់ ព័ន្ធវិស័យសង្គមកិច្ចបានបង្ហាញពីតម្រូវការកម្លាំងសេវាសង្គមដែលមានចំណេះដឹង ជំនាញ និងអាកប្បកិរិយា ចាំបាច់ព្រមទាំងគុណវុធិ និងក្រមសីលធម៌វិជ្ជាជីវៈ និងមានចំនួនគ្រប់គ្រាន់ ដើម្បីផ្តល់សេវាបង្ការទប់ស្កាត់ អន្តរាគមន៍ និងស្តារនីតិសម្បទាដល់ជនរងគ្រោះ និងងាយរងគ្រោះក្នុងគោលដៅពង្រឹងកិច្ចគាំពារសង្គម កាត់ បន្ថយភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ទន្ទឹមនឹងនេះជំរុញការអភិវឌ្ឍធនធានមនុស្ស និង កំណើនសេដ្ឋកិច្ច។ នៅឆ្នាំ២០១៥ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមូលនិធិអង្គការ សហប្រជាជាតិដើម្បីកុមារ បានជ្រើសរើសបុគ្គលិកសង្គមកិច្ចចំនួន ៣០នាក់ ដាក់ពង្រាយឱ្យធ្វើការនៅតាម

---

[34] **គុណតម្លៃ**៖ សំដៅដល់គោលការណ៍ និងគោលគំនិត ដែលអ្នកអនុវត្តការងារសង្គមទាំងអស់ប្រាថ្នាចង់បាន។ រួមបញ្ចូលនឹងចំណេះដឹងនិង ជំនាញ គុណតម្លៃនៃការងារសង្គម គឺជាលក្ខណៈវិនិច្ឆ័យវិជ្ជាជីវៈសម្រាប់វាស់ស្វង់សមត្ថភាព ក្នុងការអនុវត្ត។

[35] **ចំណេះដឹង**៖ សំដៅដល់មានចំណេះដឹងស្តីពីស្ថានភាពនិងបញ្ហាសង្គមគោលនយោបាយសង្គមនិងកម្មវិធីនានា បាតុភូតសង្គម អាជីព សង្គមកិច្ចវិទ្យា និងចំណេះដឹងអំពីទ្រឹស្តីពាក់ព័ន្ធនានា សម្រាប់អនុវត្តការងារ ក្នុងគោលបំណងសម្រួលដំណើរការនៃការផ្លាស់ប្តូរ។

[36] **ជំនាញ**៖ សំដៅដល់សមត្ថភាពធ្វើអ្វីមួយបានយ៉ាងល្អ។

[37] **សេវាសង្គម**៖ គឺជាប្រព័ន្ធរៀបរយមួយនៃសេវាកម្ម និងកម្មវិធីរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើការទប់ស្កាត់ កាត់បន្ថយ ឬដោះស្រាយហានីភ័យ ផ្នែកសង្គម និងបញ្ហាសង្គម ដោយធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាពរបស់បុគ្គល គ្រួសារ និងក្រុម។ អត្ថប្រយោជន៍ដែលផ្តល់ឱ្យត្រូវផ្អែកលើ ទស្សនៈវិស័យ ឬជម្រើសមួយស្តីពីសិទ្ធិ ឧទាហរណ៍ ផ្អែកលើមូលដ្ឋាននៃលក្ខណៈវិនិច្ឆ័យ ឬលក្ខខណ្ឌតម្រូវជាក់លាក់មួយចំនួន។

[38] **អតិថិជន**៖ សំដៅដល់អ្នកដែលទទួលផល ឬប្រយោជន៍ ឬទទួលសេវាកម្មពីអ្នកផ្តល់សេវាមនុស្សធម៌ ដោយការផ្តល់សេវានេះមិនដើម្បីប្តូរជា ប្រាក់ឡើយ។

[39] ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានចុះហត្ថលេខា នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូរបស់អង្គការ 3PC សម្រាប់ប្រមូលកស្តុតាងឱ្យកាន់តែរឹងមាំថែមទៀតអំពីអត្ថប្រយោជន៍នៃការវិនិយោគនៅក្នុងការងារសង្គមលើផ្នែកហិរញ្ញវត្ថុ និងផ្នែកធនធានមនុស្សសម្រាប់ជាលទ្ធផលបានបង្ហាញឱ្យឃើញថា មានកត្តាសំខាន់ៗចំនួនបួន (មើលរូបភាពទី១)។ សមាហរណកម្មប្រកបដោយសុវត្ថិភាពមិនត្រឹមតែការបញ្ជូនកុមារលិចត្រលប់ទៅរស់នៅជាមួយក្រុមគ្រួសារវិញទេ ក៏មានការចុះឈ្មោះកុមារឱ្យចូលរៀនបន្តផងដែរ។ ការពេញចិត្តរបស់គ្រួសារត្រូវបានកត់សម្គាល់នៅពេលកុមារ ឬសមាជិកគ្រួសារប្រាប់ដល់បុគ្គលិកសង្គមកិច្ចថា ពួកគេទទួលបានក្តីស្រលាញ់ និងកិច្ចការពាររាប្រើនជាងមុន។ ការផ្លាស់ប្តូរអាកប្បកិរិយាជាវិជ្ជមានមានន័យថា នៅពេលដែលគ្រួសារចូលរួមពាក់ព័ន្ធក្នុងការកាត់បន្ថយគ្រោះថ្នាក់ កាត់បន្ថយការប្រើប្រាស់គ្រឿងញៀន ឬគ្រឿងស្រវឹង និងអាកប្បកិរិយាហិង្សា ព្រមទាំងការយល់ពីផលប៉ះពាល់ដែលកើតចេញពីការទុកដាក់កុមារនៅក្នុងមណ្ឌលថែទាំ។ ជាចុងក្រោយបុគ្គលិកសង្គមកិច្ចមានអារម្មណ៍ថា បានជួយផ្លាស់ប្តូរស្ថានភាពរស់នៅរបស់កុមារ និងគ្រួសារតាមរយៈការងាររបស់ពួកគេ។

ក្រាហ្វិកទី១៖ ការសម្រេចបានរបស់បុគ្គលិកសង្គមកិច្ច



ប្រភព៖ របាយការណ៍ករណីសិក្សាបុគ្គលិកសង្គម

ទន្ទឹមនឹងលទ្ធផលសម្រេចបាន ក៏ជួបការលំបាកក្នុងការធ្វើការងារជាមួយអតិថិជនដែលមានតម្រូវការសេវាដោយសារចំនួនបុគ្គលិកសង្គមកិច្ចមិនគ្រប់គ្រាន់ និងកង្វះសមត្ថភាពដែលមានលក្ខណៈស្តង់ដារធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃការថែទាំកុមារ និងគ្រួសារ ហើយទំហំបន្ទុកករណីរបស់បុគ្គលិកសង្គមកិច្ចគឺមានទំហំធំជាងទំហំបន្ទុកករណីដែលត្រូវបានណែនាំនៅកម្រិតអន្តរជាតិ។ ការពង្រឹងសមត្ថភាព និងបង្កើនចំនួនកម្លាំងសេវាសង្គមអាចជួយកាត់បន្ថយទំហំបន្ទុកករណី និងអាចជួយកែលម្អគុណភាពនិងប្រសិទ្ធផលនៃសេវាសង្គមកិច្ច។ នៅក្នុងចំណោមអនុសាសន៍ទាំង៧ មានអនុសាសន៍មួយស្នើឱ្យបង្កើតប្រព័ន្ធសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈអាជីព រួមមានការអប់រំបន្ត ឱ្យគ្រប់លក្ខខណ្ឌតម្រូវសម្រាប់អ្នកអាជីពសង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចរងក្នុងការរក្សាប្រសិទ្ធភាពនៃអាជ្ញាប័ណ្ណរបស់ខ្លួន និងបង្កើនចំនួនអ្នកអាជីពសង្គមកិច្ច និង/ឬអ្នកអាជីពសង្គមកិច្ចរងឱ្យបានចំនួន ២នាក់ បម្រើការងារសង្គមកិច្ចនៅក្នុងមួយឃុំ សង្កាត់ទូទាំងប្រទេសនៅចុងឆ្នាំនៃផែនការយុទ្ធសាស្ត្រជាតិនេះ។

២.២.បញ្ហាប្រឈម

នៅឆ្នាំ២០១៩ ការត្រួតពិនិត្យតំបន់នៃកម្លាំងសេវាសង្គមនៅអាស៊ីបូព៌ា និងប៉ាស៊ីហ្វិកត្រូវបានអនុវត្ត ដោយអង្គការយូនីសេហ្វ និងសម្ព័ន្ធភាពសង្គមកិច្ចពិភពលោកបានគូសបញ្ជាក់ថា ទោះបីមានការរីកចម្រើន នៅទូទាំងរដ្ឋជាសមាជិកអាស៊ានក៏ដោយក៏នៅមានបញ្ហាប្រឈមមួយចំនួនដែរដូចជា មានភាពខុសគ្នាគួរ ឱ្យកត់សម្គាល់ពីស្ថានភាពប្រភេទកម្លាំងសេវាសង្គមដែលបានអភិវឌ្ឍ របៀបកំណត់ និងទំហំការងារសង្គម កិច្ចបានអភិវឌ្ឍជាវិជ្ជាជីវៈ របៀបកំណត់ប្រភេទកម្លាំងសេវាសង្គមកិច្ចនៅក្នុងប្រទេសនីមួយ។ គម្លាតសំខាន់ៗ ដែលបានគូសបញ្ជាក់នៅក្នុងការពិនិត្យឡើងវិញរួមមាន ប្រទេសមួយចំនួនតូចមានក្របខណ្ឌគតិយុត្ត សម្រាប់វិជ្ជាជីវៈនៃការងារសង្គមកិច្ច មានសមាមាត្រទាបនៃកម្លាំងសេវាសង្គមធៀបនឹងចំនួនប្រជាជន នៅ ប្រទេសមួយចំនួនទៀតសមត្ថភាពកម្លាំងសេវាសង្គមនៅមានកម្រិតនៅឡើយ មានគ្រឹះស្ថានបណ្តុះបណ្តាល មិនគ្រប់គ្រាន់សម្រាប់ផ្នែកសង្គមកិច្ចវិទ្យា និងការរីកាដថរីកាជាតិគាំទ្រដល់សេវាសង្គមកិច្ចនៅមានកម្រិត។

បច្ចុប្បន្នកម្ពុជាមិនទាន់មានគោលនយោបាយ និងច្បាប់សម្រាប់កម្លាំងសេវាសង្គមនៅឡើយទេគឺ គ្រាន់តែមានការបញ្ជាក់នៅក្នុងមាត្រា១០ និងមាត្រា១១ នៃច្បាប់ ស្តីពី «យុត្តិធម៌អនីតិជន» បានចែងពី ការតែងតាំង ការទទួល និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ច និងបានកំណត់អំពីតួនាទី និងភារកិច្ច របស់ភ្នាក់ងារសង្គមកិច្ចផងដែរ។ ប្រកាស ស្តីពី «នីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួស ចំពោះកុមារឆ្នាំ២០១១» ជំពូកទី៣ តួនាទី និងការកិច្ចរបស់អង្គភាពពាក់ព័ន្ធនៅត្រង់ប្រការ៧ ភារកិច្ចរបស់ ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ (គ.ក.ន.ក) ប្រការ៨ ភារកិច្ចរបស់ការិយាល័យសង្គមកិច្ច អតិតយុទ្ធជន និងយុវនីតិសម្បទា ក្រុង ស្រុក ខណ្ឌ (ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម)[40] ប្រការ៩ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការ ស្ត្រីនិងកុមារនៅថ្នាក់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ប្រការ១០ ភារកិច្ចរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រការ១១ ភារកិច្ចរបស់ក្រុមប្រឹក្សារាជធានី-ខេត្ត និងគណៈកម្មាធិការពិគ្រោះ យោបល់កិច្ចការស្ត្រីនិងកុមាររាជធានី-ខេត្ត ប្រការ១២ ភារកិច្ចនាយកដ្ឋានសុខុមាលភាពកុមាររបស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ គោលនយោបាយជាតិ ស្តីពី «ប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩» គ្រាន់តែបានកំណត់គោលដៅកសាងធនធានមនុស្សទាំងសមត្ថភាពការងារក្នុងការ អនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនៅគ្រប់រចនាសម្ព័ន្ធពាក់ព័ន្ធកិច្ចការពារកុមារ ហើយជាពិសេសនៅ តាមឃុំ សង្កាត់ និងភូមិ។ គោលនយោបាយជាតិ ស្តីពី «មនុស្សវ័យចាស់ឆ្នាំ២០១៧-២០៣០» បានបង្ហាញ ពីការព្រួយបារម្ភអំពីសុខភាព និងសុខុមាលភាពរបស់មនុស្សវ័យចាស់ និងបុគ្គលិកសង្គមមើលថែទាំ។ ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ បង្ហាញពីសារៈសំខាន់លើកិច្ចគាំពារសង្គម ដើម្បីកាត់បន្ថយភាពក្រីក្រ ភាពងាយរងគ្រោះនិងវិសមភាព បានបង្ហាញពីតម្រូវការមន្ត្រីសម្រាប់ផ្តល់សេវា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

[40] អនុក្រឹត្យលេខ ១៨២ ១៨៣ និង ១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាល ក្រុង ស្រុក និងខណ្ឌ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩

យោងតាមការពិនិត្យរួមគ្នាដែលធ្វើឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការយូនីសេហ្វបានបង្ហាញថា នៅកម្ពុជាមានអត្រាកម្លាំងសេវាសង្គមធៀបទៅនឹងប្រជាជនគឺ ១/១២ ៥០០នាក់ ជាមធ្យមនាពេលបច្ចុប្បន្ន ហើយភាគច្រើនមិនបានទទួលការបណ្តុះបណ្តាលជាផ្លូវការ ក្នុងនាមជាបុគ្គលិកសង្គមកិច្ចទេ។ អត្រាបុគ្គលិកសង្គមនេះមិនទាន់ឆ្លើយតបទៅនឹងសមាមាត្ររវាងបុគ្គលិកសង្គមនឹងប្រជាជនដែលមានចំនួនប្រជាជនដ៏ប្រសើរបំផុតនៅកម្ពុជាគួរតែមានអត្រាកម្លាំងសេវាសង្គម ១នាក់ធៀបទៅនឹងប្រជាជន ៣ ៥០០នាក់ (១/៣ ៥០០) អាចប្រហាក់ប្រហែលជាមួយប្រទេសក្នុងសមាគមន៍អាស៊ាន និងប្រទេសមួយចំនួនក្នុងពិភពលោក។ ចំណែកឯការកំណត់ប្រភេទ និងមុខងារមិនទាន់មានស្តង់ដារនិយមន័យ និងគ្មានការផ្តល់ចំណាត់ថ្នាក់សម្រាប់មន្ត្រីរាជការដោយក្រសួងមុខងារសាធារណៈចំពោះកម្លាំងសេវាសង្គមនៅកម្ពុជានៅឡើយ គឺគ្រាន់តែមានការបញ្ជាក់នៅក្នុងឯកសារមួយចំនួនដូចជារបាយការណ៍នៃការពិនិត្យឡើងវិញលើការអនុវត្តការងារសង្គមកិច្ច ឆ្នាំ២០១៤ គោលការណ៍ណែនាំ ស្តីពី «សមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ២០១៩» សេចក្តីណែនាំ ស្តីពី «ការពង្រឹងកម្លាំងសេវាសង្គមដើម្បីការពារកុមារឆ្នាំ២០១៩» និងសេចក្តីថ្លែងការណ៍អាស៊ាន ស្តីពី ការលើកកម្ពស់ការងារសង្គមកិច្ច ឆ្នាំ២០១៩។

រាជរដ្ឋាភិបាលចំណាយថវិកាលើប្រាក់ខែ និងចំណាយប្រតិបត្តិសម្រាប់មន្ត្រីរាជការដែលធ្វើការនៅក្នុងវិស័យសង្គមកិច្ច និងមានការកើនឡើងជាបន្តបន្ទាប់ទៅតាមតម្រូវការនៃការអនុវត្តមុខងារ។ បន្ថែមពីនេះក៏បានផ្តល់ការគាំទ្រដល់ការអប់រំបណ្តុះបណ្តាលកម្រិតឧត្តមសិក្សា និងជំនាញវិជ្ជាជីវៈការងារសង្គមកិច្ច។ ចំណែកឯការអនុវត្តចំណាយ និងហិរញ្ញវត្ថុសម្រាប់កម្លាំងសេវាសង្គម (អ្នកអាជីពសង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចរង) មិនទាន់មានគោលការណ៍ច្បាស់លាស់នៅឡើយ ជាក់ស្តែងនៅឆ្នាំ២០១៥ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានជ្រើសរើសបុគ្គលិកសង្គមចំនួន ៣០នាក់ ដាក់ពង្រាយឱ្យធ្វើការនៅតាមមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូរបស់អង្គការ 3PC បំពេញមុខងារគ្រប់គ្រងករណី និងសមាហរណកម្មកុមារពីមណ្ឌលថែទាំទៅគ្រួសារ និងសហគមន៍វិញ ក្រោមការគាំទ្រថវិកាពីមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ។ បុគ្គលិកសង្គមដែលធ្វើការនៅតាមអង្គការមិនមែនរដ្ឋាភិបាលជាបន្ទុកចំណាយរបស់អង្គការទាំងនោះ។

ក្រសួងអប់រំ យុវជន និងកីឡាបានទទួលស្គាល់កម្មវិធីបរិញ្ញាបត្រផ្នែកសង្គមវិទ្យាចាប់តាំងពីឆ្នាំ១៩៩៤ និងកម្មវិធីថ្នាក់អនុបណ្ឌិតផ្នែកសង្គមកិច្ចវិទ្យានៅឆ្នាំ២០០៧ សម្រាប់សកលវិទ្យាល័យភូមិន្ទភ្នំពេញ។ នៅឆ្នាំ២០១១ បានទទួលស្គាល់កម្មវិធីថ្នាក់បរិញ្ញាបត្រសង្គមកិច្ច និងកម្រិតបច្ចេកទេសវិជ្ជាជីវៈដល់និសិត្ស មន្ត្រីរាជការ និងអ្នកពាក់ព័ន្ធឱ្យក្លាយជាបុគ្គលិកសង្គមនៃវិទ្យាស្ថានជាតិសង្គមកិច្ច។ នៅឆ្នាំ២០១៣ វិទ្យាស្ថានសន្តប៉ូលបានបង្កើតកម្មវិធីបរិញ្ញាបត្រសង្គមកិច្ចដែលទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ហើយនាពេលថ្មីៗនេះអាជ្ញាប័ណ្ណថ្មីសម្រាប់ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេសត្រូវបានអនុម័ត។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចេញប្រកាស លេខ៤៤៣ ស.អ.យ./ប្រ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ស្តីពី ការដាក់ឱ្យអនុវត្តគោលការណ៍ស្តីពីសមត្ថភាពមូលដ្ឋានសម្រាប់កម្លាំងសេវាសង្គមកិច្ចនៅកម្ពុជា មានគោលបំណង និងវិសាលភាពក្នុងការកំណត់នូវវិធានសម្រាប់អ្នកអនុវត្តវិជ្ជាជីវៈសង្គមកិច្ច

និងប្រើជាឧបករណ៍ដើម្បីជាមូលដ្ឋានអប្បបរមាសម្រាប់កម្លាំងសេវាសង្គម ឬអ្នកអនុវត្តការងារសង្គម អភិវឌ្ឍសមត្ថភាពនិងការបណ្តុះបណ្តាលផ្នែកសង្គមកិច្ចវិទ្យាដល់កម្លាំងសេវាសង្គម និងជាគោលការណ៍ណែនាំសម្រាប់កម្លាំងសេវាសង្គមនៃស្ថាប័នរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនដែលពាក់ព័ន្ធក្នុងការបណ្តុះបណ្តាល និងកសាងសមត្ថភាពស្របតាមតម្រូវការនៃស្ថាប័នរបស់ខ្លួន និងប្រើប្រាស់ជាវិធានមូលដ្ឋានសម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់កម្លាំងសេវាសង្គមកិច្ច។ ចំណែកឯយន្តការ និងនិតីវិធីទទួលស្គាល់ និងផ្តល់អាជ្ញាប័ណ្ណដល់កម្លាំងសេវាសង្គមរួមមាន អ្នកអាជីពសង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចរង មិនទាន់បានរៀបចំ និងដាក់ឱ្យដំណើរការនៅឡើយ។

រាជរដ្ឋាភិបាលបានចេញគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈនៅឆ្នាំ២០១៣[41] ដើម្បីសម្របសម្រួល និងជួយដល់ក្រសួង ស្ថាប័ន សម្រេចនូវគោលដៅដូចជា៖ ១/.កែលម្អរបៀបគ្រប់គ្រងការចាត់ចែងការងារដើម្បីកំណត់ឱ្យបានច្បាស់លាស់ពីតួនាទីនិងការកិច្ច និងពីតម្រូវការនៃធនធានមនុស្សទាំងបរិមាណ និងគុណភាពដោយផ្អែកលើទំហំការងារ ២/.ពង្រឹងការគ្រប់គ្រងជំនាញ និងចំនួនមន្ត្រីរាជការស៊ីវិលតាមតម្រូវការ ៣/.លើកកម្ពស់គុណផល និងការទទួលខុសត្រូវរបស់មន្ត្រីរាជការស៊ីវិល ៤/.អភិវឌ្ឍសមត្ថភាពការងាររបស់មន្ត្រីរាជការស៊ីវិល និង៥/.ពង្រឹងសីលធម៌ និងវិន័យមន្ត្រីរាជការស៊ីវិល។ គោលនយោបាយនេះមានវិសាលភាពអនុវត្តចំពោះគ្រប់មន្ត្រីរាជការស៊ីវិលដែលស្ថិតនៅក្រោមច្បាប់ ស្តីពី «សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា»។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មិនទាន់បានកំណត់គោលនយោបាយធនធានមនុស្សសម្រាប់អ្នកអាជីពសង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចរងទាំងបរិមាណ និងគុណភាពឱ្យមានអាត្រាសមាមាត្រទៅនឹងចំនួនប្រជាជនកម្ពុជា ដែលអាចធៀបទៅនឹងអត្រាបុគ្គលិកសង្គមទៅនឹងចំនួនប្រជាជននៃប្រទេសនៅក្នុងសមាគមន៍អាស៊ីននៅឡើយ។

បច្ចុប្បន្ននៅកម្ពុជាមានគ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សាចំនួនបី គឺសាកលវិទ្យាល័យភូមិន្ទភ្នំពេញ វិទ្យាស្ថានជាតិសង្គមកិច្ច និងវិទ្យាស្ថានសន្តប៉ូល ដែលមានកម្មវិធីថ្នាក់បរិញ្ញាបត្រ និងថ្នាក់អនុបណ្ឌិតផ្នែកសង្គមកិច្ចវិទ្យាដែលទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឬា។ កន្លងមកមិនទាន់បង្កើតយន្តការសម្របសម្រួលជាលក្ខណៈពហុវិស័យសម្រាប់ការអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមមានអ្នកអាជីពសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរង អ្នកសង្គមកិច្ចបឋម និងអ្នកសង្គមកិច្ចសម្ព័ន្ធនៅឡើយរវាងគ្រឹះស្ថានអប់រំទាំងបី និងរវាងក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងវិស័យសង្គមកិច្ច។ កម្មវិធីអប់រំកម្រិតឧត្តមសិក្សាផ្នែកសង្គមកិច្ចវិទ្យារបស់គ្រឹះស្ថានអប់រំត្រូវបានទទួលស្គាល់ស្របទៅតាមគុណវុធិជាតិពីក្រសួងអប់រំ យុវជន និងកីឬា ដោយឡែកការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសង្គមកិច្ចមិនទាន់បានត្រឹមត្រូវនៅឡើយទេ ដែលនាំឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតសម្បទាសហការជាមួយមូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ បានរៀបចំផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម «ផ្តោតលើកិច្ចការពារកុមារ» ឆ្នាំ២០២១-២០២៥ ក្នុងគោលបំណងពង្រឹងសមត្ថភាពកម្លាំង

[41] បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៣

សេវាសង្គមឱ្យមានកម្រិតចំណេះដឹង និងកម្រិតជំនាញពិតប្រាកដប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីផ្តល់សេវាសង្គមកិច្ចជូនអតិថិជនដែលជាជនរងគ្រោះ និងងាយរងគ្រោះធានាបាននូវប្រសិទ្ធភាពខ្ពស់។[42]

៣. ទស្សនៈវិស័យ បេសកកម្ម និងគោលដៅយុទ្ធសាស្ត្រ

៣.១. ទស្សនៈវិស័យ

លើកកម្ពស់សមត្ថភាព និងបង្កើនចំនួនកម្លាំងសេវាសង្គម ដើម្បីផ្តល់សេវាសុខុមាលភាពសង្គមជូនដល់ប្រជាជនទូទៅ ពិសេសជនរងគ្រោះនិងងាយរងគ្រោះនៅកម្ពុជាប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌។

៣.២. បេសកកម្ម

បង្កើនចំនួនកម្លាំងសេវាសង្គមឱ្យសមាមាត្រនឹងចំនួនប្រជាជន និងពង្រឹងសមត្ថភាពឱ្យមានគុណវុធិពិតប្រាកដទាំងចំណេះដឹង ជំនាញ និងអាកប្បកិរិយាប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីក្លាយទៅជា «១.អ្នកអាជីពសង្គមកិច្ច ២.អ្នកអាជីពសង្គមកិច្ចរង ៣.អ្នកសង្គមកិច្ចបឋម និង៤.អ្នកសង្គមកិច្ចសម្ព័ន្ធ» ដែលមានការចុះឈ្មោះការទទួលស្គាល់ និងអាជ្ញាប័ណ្ណពីស្ថាប័ន ឬអង្គភាពមានសមត្ថកិច្ច។

៣.៣.គោលបំណងគោលនយោបាយ

ផែនការយុទ្ធសាស្ត្រ ស្តីពី «កម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ២០២២-២០៣១»មានគោលបំណងចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ត្រង់ចតុកោណទី១ «ការអភិវឌ្ឍធនធានមនុស្ស» ដែលរាជរដ្ឋាភិបាលបានចាត់ទុកជាចំណុចអាទិភាពមួយ ដែលត្រូវយកចិត្តទុកដាក់បំផុតក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គមសំដៅសម្រេចឱ្យបាននូវគោលដៅរយៈពេលមធ្យម និងរយៈពេលវែងរបស់កម្ពុជា ពោលគឺប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅ ឆ្នាំ២០៥០។

៣.៤. គោលដៅយុទ្ធសាស្ត្រ

ដើម្បីដោះស្រាយបញ្ហាខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសហការជាមួយអង្គការយូនីសេហ្វ អង្គការក្លែនអន្តរជាតិ អង្គការ Save the Children អង្គការមិនមែនរដ្ឋាភិបាល គ្រឹះស្ថានអប់រំ និងអ្នកពាក់ព័ន្ធ បានរៀបចំផែនការយុទ្ធសាស្ត្រ ស្តីពីកម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ ២០២២-២០៣១ក្នុងគោលបំណងបង្កើនចំនួនកម្លាំងសេវាសង្គមឱ្យសមាមាត្រនឹងចំនួនប្រជាជន និងពង្រឹងសមត្ថភាពឱ្យមានគុណវុធិពិតប្រាកដទាំងចំណេះដឹង ជំនាញ និងអាកប្បកិរិយាប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈដែលកំណត់គោលដៅយុទ្ធសាស្ត្រចំនួន៣៖ ១/.ផែនការកម្លាំងសេវាសង្គម ២/.ការអភិវឌ្ឍកម្លាំងសេវាសង្គម និង៣/.ការគាំទ្រកម្លាំងសេវាសង្គម។ គោលដៅយុទ្ធសាស្ត្រនីមួយៗគាំទ្រដោយចង្កោមសកម្មភាព និងសកម្មភាពដែលរៀបរាប់លម្អិតដូចខាងក្រោម៖

[42] ផែនការយុទ្ធសាស្ត្រដើម្បីបណ្តុះបណ្តាលកម្លាំងសេវាសង្គម ដែលបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០២១

គោលដៅយុទ្ធសាស្ត្រទី១៖ផែនការកម្លាំងសេវាសង្គម

កម្លាំងសេវាសង្គមសមាមាត្រនឹងចំនួនប្រជាជននៅតាមប្រទេសនីមួយៗក្នុងពិភពលោក និងនៅតំបន់អាស៊ានមានចំនួនខុសគ្នាច្រើន[43] ដែលនាំឱ្យអនុបាតទាបមានទំនោរទាក់ទងទៅនឹងគោនយោបាយ និងច្បាប់ដែលមានកំណត់កង្វះភាពច្បាស់លាស់លើនិយមន័យការងារសង្គមកិច្ច កង្វះវិជ្ជាជីវៈ និងឱកាសអប់រំបណ្តុះបណ្តាល។ ដើម្បីតស៊ូមតិបង្កើនចំនួនកម្លាំងសេវាសង្គមឱ្យសមាមាត្រនឹងចំនួនប្រជាជនទាមទារឱ្យមានការកំណត់ចង្កោមសកម្មភាពអនុវត្តមួយចំនួនរួមមាន៖ ១.១.បង្កើតគោលនយោបាយនិងបទប្បញ្ញត្តិសម្រាប់កម្លាំងសេវាសង្គម ១.២.កំណត់ប្រភេទ មុខងារ និងបង្កើនចំនួន សមាមាត្រនៃកម្លាំងសេវាសង្គម ១.៣.ការចំណាយ និងហិរញ្ញប្បទានគាំទ្រការងារសង្គមកិច្ច ១.៤.បង្កើតប្រព័ន្ធចុះឈ្មោះ ការទទួលស្គាល់ និងអាជ្ញាប័ណ្ណ SSW និងប្រព័ន្ធព័ត៌មានធនធានមនុស្ស SSW (HRIS) និង១.៥.កំណត់គោលនយោបាយស្តីពី កម្លាំងសេវាសង្គម[44]ដែលគាំទ្រដោយសកម្មភាពមួយចំនួនផងដែរ។

គោលដៅយុទ្ធសាស្ត្រទី១៖ ផែនការកម្លាំងសេវាសង្គម	
គោលបំណង៖	កំណត់តម្រូវការកម្លាំងសេវាសង្គម និងភាពខ្វះចន្លោះប្រព័ន្ធសុខុមាលភាពសង្គម និងធានាថាច្បាប់ គោលនយោបាយ ការចុះឈ្មោះ ការទទួលស្គាល់ នឹងមានប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ឬលិខិតបញ្ជាក់ពីវិជ្ជាជីវៈសម្រាប់កម្លាំងសេវាសង្គមប្រកបដោយប្រសិទ្ធិភាព។
លទ្ធផលរំពឹងទុក៖	កម្លាំងសេវាសង្គមមានការកើនឡើងសមាមាត្រទៅនឹងប្រជាជនឆ្លើយតបទៅនឹងតម្រូវការការងារសង្គមកិច្ចនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត៖

ល.រ	ចង្កោមសកម្មភាព	សកម្មភាពអនុវត្ត		សូចនាករ
១.១	បង្កើតគោលនយោបាយ និងបទប្បញ្ញត្តិ សម្រាប់កម្លាំងសេវាសង្គម	១.១.១	បង្កើតអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់កម្លាំងសេវាសង្គម	១.គោលនយោបាយនិងបទប្បញ្ញត្តិសម្រាប់ កម្លាំងសេវាសង្គមត្រូវ បានរៀបចំបង្កើតឡើង
		១.១.២	បង្កើតដំពូកបញ្ជាក់អំពីកម្លាំងសេវាសង្គម ដែលជាផ្នែកមួយនៃច្បាប់ការពារកុមារ	
		១.១.៣	រៀបចំបទដ្ឋានស្តីពីការងារសង្គមកម្រិតឯកទេសសម្រាប់ថ្នាក់ដឹកនាំ និងអ្នកគ្រប់គ្រងសេវាសង្គម	

[43]Global Social Service Workforce Alliance: Multi-Country Review of Social Service Workforce in the East Asia and Pacific Region 2019

[44]ASEAN three pillars to strengthen the social service workforce 2019 and the Guidelines to strengthen social service for child protection 2019(Global Social Service Workforce Alliance & UNICEF)

ល.រ	ចង្កោមសកម្មភាព	សកម្មភាពអនុវត្ត		សូចនាករ
		១.១.៤	រៀបចំបទដ្ឋានការងារសង្គមកិច្ចបែបគ្លីនិកសម្រាប់អ្នកអាជីពសង្គមកិច្ច	
១.២	កំណត់ប្រភេទមុខងារ និងបង្កើនចំនួនសមាមាត្រនៃកម្លាំងសេវាសង្គម	១.២.១	ស្នើសុំឱ្យមានការទទួលស្គាល់ប្រភេទកម្លាំងសេវាសង្គមនៅចំណុច ១.៥ ពីរាជដ្ឋាភិបាល	(២)កម្លាំងសេវាសង្គមត្រូវបានកំណត់ប្រភេទមុខងារ និងបង្កើនចំនួនសមាមាត្រនឹងប្រជាជន
		១.២.២	រៀបចំមុខងារតាមប្រភេទកម្លាំងសេវាសង្គមនៅចំណុច១.៥ និងស្នើសុំឱ្យមានការទទួលស្គាល់ជាក្របខណ្ឌមុខងារសារធារណៈ	
		១.២.៣	សិក្សាពីតម្រូវការនឹងបង្កើនចំនួនកម្លាំងសេវាសង្គមដើម្បីឆ្លើយតបទៅនឹងទំហំការងារសង្គមកិច្ច និងសមាមាត្រនឹងប្រជាជនតាមតំបន់នៃរដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសនៅតាមឃុំ/សង្កាត់	
១.៣	ការចំណាយ និងហិរញ្ញប្បទានគាំទ្រការងារសង្គមកិច្ច	១.៣.១	ធ្វើការសិក្សា និងវិភាគថ្លៃចំណាយរបស់ គ.ក.ន.ក បច្ចុប្បន្ននិងស្នើសុំឱ្យមានការវិភាជ ថវិកាឱ្យគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនិងឱ្យចំផ្នែកសេវានីមួយៗនៃការងារសង្គមកិច្ចនៅក្នុងដែនសមត្ថកិច្ច	(៣) ការងារសង្គមកិច្ចដែលទទួលបានការវិភាជ ថវិកាគាំទ្រគ្រប់គ្រាន់
		១.៣.២	សិក្សា និងវិភាគថ្លៃចំណាយរបស់ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមក្រុង ស្រុក ខណ្ឌ និងស្នើសុំឱ្យមានការវិភាជ ថវិកាគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនិងឱ្យចំផ្នែកសេវានីមួយៗនៃការងារសង្គមកិច្ចនៅក្នុងដែនសមត្ថកិច្ច	
		១.៣.៣	សិក្សា និងវិភាគថ្លៃចំណាយរបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត និងស្នើសុំឱ្យមានការវិភាជ ថវិកាគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃការងារសង្គមកិច្ចនៅក្នុងដែនសមត្ថកិច្ច	

ល.រ	ចង្កោមសកម្មភាព	សកម្មភាពអនុវត្ត		សូចនាករ
		១.៣.៤	តស៊ូមតិឱ្យមានការយល់ដឹងអំពីតម្រូវការហិរញ្ញវត្ថុនិងស្នើសុំការវិភាជថវិការដ្ឋ និងថវិកាដែគូឱ្យគ្រប់គ្រាន់តាមតម្រូវការការងារសង្គមកិច្ច	
១.៤	បង្កើតប្រព័ន្ធចុះឈ្មោះ ការទទួលស្គាល់ និងអាជ្ញាប័ណ្ណ SSW និងប្រព័ន្ធព័ត៌មានធនធានមនុស្ស SSW(HRIS)	១.៤.១	សិក្សាពីប្រព័ន្ធចុះឈ្មោះ ការទទួលស្គាល់ និងការផ្តល់អាជ្ញាប័ណ្ណដល់កម្លាំងសេវាសង្គមឱ្យស្របទៅនឹងបទដ្ឋានតំបន់ និងអន្តរជាតិ	(៤) ប្រព័ន្ធចុះឈ្មោះ ការទទួលស្គាល់ និងអាជ្ញាប័ណ្ណ SSW និងប្រព័ន្ធព័ត៌មានធនធានមនុស្ស SSW (HRIS) ត្រូវបានបង្កើតឡើង
		១.៤.២	បង្កើតនីតិវិធីចុះឈ្មោះ ការទទួលស្គាល់ និងការផ្តល់អាជ្ញាប័ណ្ណកម្លាំងសេវាសង្គម	
		១.៤.៣	បង្កើតប្រព័ន្ធព័ត៌មានធនធានមនុស្សកម្លាំងសេវាសង្គម ដែលមានអាជ្ញាប័ណ្ណពីស្ថាប័នរដ្ឋទទួលបន្ទុកវិស័យសង្គមកិច្ច	
១.៥	កំណត់គោលនយោបាយស្តីពីកម្លាំងសេវាសង្គម	១.៥.១	បង្កើតគោលនយោបាយធនធានមនុស្ស សម្រាប់កម្លាំងសេវាសង្គមមាន(អ្នកអាជីពសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរង អ្នកសង្គមកិច្ចបឋម និងអ្នកសង្គមកិច្ចសម្ព័ន្ធ)	(៥)គោលនយោបាយធនធានមនុស្សសម្រាប់កម្លាំងសេវាសង្គមត្រូវបានរៀបចំបង្កើតឡើង
		១.៥.២	ផ្សព្វផ្សាយគោលនយោបាយស្តីពីធនធានមនុស្សសម្រាប់កម្លាំងសេវាសង្គមកិច្ចដល់អ្នកពាក់ព័ន្ធ	

គោលដៅយុទ្ធសាស្ត្រទី២៖ ការអភិវឌ្ឍកម្លាំងសេវាសង្គម

កម្មវិធីអប់រំបណ្តុះបណ្តាលការងារសង្គមនៅតាមបណ្តាប្រទេសអាស៊ានកំពុងកើនឡើងដែលមានបរិញ្ញាបត្រ និងអនុបណ្ឌិតផ្នែកការងារសង្គម។ ទោះជាយ៉ាងណា ការអប់រំបណ្តុះបណ្តាលការងារសង្គមដែលមានគឺមិនគ្រប់គ្រាន់ដើម្បីអភិវឌ្ឍកម្លាំងសេវាសង្គមដែលមានជំនាញវិជ្ជាជីវៈរឹងមាំនោះទេ។ គ្រឹះស្ថានអប់រំខ្លះមិនមានគ្រូបង្រៀនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានបទពិសោធន៍ច្រើនទេ ពីព្រោះវិជ្ជាជីវៈនេះមានលក្ខណៈថ្មី។ កម្មវិធីអប់រំបណ្តុះបណ្តាលសម្រាប់មន្ត្រីជំនាញមាននៅបណ្តាប្រទេសអាស៊ានទាំងអស់មានលក្ខណៈខុសគ្នាៗទៅលើចំណងជើងកម្មវិធីសិក្សា យន្តការទទួលស្គាល់ និងផ្តល់អាជ្ញាប័ណ្ណ។[45] ការអភិវឌ្ឍកម្លាំងសេវាសង្គមទាមទារឱ្យក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអ្នកពាក់

[45] Global Social Service Workforce Alliance: Multi-Country Review of Social Service Workforce in the East Asia and Pacific Region 2019

ព័ន្ធកំណត់ចង្កោមសកម្មភាពមួយយចំនួន៖ ២.១.បង្កើតកម្មវិធីឧត្តមសិក្សាសង្គមកិច្ចវិទ្យា ២.២.បង្កើតកិច្ចសហការពហុវិស័យសម្រាប់អប់រំ និងបណ្តុះបណ្តាល ២.៣.តម្រូវការអប់រំបណ្តុះបណ្តាលឱ្យស្របទៅតាមស្តង់ដារជាតិនិងអន្តរជាតិ និង២.៤.ផ្តល់នូវឱកាសបន្តការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈដែលគាំទ្រដោយសកម្មភាពមួយចំនួនផងដែរ។

គោលដៅយុទ្ធសាស្ត្រទី២៖	**ការអភិវឌ្ឍកម្លាំងសេវាសង្គម**
គោលបំណង៖	ផ្តល់ការអប់រំ និងបណ្តុះបណ្តាលកម្លាំងសេវាសង្គមប្រកបដោយប្រសិទ្ធភាពគុណភាពនៅមុន និងកំឡុងពេលបំពេញការងារ តម្រូវការអប់រំ និងបណ្តុះបណ្តាលតាមតម្រូវការរបស់កម្លាំងសេវាសង្គម បង្កើតប្រព័ន្ធទទួលស្គាល់វិជ្ជាជីវៈឱ្យស្របទៅតាមបទដ្ឋានអន្តរជាតិ និងបរិបទកម្ពុជា។
លទ្ធផលរំពឹងទុក៖	កម្លាំងសេវាសង្គមដែលទទួលបានការអភិវឌ្ឍសមត្ថភាពជំនាញ ចំណេះដឹងនិងអាកប្បកិរិយាចាំបាច់ ព្រមទាំងគុណវុធិ និងក្រមសីលធម៌វិជ្ជាជីវៈ។

ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត៖

ល.រ	ចង្កោមសកម្មភាព	សកម្មភាពអនុវត្ត		សូចនាករ
២.១	បង្កើតកម្មវិធីឧត្តមសិក្សាសង្គមកិច្ចវិទ្យា	២.១.១	បង្កើតក្រុមការងារបច្ចេកទេសដើម្បីអភិវឌ្ឍកម្មវិធីសិក្សាថ្នាក់ឧត្តមសិក្សាសង្គមកិច្ចវិទ្យា	(១)កម្មវិធីឧត្តមសិក្សាសង្គមកិច្ចវិទ្យាត្រូវបានបង្កើតឡើង
		២.១.២	ធ្វើបច្ចុប្បន្នកម្មវិធីសញ្ញាបត្រជាន់ខ្ពស់ផ្នែកសង្គមកិច្ចវិទ្យាឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារសង្គមកិច្ច	
		២.១.៣	បង្កើតកម្មវិធីកម្រិតសញ្ញាបត្រលើការងារសង្គមកិច្ចឱ្យស្របតាមការអនុវត្តអន្តរជាតិ និងបរិបទកម្ពុជា។	
២.២	បង្កើតកិច្ចសហការពហុវិស័យសម្រាប់អប់រំ និងបណ្តុះបណ្តាល	២.២.១	ពង្រឹងនិងពង្រីកការចុះអនុសារណៈកិច្ចសហប្រតិបត្តិការរវាងគ្រឹះស្ថានអប់រំការងារសង្គមកិច្ចជាតិ និងអន្តរជាតិ	(២)កិច្ចសហការពហុវិស័យសម្រាប់ការអប់រំ និងបណ្តុះបណ្តាលកម្លាំងសេវាសង្គមត្រូវបានរៀបចំបង្កើតឡើង
		២.២.២	បង្កើតកម្មវិធីពិភាក្សារវាងគ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សា និងកម្រិតជំនាញបច្ចេកទេសការងារសង្គមកិច្ច	

ល.រ	ចង្កោមសកម្មភាព	សកម្មភាពអនុវត្ត		សូចនាករ
		២.២.៣	ផ្លាស់ប្តូរគ្រូ និងសាស្ត្រាចារ្យរវាងគ្រឹះស្ថានអប់រំផ្នែកសង្គមកិច្ចវិទ្យាដើម្បីបង្កើនសមត្ថភាព និងបទពិសោធន៍បង្រៀន	
		២.២.៤	បង្កើតប្រព័ន្ធគាំទ្រនៅតាមស្ថាប័នរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិនិងអង្គការមិនមែនរដ្ឋាភិបាលដើម្បីគាំទ្រនិស្សិតសង្គមកិច្ចចុះកម្មសិក្សា	
		២.២.៥	បង្កើនកិច្ចសហការពហុវិស័យលើការងារសង្គមកិច្ចដើម្បីផ្លាស់ប្តូរបទពិសោធន៍ការងារជំនាញសង្គមកិច្ចរបស់កម្លាំងសេវាសង្គម	
២.៣	តម្រូវការអប់រំ បណ្តុះបណ្តាលឱ្យស្របទៅតាមស្តង់ដារជាតិ និងអន្តរជាតិ	២.៣.១	ពិនិត្យ និងវិភាគលើការអប់រំបណ្តុះបណ្តាលដែលបានកំណត់ដោយ IFSW IASSW និងគ្រឹះស្ថានអប់រំ ASEAN និងអន្តរជាតិ	(៣)ការអប់រំបណ្តុះបណ្តាលកម្លាំងសេវាសង្គមត្រូវបានតម្រូវឱ្យស្របតាមស្តង់ដារជាតិ និងអន្តរជាតិ
		២.៣.២	សិក្សាពីកម្មវិធីអប់រំបណ្តុះបណ្តាលដែលបានអនុវត្តដោយ NISA RUPP SPI និងអង្គការមិនមែនរដ្ឋាភិបាលកន្លងមក រួមទាំងកម្មវិធីបណ្តុះបណ្តាល BSST PSST MSST	
		២.៣.៣	អភិវឌ្ឍកម្មវិធីអប់រំបណ្តុះបណ្តាលកម្រិតឧត្តម និងសញ្ញាបត្រវិជ្ជាជីវៈសង្គមកិច្ចវិទ្យាឱ្យស្របតាមស្តង់ដារជាតិ និងអន្តរជាតិ	
២.៤	ផ្តល់នូវឱកាសបន្តការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈ	២.៤.១	បង្កើតប្រព័ន្ធអនឡាញសម្រាប់បណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល និបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងចង់បន្តការអភិវឌ្ឍវិជ្ជាជីវៈសង្គមកិច្ចគ្រប់កម្រិត	(៤)កម្លាំងសេវាសង្គមទទួលបានឱកាសបន្តការបណ្តុះបណ្តាលនិងការអភិវឌ្ឍវិជ្ជាជីវៈ

ល.រ	ចង្កោមសកម្មភាព	សកម្មភាពអនុវត្ត		សូចនាករ
		២.៤.២	រៀបចំឱ្យមានអាហារូបករណ៍សម្រាប់មន្ត្រីរាជការ បុគ្គលិកអង្គការនិងយុវជនក្រីក្រជួបការលំបាកអាចបន្តអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន	
		២.៤.៣	បញ្ជូនមន្ត្រីរាជការ អ្នកអាជីពសង្គមកិច្ច ឬអ្នកអាជីពសង្គមកិច្ចរងឱ្យទៅបន្តការសិក្សាកម្រិតជំនាញសង្គមកិច្ចជាន់ខ្ពស់នៅតាមគ្រឹះស្ថានអប់រំអន្តរជាតិនានា	
		២.៤.៤	បង្កើតឱ្យមានការធ្វើទស្សនកិច្ចសិក្សានៅតាមបណ្តាប្រទេសនានាក្នុងតំបន់និងអន្តរជាតិដែលទទួលជោគជ័យលើការងារសង្គមកិច្ច	

គោលដៅយុទ្ធសាស្ត្រទី៣៖ ការគាំទ្រកម្លាំងសេវាសង្គម

ក្រុមប្រឹក្សាវិជ្ជាជីវៈសង្គមកិច្ចមានសារៈសំខាន់ដើរតួនាទីក្នុងការត្រួតពិនិត្យដល់បុគ្គលិកសង្គម និងអ្នកជំនាញអាជីព និងការរីកចម្រើនសម្រាប់អ្នកអាជីពសង្គមកិច្ចមានភាពខុសប្លែកគ្នានៅតំបន់អាស៊ាន។ កម្លាំងសេវាសង្គមបានទទួលស្គាល់នូវតួនាទីរបស់ពួកគេជាវិជ្ជាជីវៈមួយត្រូវបានរងផលប៉ះពាល់ដោយការយល់ដឹងពីវប្បធម៌ និងប្រវត្តិសាស្ត្រនៃការងារសង្គមកិច្ចដែលទាក់ទងទៅនឹង «ការធ្វើល្អនៅក្នុងសហគមន៍» ដូច្នេះការងារសង្គមកិច្ចមិនត្រូវបានគេចាត់ទុកថាជាអាជីពទេ ហើយច្រើនតែទទួលបានប្រាក់ខែទាប និងខ្វះខាតដែលគួរតែមានការគាំទ្របន្ថែមលើកម្លាំងសេវាសង្គមនេះ។[46] ដើម្បីគាំទ្រកម្លាំងសេវាសង្គមគឺតម្រូវឱ្យក្រសួងសង្គមកិច្ច អតីតុទ្ធជន និងយុវនីតិសម្បទា និងអ្នកពាក់ព័ន្ធត្រូវធ្វើការកំណត់ចង្កោមសកម្មភាពមួយចំនួន៖ ៣.១.ធ្វើឱ្យប្រសើរឡើងនូវការជ្រើសរើសនិងការរក្សាអ្នកអាជីពសង្គមកិច្ច ៣.២.បង្កើតនិងពង្រឹងសមត្ថភាពស្ថាប័នវិជ្ជាជីវៈសង្គមកិច្ច ៣.៣.វិនិយោគលើការត្រួតពិនិត្យគុណភាពនៃកម្លាំងសេវាសង្គម ៣.៤.ជំរុញឱ្យមានការអភិវឌ្ឍអាជីពនិងវឌ្ឍនភាព និង៣.៥.ផ្សព្វផ្សាយក្រមសីលធម៌វិជ្ជាជីវៈ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធកម្លាំងសេវាសង្គម។[47]

[46] Global Social Service Workforce Alliance: Multi-Country Review of Social Service Workforce in the East Asia and Pacific Region 2019

[47] ASEAN three pillars to strengthen the social service workforce 2019 and the Guidelines to strengthen social service for child protection 2019(Global Social Service Workforce Alliance & UNICEF)

គោលដៅយុទ្ធសាស្ត្រទី៣៖ ការគាំទ្រកម្លាំងសេវាសង្គម	
គោលបំណង៖	កែលម្អនីតិវិធីជ្រើសរើសនិងរក្សាកម្លាំងសេវាសង្គមតាមរយៈការកែលម្អការពេញចិត្តការងារនិងឱកាសសម្រាប់ការអភិវឌ្ឍអាជីព ពង្រឹងការអនុវត្តការងាររបស់កម្លាំងសេវាសង្គមតាមរយៈការត្រួតពិនិត្យគុណភាព ការគាំទ្រដល់ស្ថាប័នដែលត្រូវបានផ្តល់អំណាចឱ្យកំណត់ស្តង់ដារ ក្រមសីលធម៌ និងធ្វើឱ្យអ្នកអាជីពសង្គមកិច្ចមានគណនេយ្យភាព និងដោះស្រាយការយល់ឃើញអវិជ្ជមានជាសាធារណៈចំពោះកម្លាំងសេវាសង្គម។
លទ្ធផលរំពឹងទុក៖	កម្លាំងសេវាសង្គមកិច្ចមានការពេញចិត្តចំពោះការងារសង្គម និងការអភិវឌ្ឍអាជីពដែលគាំទ្រពីស្ថាប័នរដ្ឋ គណៈវិជ្ជាជីវៈសង្គមកិច្ច និងអង្គការមិនមែនរដ្ឋាភិបាល។

ចង្កោមសកម្មភាព និងសកម្មភាពអនុវត្ត៖

ល.រ	ចង្កោមសកម្មភាព	សកម្មភាពអនុវត្ត		សូចនាករ
៣.១	ធ្វើឱ្យប្រសើរឡើងប្រព័ន្ធជ្រើសរើសនិងរក្សាអ្នកអាជីពសង្គមកិច្ច	៣.១.១	បង្កើតលក្ខខណ្ឌសម្រាប់ជ្រើសរើសមន្ត្រីឱ្យចូលបម្រើការងារសង្គមកិច្ចនៅស្ថាប័នថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិត្រូវមានសញ្ញាបត្រឧត្តមសិក្សាផ្នែកសង្គមកិច្ចវិទ្យាឬសញ្ញាបត្រវិជ្ជាជីវៈសង្គមកិច្ច	(១)ប្រព័ន្ធជ្រើសរើសនិងរក្សាអ្នកអាជីពសង្គមកិច្ចត្រូវបានរៀបចំឱ្យកាន់តែប្រសើរឡើង
		៣.១.២	ជំរុញឱ្យអង្គការមិនមែនរដ្ឋាភិបាលនិងវិស័យឯកជនបន្ថែមលក្ខខ័ណ្ឌសញ្ញាបត្រកម្រិតឧត្តមសិក្សាផ្នែកសង្គមកិច្ចវិទ្យា ឬសញ្ញាបត្រវិជ្ជាជីវៈសង្គមកិច្ចសម្រាប់ជ្រើសរើសបុគ្គលិក	
		៣.១.៣	ស្នើសុំឱ្យមានកម្រិតកាំប្រាក់ទៅតាមប្រភេទកម្លាំងសេវាសង្គមអ្នកអាជីពសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរង និងលើកទឹកចិត្តផ្តល់ប្រាក់ឧបត្ថម្ភតាមមុខងារវិជ្ជាជីវៈឯកទេសរួមទាំងផ្តល់សញ្ញាបត្រ ឬលិខិតសរសើរ	
		៣.១.៤	រៀបចំបង្កើតឱ្យមានលិខិតបទដ្ឋានគតិយុត្តក្នុងការជ្រើសរើសអ្នកអាជីព	

ល.រ	ចង្កោមសកម្មភាព		សកម្មភាពអនុវត្ត	សូចនាករ
			សង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចរង និងការលើកទឹកចិត្ត	
៣.២	បង្កើតនិងពង្រឹងសមត្ថភាពស្ថាប័នវិជ្ជាជីវៈសង្គមកិច្ច	៣.២.១	រៀបចំបង្កើតស្ថាប័នវិជ្ជាជីវៈសង្គមកិច្ចទទួលបន្ទុកកំណត់ស្តង់ដារក្រមសីលធម៌ និងទទួលស្គាល់ប្រភេទកម្លាំងសេវាសង្គម	(២)ស្ថាប័នវិជ្ជាជីវៈសង្គមកិច្ចត្រូវបានរៀបចំបង្កើតឡើងនិងពង្រឹងសមត្ថភាព
		៣.២.២	បង្កើតនីតិវិធីចុះឈ្មោះ ការទទួលស្គាល់ និងការផ្តល់អាជ្ញាប័ណ្ណដល់កម្លាំងសេវាសង្គមនិងដាក់ពិន្ទុសម្រាប់អ្នកអាជីពសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរង អ្នកសង្គមកិច្ចបឋម និងអ្នកសង្គមកិច្ចសម្ព័ន្ធ	
		៣.២.៣	ពង្រឹងសមត្ថភាពស្ថាប័នវិជ្ជាជីវៈសង្គមកិច្ចសម្រាប់គ្រប់គ្រងកម្លាំងសេវាសង្គមប្រកបដោយប្រសិទ្ធភាពនិងតម្លាភាព	
		៣.២.៤	ទស្សនកិច្ចសិក្សានៅតាមបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកស្តីពីបទពិសោធន៍លើការគ្រប់គ្រងកម្លាំងសេវាសង្គម	
		៣.២.៥	ពង្រឹងភាពជាដៃគូរវាងស្ថាប័នវិជ្ជាជីវៈសង្គមកិច្ច និងគ្រឹះស្ថានអប់រំ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ	
៣.៣	វិនិយោគលើការត្រួតពិនិត្យគុណភាពនៃកម្លាំងសេវាសង្គម	៣.៣.១	បង្កើតនីតិវិធីត្រួតពិនិត្យគុណភាពកម្លាំងសេវាសង្គមដោយផ្តោតលើចំណេះដឹង ជំនាញ អាកប្បកិរិយា និងក្រមសីលធម៌វិជ្ជាជីវៈផ្តល់សេវាសង្គមកិច្ចជូនអតិថិជន	(៣)ការត្រួតពិនិត្យកម្លាំងសេវាសង្គមត្រូវបានវិនិយោគបន្ថែម

ល.រ	ចង្កោមសកម្មភាព	សកម្មភាពអនុវត្ត		សូចនាករ
		៣.៣.២	បណ្តុះបណ្តាលអ្នកត្រួតពិនិត្យឱ្យប្រើទិន្នន័យនៅពេលជួបជាមួយអ្នកកាន់ករណី	
		៣.៣.៣	ផ្តល់ឧបករណ៍និងធនធានជូនដល់អ្នកត្រួតពិនិត្យសម្រាប់ប្រើប្រាស់នៅពេលជួបជាមួយអ្នកកាន់ករណី	
		៣.៣.៤	ផ្តល់សម្ភារ ឧបករណ៍ និងវិធីសាស្ត្រសម្រាប់អ្នកត្រួតពិនិត្យដើម្បីគាំទ្រការបណ្តុះបណ្តាលលើការងារដល់អ្នកកាន់ករណី	
		៣.៣.៥	ត្រួតពិនិត្យ និងវាយតម្លៃពីការពេញចិត្តរបស់អតិថិជនចំពោះគុណភាពសេវាដែលទទួលបានពីកម្លាំងសេវាសង្គម(អ្នកកាន់ករណី)	
៣.៤	ជំរុញឱ្យមានការអភិវឌ្ឍអាជីពនិងវឌ្ឍនភាព	៣.៤.១	បង្កើនចំនួនជ្រើសរើសកម្លាំងសេវាសង្គមដែលមានការទទួលស្គាល់វិជ្ជាជីវៈឱ្យចូលបម្រើការងារក្នុងវិស័យសង្គមកិច្ច	(៤)កម្លាំងសេវាសង្គមដែលទទួលបានការអភិវឌ្ឍអាជីព និងវឌ្ឍនភាពលើមុខងារ
		៣.៤.២	លើកទឹកចិត្តមន្ត្រីរាជការ បុគ្គលិកអង្គការ និងអ្នកស្ម័គ្រចិត្តដែលកំពុងបម្រើការងារសង្គមកិច្ចឱ្យបន្តអភិវឌ្ឍអាជីពដើម្បីផ្លាស់ប្តូរមុខតំណែង និងការទទួលស្គាល់អាជីព	
		៣.៤.៣	រៀបចំកម្មវិធីហ្វឹកហាត់ការងារ បង្រៀនផ្ទាល់នៅពេលផ្តល់សេវាសង្គមកិច្ច និងផ្តល់ឱកាសអភិវឌ្ឍជំនាញដល់កម្លាំងសេវាសង្គមជាមួយនឹងធនធានផ្សេងៗគ្នា	
		៣.៤.៤	រៀបចំវគ្គរំលឹកវិជ្ជាជីវៈដើម្បីឱ្យកម្លាំងសេវាសង្គមផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈមក្នុង	

ល.រ	ចង្កោមសកម្មភាព	សកម្មភាពអនុវត្ត		សូចនាករ
			កាងារសង្គមកិច្ច	
៣.៥	ផ្សព្វផ្សាយក្រមសីលធម៌វិជ្ជាជីវៈ និងបទដ្ឋានគតិយុត្ត៣ក់ព័ន្ធកម្លាំងសេវាសង្គម	៣.៥.១	ចងក្រងជាសៀវភៅ ឬខ្សែវីដេអូស្តីពីករណីជោគជ័យនៃការងារសង្គមកិច្ច និងវឌ្ឍនភាពកម្លាំងសេវាសង្គម	(៥)កម្លាំងសេវាសង្គមទទួលបានចំណេះដឹងពីក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់កម្លាំងសេវាសង្គម និងបទដ្ឋានគតិយុត្ត
		៣.៥.២	រៀបចំទិវាសង្គមកិច្ចអន្តរជាតិថ្ងៃទី ១៥ មីនាប្រចាំឆ្នាំដោយបង្កើតប្រធានបទក្នុងគោលបំណងលើកកម្ពស់ការងារសង្គមកិច្ច	
		៣.៥.៣	គាំទ្រដល់យុទ្ធនាការលើកកម្ពស់ការងារសង្គមកិច្ច និងកម្លាំងសេវាសង្គមដោយសហការពីសិស្សានុសិស្ស ក្រសួងស្ថាប័ន រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល	
		៣.៥.៤	បង្កើតឱ្យមានវេទិកាដើម្បីពិភាក្សាចែករំលែកបទពិសោធន៍ការងារសង្គមកិច្ចជារៀងរាល់មួយឆ្នាំម្តង	
		៣.៥.៥	លើកកម្ពស់តួនាទីកម្លាំងសេវាសង្គមដែលចូលរួមដោះស្រាយបញ្ហាសង្គមក្នុងគោលដៅបង្កើនហានៈសង្គម និងសុជីវធម៌	
		៣.៥.៦	រៀបចំបង្កើតឯកសណ្ឋាន និងប័ណ្ណសម្គាល់សម្រាប់អ្នកអាជីពសង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចរង	

៤. ការរៀបចំស្ថាប័នសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលមានវិទ្យាស្ថានជាតិសង្គមកិច្ចបង្កើតឡើងអនុក្រឹត្យលេខ២៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៩ ស្តីពីការបង្កើតវិទ្យាស្ថានជាតិសង្គមកិច្ច មានបេសកកម្មបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ លើមុខជំនាញសង្គមកិច្ច វិស្វកម្មឧបករណ៍សិប្បនិម្មិតនិងណេប និងវិជ្ជាជីវៈសង្គមកិច្ច រួមទាំងធ្វើការស្រាវជ្រាវលើផ្នែកសង្គមកិច្ច ឆ្លើយតបទៅនឹង

តម្រូវការប្រទេសជាតិ។[48] ក្រសួងនឹងសហការជាមួយគ្រឹះស្ថានអប់រំរួមមានសកលវិទ្យាល័យភូម្ទិភ្នំពេញ[49] វិទ្យាស្ថានសន្តប៉ូល[50] ដើម្បីពង្រឹងនិងពង្រីកការអប់រំបណ្តុះបណ្តាលជំនាញសង្គមកិច្ចវិទ្យាដល់និស្សិតក្នុងគោលដៅបង្កើនចំនួនអ្នកអាជីពសង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចរង។ ក្រសួងនឹងសហការជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍធ្វើការបណ្តុះបណ្តាល អ្នកសង្គមកិច្ចបឋម និងអ្នកសង្គមកិច្ចសម្ព័ន្ធទៅតាមតម្រូវការរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវក្នុងការផ្តល់សេវាសង្គមកិច្ចដល់អតិថិជនដែលជាជនរងគ្រោះ និងងាយរងគ្រោះ។

ក្រសួងនឹងធ្វើការជាមួយក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធរៀបចំឱ្យមានការទទួលសម្គាល់អាជីពសង្គមកិច្ចជាផ្លូវការពីរាជរដ្ឋាភិបាល និងបង្កើតអង្គភាពទទួលស្គាល់និងផ្តល់អាជ្ញាប័ណ្ណដល់កម្លាំងសេវាសង្គម និងពង្រឹងនិងលើកទឹកចិត្តឱ្យមានការបង្កើតសមាគមវិជ្ជាជីវៈសង្គមកិច្ច ដើម្បីកំណត់ស្តង់ដាររួមទាំងក្រមសីលធម៌ និងធានាថាសមាជិកអាជីពមានគណនេយ្យភាព និងដោះស្រាយការយល់ឃើញអវិជ្ជមានជាសាធារណៈចំពោះកម្លាំងសេវាសង្គម។ បន្ថែមពីនេះ ក្រសួងនឹងសហការជាមួយអ្នកពាក់ព័ន្ធទាំងអស់ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រស្តីពីកម្លាំងសេវាសង្គមនេះ ឱ្យទទួលបានជោគជ័យប្រកបដោយការទទួលខុសត្រូវខ្ពស់។

៥. យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន និងតម្រូវការថវិកា

៥.១. យុទ្ធសាស្ត្រកៀរគរហិរញ្ញប្បទាន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងលើកគម្រោងចំណាយ និងជំរុញឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធលើថវិកាចំណាយសម្រាប់អនុវត្តសកម្មភាពដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីប្រចាំឆ្នាំដើម្បីស្នើសុំថវិកាជាតិគាំទ្រ។ ក្រសួងនឹងយកចិត្តទុកដាក់ខ្ពស់លើភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានាដែលធ្វើសកម្មភាពរបស់ខ្លួនលើការពង្រឹងសមត្ថភាព និងបង្កើនចំនួនកម្លាំងសេវាសង្គម ដើម្បីស្នើសុំការគាំទ្រទាំងថវិកា និងបច្ចេកទេសដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រនេះទទួលបានជោគជ័យ។

៥.២.តម្រូវការថវិកាសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រ

ផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជា២០២២-២០៣២**» នេះរួមមានការប៉ាន់ប្រមាណថ្លៃចំណាយនៅ ឧបសម្ព័ន្ធទី១នឹងជួយផ្តល់ជាព័ត៌មានមូលដ្ឋានសម្រាប់នីតិវិធីគណនាថ្លៃចំណាយនៅក្នុងផែនការយុទ្ធសាស្ត្រថវិកានិងថវិកាកម្មវិធីប្រចាំឆ្នាំ និងគម្រោងចំណាយរបស់ដៃគូពាក់ព័ន្ធ។ ក្រសួងនឹងលើកសកម្មភាព និងគម្រោងចំណាយនៅក្នុងថវិកាកម្មវិធីសម្រាប់ថវិកាជាតិ និងស្នើសុំការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងវិស័យឯកជន។ ការប៉ាន់ប្រមាណថ្លៃចំណាយសម្រាប់សកម្មភាពជា

---

[48] កម្មវិធីបណ្តុះបណ្តាលជំនាញសង្គមកិច្ចចាប់ផ្តើមនៅឆ្នាំ២០០៩

[49] កម្មវិធីផ្នែកសង្គមវិទ្យាចាប់តាំងពីឆ្នាំ១៩៩៤ មានថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកសិល្បៈក្នុងការងារសង្គម។

[50] កម្មវិធីបរិញ្ញាបត្រសង្គមកិច្ចត្រូវបានចាប់ផ្តើមនៅឆ្នាំ២០១៣

យុទ្ធសាស្ត្ររយៈពេលវែងដប់ឆ្នាំ (១០ឆ្នាំ) ជួយគាំទ្រដល់ការអនុវត្ត តាមរយៈការជួយកំណត់ពីរបៀបក្នុងការវិភាជន៍ថវិកាដ៏ប្រសើរបំផុតនិងចាត់អាទិភាពទៅលើធនធានដែលមានកម្រិត និងការកំណត់រកចន្លោះខ្វះខាតធនធានដើម្បីធ្វើការចង្អុលទិសចំពោះសកម្មភាពស្វែងរកមូលនិធិ។ ផែនការយុទ្ធសាស្ត្រនេះត្រូវការថវិកាគាំទ្រចំនួនប្រមាណ **៤ ៦៣៩ ០០០.០០ USD** ទាំងថវិកាដ្ឋ និងថវិកាដៃគូ ដើម្បីចំណាយតាមគោលដៅយុទ្ធសាស្ត្រក្នុងរយៈពេល១០ឆ្នាំ (២០២២-២០៣១) ដូចមានចែងនៅក្នុងតារាងទី៣ ខាងក្រោម៖

តារាងទី៣៖ តារាងតម្រូវការថវិកាសម្រាប់អនុវត្តគោលដៅយុទ្ធសាស្ត្រឆ្នាំ ២០២២-២០៣១

ល.រ	គោលដៅយុទ្ធសាស្ត្រ	ប៉ាន់ប្រមាណតម្រូវការថវិកា(USD)		
		សរុបរួម	**ថវិកាដ្ឋ**	**ថវិកាដៃគូ**
១	ផែនការកម្លាំងសេវាសង្គម	៦១៩ 000.00	៣0%	៧0%
២	ការអភិវឌ្ឍកម្លាំងសេវាសង្គម	១ ៤១0 000.00	៣៥%	៦៥%
៣	ការគាំទ្រកម្លាំងសេវាសង្គម	២ ៦១0 000.00	៣0%	៧0%
	សរុបថវិកាចំណាយ	**៤ ៦៣៩ 000.00**	៣២%	៦៨%

៦. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីឱ្យការអនុវត្តផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ២០២២-២០៣១**» សម្រេចបានតាមគោលដៅយុទ្ធសាស្ត្រ លទ្ធផលរំពឹងទុក និងចំណុចដៅនៃសូចនាករដែលបានកំណត់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃមួយជាក់លាក់សម្រាប់រាស់រ៉ែងវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រ។ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃផែនការយុទ្ធសាស្ត្រ គឺជាការងារដ៏សំខាន់តម្រូវឱ្យក្រសួងរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ដោយមានការពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយជាមួយអ្នកពាក់ព័ន្ធនានាផ្អែកលើផែនការយុទ្ធសាស្ត្រ ស្តីពីកម្លាំងសេវាសង្គមនៅកម្ពុជានេះ។

៦.១. ការត្រួតពិនិត្យតាមដាន

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងតាមដានត្រួតពិនិត្យវឌ្ឍនភាពសម្រេចបានក្នុងការអនុវត្តយុទ្ធសាស្ត្រប្រចាំឆ្នាំនីមួយៗធៀបទៅនឹងលទ្ធផលរំពឹងទុក និងចំណុចដៅនៃសូចនាករ និងធនធានប្រចាំឆ្នាំ។ ការតាមដានត្រួតពិនិត្យត្រូវផ្អែកលើឧបករណ៍ដូចជា ផែនការសកម្មភាព និងរបាយការណ៍ប្រចាំឆ្នាំ។ អង្គភាពទទួលបន្ទុកត្រួតពិនិត្យតាមដាននឹងធ្វើរបាយការណ៍ពីលទ្ធផលតាមដានត្រួតពិនិត្យប្រចាំឆ្នាំជូនថ្នាក់ដឹកនាំក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីកែលម្អ និងផ្តល់អនុសាសន៍។

៦.២.ការវាយតម្លៃ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានឹងវាយតម្លៃលទ្ធផលសម្រេចបានដោយផ្អែកលើសូចនាករដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ។ ការវាយតម្លៃនឹងធ្វើចំនួនពីរដង គឺការវាយតម្លៃពាក់កណ្តាលអាណាត្តិនៅឆមាសទី២ ឆ្នាំ២០២៦ និងការវាយតម្លៃបញ្ចប់អាណាត្តិនៅឆមាសទី២ ឆ្នាំ២០៣១។ ការវាយតម្លៃនេះនឹងផ្អែកលើឧបករណ៍ដូចជា ផែនការសកម្មភាពប្រចាំឆ្នាំ និងរបាយការណ៍លទ្ធផលប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំនីមួយៗ របាយការណ៍វាយតម្លៃវឌ្ឍនភាពពាក់កណ្តាលអាណាត្តិ និងរបាយការណ៍វាយតម្លៃវឌ្ឍនភាពបញ្ចប់អាណាត្តិ ២០២២-២០៣១។

៧. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ ២០២២-២០៣១**» ត្រូវបានរៀបចំកសាងឡើងនៅឆ្នាំ២០២១ ក្រោមការដឹកនាំសម្របសម្រួលពីនាយកដ្ឋានសុខុមាលភាពសង្គមនៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតិតយុទ្ធជន និងយុវនីតិសម្បទា គាំទ្រដោយអង្គការយូនីសេហ្វ អង្គការផ្លែនអន្តរជាតិកម្ពុជា និងការចូលរួមពីអ្នកពាក់ព័ន្ធនានា ដោយមានការសម្របសម្រួលពិគ្រោះយោបល់ និងពិភាក្សាគ្រប់ជ្រុងជ្រោយជាមួយភាគីពាក់ព័ន្ធនានា។ ផែនការយុទ្ធសាស្ត្រនេះ គឺជាផែនទីចង្អុលផ្លូវសម្រាប់ពង្រឹងសមត្ថភាព និងបង្កើនចំនួនកម្លាំងសេវាសង្គមឱ្យសមាមាត្រនឹងប្រជាជន។ ផែនការយុទ្ធសាស្ត្រនេះនឹងចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ឆ្នាំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២០១៩-២០២៣ ក្របខណ្ឌគុណវុធ្ឍិជាតិ២០១៤ និងឯកសារពាក់ព័ន្ធជាតិ និងអន្តរជាតិ។ ទន្ទឹមនឹងការចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ត្រង់ចតុកោណទី១ «ការអភិវឌ្ឍធនធានមនុស្ស» ដែលរាជរដ្ឋាភិបាលបានចាត់ទុកជាចំណុចអាទិភាពមួយដែលត្រូវយកចិត្តទុកដាក់បំផុតក្នុងការជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម សំដៅសម្រេចឱ្យបាននូវគោលដៅរយៈពេលមធ្យម និងរយៈពេលវែងរបស់កម្ពុជាពោល គឺប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ផែនការយុទ្ធសាស្ត្រ ស្តីពី «**កម្លាំងសេវាសង្គមនៅកម្ពុជាឆ្នាំ ២០២២-២០៣១**» នេះ មានគោលដៅយុទ្ធសាស្ត្រជាអាទិភាពសំខាន់ចំនួន៣គឺ៖ ១/.ផែនការកម្លាំងសេវាសង្គម ២/.ការអភិវឌ្ឍកម្លាំងសេវាសង្គម និង៣/.ការគាំទ្រកម្លាំងសេវាសង្គមដែលតម្រូវឱ្យមានការចូលរួមអនុវត្តពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថានប័ន គ្រឹះស្ថានអប់រំ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនានាឱ្យទទួលបានជោគជ័យប្រកបដោយការទទួលខុសត្រូវ។

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ តារាងម៉ាទ្រីច ចង្កោមសកម្មភាព និងសកម្មភាព

គោលដៅយុទ្ធសាស្ត្រទី១៖ ផែនការកម្លាំងសេវាសង្គម

ល.រ	ចង្កោមសកម្មភាព	សកម្មភាព		ថវិកា (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
					1	2	3	4	5	6	7	8	9	10		
១.១	បង្កើតគោលនយោបាយនិងបទប្បញ្ញត្តិ សម្រាប់កម្លាំងសេវាសង្គម	១.១.១	បង្កើតអនុក្រឹត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់កម្លាំងសេវាសង្គម	7,000	x										MoSVY	(១)អនុក្រឹត្យស្តីពីក្រមសីលធម៌ សម្រាប់កម្លាំងសេវាសង្គមដែលទទួលបានការអនុម័ត
		១.១.២	បង្កើតជំពូកបញ្ជាក់អំពីកម្លាំងសេវាសង្គមដែលជាផ្នែកមួយនៃច្បាប់ការពារកុមារ	40,000	x	x									MoSVY MoJ NGOs	(២)ជំពូកបញ្ជាក់អំពីកម្លាំងសេវាសង្គមដែលជាផ្នែកមួយនៃច្បាប់ការពារកុមារដែលបានរៀបចំ
		១.១.៣	រៀបចំបទដ្ឋានស្តីពីការងារសង្គមកម្រិតឯកទេសសម្រាប់ថ្នាក់ដឹកនាំ និងអ្នកគ្រប់គ្រងសេវាសង្គម	50,000		x	x								MoSVY NGOs	(៣)បទដ្ឋានស្តីពីការងារសង្គមកិច្ចកម្រិតឯកទេសសម្រាប់ថ្នាក់ដឹកនាំ និងអ្នកគ្រប់គ្រងសេវាសង្គមកិច្ចដែលបានរៀបចំបង្កើតឡើង
		១.១.៤	រៀបចំបទដ្ឋានការងារសង្គមកិច្ចបែបគ្លីនិកសម្រាប់អ្នកអាជីពសង្គមកិច្ច	45,000				x	x						MoSVY NGOs	(៤)បទដ្ឋានការងារសង្គមកិច្ចបែបគ្លីនិកសម្រាប់អ្នកអាជីពសង្គមកិច្ចត្រូវបានរៀបចំបង្កើតឡើង
១.២	កំណត់ប្រភេទ មុខងារ និងបង្កើនចំនួនសមាមាត្រនៃកម្លាំងសេវាសង្គម	១.២.១	ស្នើសុំឱ្យមានការទទួលស្គាល់ប្រភេទកម្លាំងសេវាសង្គមនៅចំណុច ១.៥ ពីរាជដ្ឋាភិបាល	25,000		x	x								MoSVY MoCS	(៥)ប្រភេទកម្លាំងសេវាសង្គមត្រូវបានទទួលស្គាល់ពីរដ្ឋាភិបាល
		១.២.២	រៀបចំមុខងារតាមប្រភេទកម្លាំងសេវាសង្គមនៅចំណុច១.៥ និងស្នើសុំឱ្យមានការទទួលស្គាល់ជាក្របខណ្ឌមុខងារសារធារណៈ	25,000		x	x								MoSVY MoCS	(៦)ប្រភេទកម្លាំងសេវាសង្គមត្រូវបានកំណត់មុខងារដាក់បញ្ចូលក្នុងក្របខណ្ឌមុខងារសាធារណៈ

ល.រ	ចង្កោមសកម្មភាព		សកម្មភាព	ថវិកា (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
					1	2	3	4	5	6	7	8	9	10		
		១.២.៣	សិក្សាពីតម្រូវការនឹងបង្កើនចំនួនកម្លាំងសេវាសង្គមដើម្បីឆ្លើយតបទៅនឹងទំហំការងារសង្គមកិច្ច និងសមាមាត្រនឹងប្រជាជនតាមតំបន់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅតាមឃុំ/សង្កាត់	55,000			x	x	x						MoSVY MoCS MoI	(៧)របាយការណ៍ស្តីពីតម្រូវការកម្លាំងសេវាសង្គមឆ្លើយតបទៅនឹងទំហំការងារត្រូវបានបញ្ចប់
១.៣	ការចំណាយ និងហិរញ្ញប្បទានគាំទ្រការងារសង្គមកិច្ច	១.៣.១	ធ្វើការសិក្សា និងវិភាគថ្លៃចំណាយរបស់ គ.ក.ន.ក បច្ចុប្បន្ននិងស្នើសុំឱ្យមានការវិភាជន៍ថវិកាឱ្យគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនិងឱ្យចំផ្នែកសេវានីមួយៗនៃការងារសង្គមកិច្ចនៅក្នុងដែនសមត្ថកិច្ច	45,000		x	x	x						MoSVY MEF MoI SNA	(៨)របាយការណ៍ស្តីពីការវិភាគតម្រូវការចំណាយជាក់ស្តែងរបស់ គ.ក.ន.ក ត្រូវបានបញ្ចប់
		១.៣.២	សិក្សា និងវិភាគថ្លៃចំណាយរបស់ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ និងស្នើសុំឱ្យមានការវិភាជន៍ថវិកាគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនិងឱ្យចំផ្នែកសេវានីមួយៗនៃការងារសង្គមកិច្ចនៅក្នុងដែនសមត្ថកិច្ច	30,000			x	x						MoSVY MoEF SNA NGOs	(៩)របាយការណ៍ស្តីពីការវិភាគតម្រូវការចំណាយជាក់ស្តែងរបស់ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្រុង ស្រុក ខណ្ឌ ត្រូវបានបញ្ចប់
		១.៣.៣	សិក្សា និងវិភាគថ្លៃចំណាយរបស់មន្ទីរ ស.អ.យ រាជធានី ខេត្ត និងស្នើសុំឱ្យមានការវិភាជន៍ថវិកាគ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងនៃការងារសង្គមកិច្ចនៅក្នុងដែនសមត្ថកិច្ច	25,000		x	x							MoSVY MoEF NGOs	(១០)របាយការណ៍ស្តីពីការវិភាគតម្រូវការចំណាយជាក់ស្តែងរបស់មន្ទីរ ស.អ.យ ត្រូវបានបញ្ចប់

ល.រ	ចង្កោមសកម្មភាព	សកម្មភាព		ថវិកា (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
					1	2	3	4	5	6	7	8	9	10		
		១.៣.៤	តស៊ូមតិឱ្យមានការយល់ដឹងអំពីតម្រូវការហិរញ្ញវត្ថុនិងស្នើសុំការវិភាជន៍ថវិការដ្ឋ និងថវិកាដៃគូឱ្យគ្រប់គ្រាន់តាមតម្រូវការការងារសង្គមកិច្ច	30,000			x	x						MoSVY MoEF NGOs	(១១)ការវិភាជន៍ថវិកាដ្ឋ និងថវិកាដៃគូមានការកើនឡើងឆ្លើយតបទៅនឹងតម្រូវការការងារសង្គមកិច្ច
១.៤	បង្កើតប្រព័ន្ធចុះឈ្មោះ ការទទួលស្គាល់ និងអាជ្ញាប័ណ្ណ SSW និងប្រព័ន្ធព័ត៌មានធនធានមនុស្ស SSW(HRIS)	១.៤.១	សិក្សាពីប្រព័ន្ធចុះឈ្មោះ ការទទួលស្គាល់និងការផ្តល់អាជ្ញាប័ណ្ណដល់កម្លាំងសេវាសង្គមឱ្យស្របទៅនឹងបទដ្ឋានតំបន់ និងអន្តរជាតិ	25,000		x	x								MoSVY NGOs	(១២)របាយការណ៍ស្តីពីការបង្កើតប្រព័ន្ធ ចុះឈ្មោះ ការទទួលស្គាល់ និងការផ្តល់អាជ្ញាប័ណ្ណត្រូវបានបញ្ចប់
		១.៤.២	បង្កើតនីតិវិធីចុះឈ្មោះ ការទទួលស្គាល់និងការផ្តល់អាជ្ញាប័ណ្ណកម្លាំងសេវាសង្គម	80,000			x	x	x	x	x	x	x	x	MoSVY NGOs	(១៣)នីតិវិធីសម្រាប់ចុះឈ្មោះ ការទទួលស្គាល់និងការផ្តល់អាជ្ញាប័ណ្ណត្រូវបានបង្កើតនិងដំណើរការ
		១.៤.៣	បង្កើតប្រព័ន្ធព័ត៌មានធនធានមនុស្សកម្លាំងសេវាសង្គមដែលមានអាជ្ញាប័ណ្ណពីស្ថាប័នរដ្ឋទទួលបន្ទុកវិស័យសង្គមកិច្ច	37,000			x								MoSVY NGOs	(១៤)ប្រព័ន្ធព័ត៌មានធនធានមនុស្ស របស់កម្លាំងសេវាសង្គម ត្រូវបានបង្កើតឡើង
១.៥	កំណត់គោលនយោបាយស្តីពីកម្លាំងសេវាសង្គម	១.៥.១	បង្កើតគោលនយោបាយធនធានមនុស្ស សម្រាប់កម្លាំងសេវាសង្គមមាន(អ្នកអាជីពសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរង អ្នកសង្គមកិច្ចបឋម និងអ្នកសង្គមកិច្ចសម្ព័ន្ធ)	25,000			x	x							MoSVY MoCS NGOs	(១៥)គោលនយោបាយស្តីពីកម្លាំងសេវាសង្គមត្រូវបានអនុម័ត
		១.៥.២	ផ្សព្វផ្សាយគោលនយោបាយស្តីពីធនធានមនុស្សសម្រាប់កម្លាំងសេវាសង្គមកិច្ចដល់អ្នកពាក់ព័ន្ធ	75,000				x	x	x	x	x	x	x	MoSVY	(១៦)គោលនយោបាយធនធានមនុស្សសម្រាប់កម្លាំងសេវាសង្គម ត្រូវបានផ្សព្វផ្សាយ
			សរុបថវិកាចំណាយសម្រាប់គោលដៅយុទ្ធសាស្ត្រទី១	**619,000**												

គោលដៅយុទ្ធសាស្ត្រទី២៖ ការអភិវឌ្ឍកម្លាំងសេវាសង្គម

ល.រ	ចង្កោមសកម្មភាព	សកម្មភាព		ចំណាយ (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
					1	2	3	4	5	6	7	8	9	10		
២.១	បង្កើតកម្មវិធី ឧត្តមសិក្សា សង្គមកិច្ចវិទ្យា	២.១.១	បង្កើតក្រុមការងារបច្ចេកទេសដើម្បីអភិវឌ្ឍកម្មវិធីសិក្សាថ្នាក់ឧត្តមសិក្សាសង្គមកិច្ចវិទ្យា	60,000	x	x									NISA	(១)ក្រុមការងារបច្ចេកទេសត្រូវបានបង្កើតឡើង
		២.១.២	ធ្វើបច្ចុប្បន្នកម្មវិធីសញ្ញាបត្រជាន់ខ្ពស់ផ្នែកសង្គមកិច្ចវិទ្យាឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារសង្គមកិច្ច។	60,000		x	x								NISA NGOs	(២)កម្មវិធីបរិញ្ញាបត្រ និងសញ្ញាបត្រជាន់ខ្ពស់ផ្នែកសង្គមកិច្ចវិទ្យាត្រូវបានធ្វើបច្ចុប្បន្នភាព
		២.១.៣	បង្កើតកម្មវិធីកម្រិតសញ្ញាបត្រលើការងារសង្គមកិច្ចឱ្យស្របតាមការអនុវត្តអន្តរជាតិ និងបរិបទកម្ពុជា។	45,000		x	x			x	x				NISA RUPP SPI	(៣)កម្មវិធីកម្រិតសញ្ញាបត្រលើការងារសង្គមកិច្ចត្រូវបានបង្កើតឡើង
២.២	បង្កើតកិច្ចសហការពហុវិស័យសម្រាប់អប់រំ និងបណ្តុះបណ្តាល	២.២.១	ពង្រឹងនិងពង្រីកការចុះអនុសារណៈកិច្ចសហប្រតិបត្តិការរវាងគ្រឹះស្ថានអប់រំការងារសង្គមកិច្ចជាតិ និងអន្តរជាតិ។	85,000		x	x	x	x	x	x	x	x	x	NISA	(៤) ចំនួនអនុសារណៈរវាងគ្រឹះស្ថានអប់រំការងារសង្គមកិច្ចជាតិ និងអន្តរជាតិមានការកើនឡើង
		២.២.២	បង្កើតកម្មវិធីពិភាក្សារវាងគ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សា និងកម្រិតជំនាញបច្ចេកទេសលើការងារសង្គមកិច្ច។	50,000		x	x	x	x	x	x	x	x	x	NISA RUPP SPI	(៥)កម្មវិធីពិភាក្សារវាងគ្រឹះស្ថានអប់រំកម្រិតឧត្តមសិក្សា និងកម្រិតជំនាញបច្ចេកទេសត្រូវបានបង្កើត
		២.២.៣	ផ្លាស់ប្តូរគ្រូ និងសាស្ត្រាចារ្យរវាងគ្រឹះស្ថានអប់រំផ្នែកសង្គមកិច្ចវិទ្យាដើម្បីបង្កើនសមត្ថភាព និងបទពិសោធន៍បង្រៀន។	75,000		x		x		x		x		x	NISA RUPP SPI	(៦)គ្រូនិងសាស្ត្រាចារ្យទទួលបានចំណេះដឹងនិងបទពិសោធន៍បង្រៀនផ្នែកសង្គមកិច្ចវិទ្យាកើនឡើង
		២.២.៤	បង្កើតប្រព័ន្ធគាំទ្រនៅតាមស្ថាប័នរដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិនិងអង្គការមិនមែនរដ្ឋាភិបាលដើម្បីគាំទ្រនិស្សិតសង្គមកិច្ចចុះកម្មសិក្សា	100,000		x	x	x	x	x	x	x	x	x	MoSVY Ministries NGOs	(៧)និស្សិតសង្គមកិច្ចចុះកម្មសិក្សា ជំនាញសង្គមកិច្ចទទួលបានការគាំទ្រពីស្ថាប័នពាក់ព័ន្ធ

ល.រ	ចង្កោមសកម្មភាព		សកម្មភាព	ចំណាយ (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
					1	2	3	4	5	6	7	8	9	10		
		២.២.៥	បង្កើនកិច្ចសហការពហុវិស័យលើការងារសង្គមកិច្ចដើម្បីផ្លាស់ប្តូរបទពិសោធន៍ការងារជំនាញសង្គមកិច្ចរបស់កម្លាំងសេវាសង្គម	40,000		x		x		x		x		x	MoSVY	(៨)កម្លាំងសេវាសង្គមកិច្ចទទួលបានចំណេះដឹង និងបទពិសោធន៍ការងារសង្គមកិច្ច
២.៣	តម្រូវការអប់រំបណ្តុះបណ្តាលឱ្យស្របទៅតាមស្តង់ដារជាតិ និងអន្តរជាតិ	២.៣.១	ពិនិត្យ និងវិភាគលើការអប់រំបណ្តុះបណ្តាលដែលបានកំណត់ដោយ IFSW IASSW និងគ្រឹះស្ថានអប់រំ ASEAN និងអន្តរជាតិ	35,000			x	x							NISA	(៩)របាយការណ៍វិភាគលើការអប់រំបណ្តុះបណ្តាល IFSW IASSW និងគ្រឹះស្ថានអប់រំASEAN និងអន្តរជាតិត្រូវបានបញ្ចប់
		២.៣.២	សិក្សាពីកម្មវិធីអប់រំបណ្តុះបណ្តាលដែលបានអនុវត្តដោយ NISA RUPP SPI និងអង្គការមិនមែនរដ្ឋាភិបាលកន្លងមក រួមទាំងកម្មវិធីបណ្តុះបណ្តាល BSST PSST MSST	45,000		x	x								NISA RUPP SPI	(១០)របាយការណ៍ស្តីពីម្មវិធីអប់រំបណ្តុះបណ្តាលការងារសង្គមកិច្ចដែលអនុវត្តដោយគ្រឹះស្ថានអប់រំ អង្គការត្រូវបានបញ្ចប់
		២.៣.៣	អភិវឌ្ឍកម្មវិធីអប់រំបណ្តុះបណ្តាលកម្រិតឧត្តម និងសញ្ញាបត្រវិជ្ជាជីវៈសង្គមកិច្ចវិទ្យាឱ្យស្របតាមស្តង់ដារជាតិ និងអន្តរជាតិ	70,000			x		x		x		x		NISA RUPP SPI	(១១)កម្មវិធីអប់រំបណ្តុះបណ្តាលកម្រិតឧត្តម និងសញ្ញាបត្រវិជ្ជាជីវៈសង្គមកិច្ចវិទ្យាឱ្យស្របតាមស្តង់ដារជាតិ និងអន្តរជាតិត្រូវបានអភិវឌ្ឍ
២.៤	ផ្តល់នូវឱកាស និងបន្តការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈ	២.៤.១	បង្កើតប្រព័ន្ធអនឡាញសម្រាប់បណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិល និងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលដែលមានបំណងចង់បន្តការអភិវឌ្ឍវិជ្ជាជីវៈសង្គមកិច្ចគ្រប់កម្រិត	75,000		x	x	x	x	x	x	x	x	x	NISA RUPP SPI	(១២)ប្រព័ន្ធអនឡាញសម្រាប់បណ្តុះបណ្តាលការងារសង្គមកិច្ចត្រូវបានបង្កើតឡើងនិងដំណើរការ
		២.៤.២	រៀបចំឱ្យមានអាហារូបករណ៍សម្រាប់មន្ត្រីរាជការ បុគ្គលិកអង្គការ និងយុវជនក្រីក្រជួបការលំបាកអាចបន្តអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន	150,000		x	x	x	x	x	x	x	x	x	MoSVY NGOs	(១៣)មន្ត្រីរាជការ បុគ្គលិកអង្គការ និងយុវជនក្រីក្រជួបការលំបាកទទួលបានអាហារូបករណ៍ដើម្បីអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន

ល.រ	ចង្កោមសកម្មភាព	សកម្មភាព	ចំណាយ (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
				1	2	3	4	5	6	7	8	9	10		
		២.៤.៣ បញ្ជូនមន្ត្រីរាជការ អ្នកអាជីពសង្គមកិច្ច ឬអ្នកអាជីពសង្គមកិច្ចរងឱ្យទៅបន្តការសិក្សាកម្រិតជំនាញសង្គមកិច្ចជាន់ខ្ពស់នៅតាមគ្រឹះស្ថានអប់រំអន្តរជាតិនានា	200,000		x	x	x	x	x	x	x	x	x	MoSVY NGOs	(១៤)មន្ត្រីរាជការ អ្នកអាជីពសង្គមកិច្ច ឬអ្នកអាជីពសង្គមកិច្ចរងត្រូវបានបញ្ជូនទៅបន្តការសិក្សាកម្រិតជំនាញសង្គមកិច្ចជាន់ខ្ពស់នៅតាមគ្រឹះស្ថានអប់រំអន្តរជាតិនានា
		២.៤.៤ បង្កើតឱ្យមានការធ្វើទស្សនកិច្ចសិក្សានៅតាមបណ្តាប្រទេសនានាក្នុងតំបន់ និងអន្តរជាតិដែលទទួលជោគជ័យលើការងារសង្គមកិច្ច	320,000		x		x		x		x		x	MoSVY NGOs	(១៥)មន្ត្រីរាជការ អ្នកអាជីពសង្គមកិច្ច ឬអ្នកអាជីពសង្គមកិច្ចរងទទួលបានការធ្វើធ្វើទស្សនកិច្ចសិក្សានៅតាមបណ្តាប្រទេសនានាក្នុងតំបន់ និងអន្តរជាតិ
		សរុបថវិកាចំណាយសម្រាប់គោលដៅយុទ្ធសាស្ត្រទី២	**1,410,000**												

គោលដៅយុទ្ធសាស្ត្រទី៣៖ ការគាំទ្រកម្លាំងសេវាសង្គម

ល.រ	ចង្កោមសកម្មភាព		សកម្មភាព	ចំណាយ (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
					1	2	3	4	5	6	7	8	9	10		
៣.១	ធ្វើឱ្យប្រសើរឡើងប្រព័ន្ធជ្រើសរើស និងរក្សាអ្នកអាជីពសង្គមកិច្ច	៣.១.១	បង្កើតលក្ខខណ្ឌសម្រាប់ជ្រើសរើសមន្ត្រីឱ្យចូលបម្រើការងារសង្គមកិច្ចនៅស្ថាប័នថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិត្រូវមានសញ្ញាបត្រឧត្តមសិក្សាផ្នែកសង្គមកិច្ចវិទ្យាឬសញ្ញាបត្រវិជ្ជាជីវៈសង្គមកិច្ច	35,000		x	x	x							MoSVY MoSC	(១)ចំនួនមន្ត្រីមានសញ្ញាបត្រផ្នែកសង្គមកិច្ចវិទ្យានៅក្នុងស្ថាប័នរដ្ឋវិស័យសង្គមកិច្ចមានការកើនឡើង
		៣.១.២	ជំរុញឱ្យអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនបន្ថែមលក្ខខ័ណ្ឌសញ្ញាបត្រកម្រិតឧត្តមសិក្សាផ្នែកសង្គមកិច្ចវិទ្យា ឬសញ្ញាបត្រវិជ្ជាជីវៈសង្គមកិច្ចសម្រាប់ជ្រើសរើសបុគ្គលិក	60,000			x	x	x	x	x	x	x		MoSVY NGOs	(២)អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនធ្វើការងារផ្នែកសង្គមកិច្ចបានដាក់បញ្ចូលលក្ខខ័ណ្ឌក្នុងការជ្រើសរើសបុគ្គលិក
		៣.១.៣	ស្នើសុំឱ្យមានកម្រិតកាំប្រាក់ទៅតាមប្រភេទកម្លាំងសេវាសង្គមអ្នកអាជីពសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរង និងលើកទឹកចិត្តផ្តល់ប្រាក់ឧបត្ថម្ភតាមមុខងារវិជ្ជាជីវៈឯកទេសរួមទាំងផ្តល់សញ្ញាបត្រ ឬលិខិតសរសើរ	35,000		x	x								MoSVY MoCS MoEF	(៣)កម្រិតកាំប្រាក់ និង ប្រាប់ឧបត្ថម្ភតាមមុខងារវិជ្ជាជីវៈឯកទេសសម្រាប់ប្រភេទកម្លាំងសេវាសង្គម
		៣.១.៤	រៀបចំបង្កើតឱ្យមានលិខិតបទដ្ឋានគតិយុត្តក្នុងការជ្រើសរើសអ្នកអាជីពសង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចរង និងការលើកទឹកចិត្ត	50,000		x		x		x		x		x	MoSVY	(៤)បទដ្ឋានគតិយុត្តក្នុងការជ្រើសរើសអ្នកអាជីពសង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចរង និងការលើកទឹកចិត្តត្រូវបានបង្កើត
៣.២	បង្កើតនិងពង្រឹងសមត្ថភាពស្ថាប័នវិជ្ជាជីវៈសង្គមកិច្ច	៣.២.១	រៀបចំបង្កើតស្ថាប័នវិជ្ជាជីវៈសង្គមកិច្ចទទួលបន្ទុកកំណត់ស្តង់ដារ ក្រមសីលធម៌ និងទទួលស្គាល់ប្រភេទកម្លាំងសេវាសង្គម	45,000		x	x	x	x	x	x	x	x	x	MoSVY NGOs	(៥)គណៈវិជ្ជាជីវៈសង្គមកិច្ចត្រូវបានបង្កើត និងដំណើរការ

ល.រ	ចង្កោមសកម្មភាព	សកម្មភាព		ចំណាយ (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
					1	2	3	4	5	6	7	8	9	10		
		៣.២.២	បង្កើតនីតិវិធីចុះឈ្មោះ ការទទួលស្គាល់ និងការផ្តល់អាជ្ញាប័ណ្ណដល់កម្លាំងសេវាសង្គមនិងដាក់ពិន័យសម្រាប់អ្នកអាជីពសង្គមកិច្ច អ្នកអាជីពសង្គមកិច្ចរង អ្នកសង្គមកិច្ចបឋម និងអ្នកសង្គមកិច្ចសម្ព័ន្ធ	105,000		x	x		x	x	x	x	x	x	MoSVY NGOs	(៦)នីតិវិធីសម្រាប់ការចុះឈ្មោះ ការទទួលស្គាល់និងការផ្តល់អាជ្ញាប័ណ្ណដល់កម្លាំងសេវាសង្គមនិងដាក់ពិន័យត្រូវបានរៀបចំបង្កើតឡើង
		៣.២.៣	ពង្រឹងសមត្ថភាពស្ថាប័នវិជ្ជាជីវៈ សង្គមកិច្ចសម្រាប់គ្រប់គ្រងកម្លាំងសេវាសង្គមប្រកបដោយប្រសិទ្ធភាព និងតម្លាភាព	150,000			x	x	x	x	x	x	x	x	MoSVY NGOs	(៧)គណៈវិជ្ជាជីវៈសង្គមកិច្ចត្រូវបានពង្រឹងសមត្ថភាព
		៣.២.៤	ទស្សនកិច្ចសិក្សានៅតាមបណ្តាប្រទេសក្នុងតំបន់និងពិភពលោកស្តីពីបទពិសោធន៍លើការគ្រប់គ្រងកម្លាំងសេវាសង្គម	100,000		x		x		x		x		x	MoSVY NGOs	(៨)មន្ត្រីពាក់ព័ន្ធទទួលបានចំណេះដឹង និងបទពិសោធន៍គ្រប់គ្រងកម្លាំងសេវាសង្គមកិច្ចពីទស្សនកិច្ចសិក្សានៅតាមបណ្តាប្រទេសក្នុងតំបន់និងពិភពលោក
		៣.២.៥	ពង្រឹងភាពជាដៃគូរវាងស្ថាប័នវិជ្ជាជីវៈសង្គមកិច្ចនិងគ្រឹះស្ថានអប់រំ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ	840,000		x	x	x	x	x	x	x	x	x	MoSVY NGOs	(៩)គណៈវិជ្ជាជីវៈសង្គមកិច្ចទទួលបានការគាំទ្រពីគ្រឹះស្ថានអប់រំ និង NGOs
៣.៣	វិនិយោគលើការត្រួតពិនិត្យគុណភាពនៃកម្លាំងសេវាសង្គម	៣.៣.១	បង្កើតនីតិវិធីត្រួតពិនិត្យគុណភាពកម្លាំងសេវាសង្គមដោយផ្តោតលើចំណេះដឹង ជំនាញ អាកប្បកិរិយា និងក្រមសីលធម៌វិជ្ជាជីវៈផ្តល់សេវាសង្គមកិច្ចជូនអតិថិជន	70,000			x	x	x	x	x	x	x	x	MoSVY NGOs	(១០)នីតិវិធីត្រួតពិនិត្យគុណភាពកម្លាំងសេវាសង្គមត្រូវបានរៀបចំបង្កើតឡើង

ល.រ	ចង្កោមសកម្មភាព	សកម្មភាព		ចំណាយ (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
					1	2	3	4	5	6	7	8	9	10		
		៣.៣.២	បណ្តុះបណ្តាលអ្នកត្រួតពិនិត្យឱ្យប្រើទិន្នន័យនៅពេលជួបជាមួយអ្នកកាន់ករណី	85,000			x	x	x	x	x	x	x	x	x	MoSVY NGOs	(១១)អ្នកត្រួតពិនិត្យចេះប្រើទិន្នន័យនៅពេលជួបជាមួយអ្នកកាន់ករណី
		៣.៣.៣	ផ្តល់ឧបករណ៍និងធនធានជូនដល់អ្នកត្រួតពិនិត្យសម្រាប់ប្រើប្រាស់នៅពេលជួបជាមួយអ្នកកាន់ករណី	95,000			x	x	x	x	x	x	x	x	MoSVY NGOs	(១២)អ្នកកាន់ករណីមានឧបករណ៍និងធនធានដើម្បីអនុវត្តការងារ
		៣.៣.៤	ផ្តល់សម្ភារ ឧបករណ៍ និងវិធីសាស្ត្រសម្រាប់អ្នកត្រួតពិនិត្យដើម្បីគាំទ្រការបណ្តុះបណ្តាលលើការងារដល់អ្នកកាន់ករណី	150,000			x	x	x	x	x	x	x	x	MoSVY NGOs	(១៣)អ្នកត្រួតពិនិត្យមានសម្ភារ ឧបករណ៍ និងវិធីសាស្ត្រសម្រាប់បណ្តុះបណ្តាលអ្នកកាន់ករណី
		៣.៣.៥	ត្រួតពិនិត្យ និងវាយតម្លៃពីការពេញចិត្តរបស់អតិថិជនចំពោះគុណភាពសេវាដែលទទួលបានពីកម្លាំងសេវាសង្គម(អ្នកកាន់ករណី)	70,000			x		x		x		x		MoSVY NGOs	(១៤)អតិថិជនមានការពេញចិត្តចំពោះគុណភាពសេវា
៣.៤	ជំរុញឱ្យមានការអភិវឌ្ឍអាជីពនិងវឌ្ឍនភាព	៣.៤.១	បង្កើនចំនួនជ្រើសរើសកម្លាំងសេវាសង្គមដែលមានការទទួលស្គាល់វិជ្ជាជីវៈឱ្យចូលបម្រើការងារក្នុងវិស័យសង្គមកិច្ច	85,000			x	x	x	x	x	x	x	x	MoSVY MoCS NGOs	(១៥)ចំនួនកម្លាំងសេវាសង្គមត្រូវបានទទួលស្គាល់វិជ្ជាជីវៈឱ្យចូលបម្រើការងារ
		៣.៤.២	លើកទឹកចិត្តមន្ត្រីរាជការ បុគ្គលិកអង្គការ និងអ្នកស្ម័គ្រចិត្តដែលកំពុងបម្រើការងារសង្គមកិច្ចឱ្យបន្តអភិវឌ្ឍអាជីពដើម្បីផ្លាស់ប្តូរមុខតំណែង និងការទទួលស្គាល់អាជីព	80,000			x	x	x	x	x	x	x	x	MOSVY MoCS NGOs	(១៦)មន្ត្រីរាជការ បុគ្គលិកអង្គការ និងអ្នកស្ម័គ្រចិត្តត្រូវបានលើកទឹកចិត្តអភិវឌ្ឍអាជីពដើម្បីផ្លាស់ប្តូមុខតំណែង
		៣.៤.៣	រៀបចំកម្មវិធីហ្វឹកហាត់ការងារ បង្រៀនផ្ទាល់នៅពេលផ្តល់សេវាសង្គមកិច្ច និងផ្តល់ឱកាស	90,000			x	x	x	x	x	x	x	x	MoSVY NISA	(១៧)កម្លាំងសេវាសង្គមទទួលបានជំនាញច្បាស់លាស់តាមកម្ម

ល.រ	ចង្កោមសកម្មភាព		សកម្មភាព	ចំណាយ (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
					1	2	3	4	5	6	7	8	9	10		
			អភិវឌ្ឍជំនាញដល់កម្លាំងសេវាសង្គមជាមួយនឹងធនធានផ្សេងៗគ្នា													វិធីហាត់ការ និងបង្រៀនផ្ទាល់ពីការងារ
		៣.៤.៤	រៀបចំវគ្គរំលឹកវិជ្ជាជីវៈដើម្បីឱ្យកម្លាំងសេវាសង្គមផ្លាស់ប្តូរបទពិសោធន៍ជោគជ័យ និងបញ្ហាប្រឈមក្នុងការងារសង្គមកិច្ច	75,000			x		x		x		x		MoSVY	(១៨)វគ្គរំលឹកបច្ចេកទេសការងារសង្គមកិច្ចត្រូវបានរៀបចំបង្កើតឡើង
៣.៥	ផ្សព្វផ្សាយក្រមសីលធម៌វិជ្ជាជីវៈ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធកម្លាំងសេវាសង្គម	៣.៥.១	ចងក្រងជាសៀវភៅ ឬខ្សែវីដេអូស្តីពីករណីជោគជ័យនៃការងារសង្គមកិច្ច និងវឌ្ឍនភាពកម្លាំងសេវាសង្គម	75,000			x		x		x		x		MoSVY	(១៩)សៀវភៅឬខ្សែវីដេអូស្តីពីករណីជោគជ័យនៃការងារសង្គមនិងកម្លាំងសេវាសង្គមត្រូវបានរៀបចំបង្កើតឡើង
		៣.៥.២	រៀបចំទិវាសង្គមកិច្ចអន្តរជាតិថ្ងៃទី១៥ មីនាប្រចាំឆ្នាំដោយបង្កើតប្រធានបទក្នុងគោលបំណងលើកកម្ពស់ការងារសង្គមកិច្ច	95,000	x	x	x	x	x	x	x	x	x	x	MoSVY NGOs	(២០)ទិវាសង្គមកិច្ចអន្តរជាតិថ្ងៃទី១៥មីនាប្រចាំឆ្នាំត្រូវបានរៀបចំ
		៣.៥.៣	គាំទ្រដល់យុទ្ធនាការលើកកម្ពស់ការងារសង្គមកិច្ច និងកម្លាំងសេវាសង្គមដោយសហការពីសិស្សានុសិស្ស ក្រសួងស្ថាប័ន រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល	55,000		x		x		x		x		x	MoSVY	(២១)យុទ្ធនាការលើកកម្ពស់ការងារសង្គមកិច្ច និងកម្លាំងសេវាសង្គមទទួលបានការគាំទ្រ
		៣.៥.៤	បង្កើតឱ្យមានវេទិកាដើម្បីពិភាក្សាចែករំលែកបទពិសោធន៍ការងារសង្គមកិច្ចជារៀងរាល់មួយឆ្នាំម្តង	50,000			x	x	x	x	x	x	x	x	MoSVY MoIn NGOs	(២២)វេទិកាសម្រាប់ការងារសង្គមនិងកម្លាំងសេវាសង្គមត្រូវបានរៀបចំបង្កើតឡើង
		៣.៥.៥	លើកកម្ពស់តួនាទីកម្លាំងសេវាសង្គមដែលចូលរួមដោះស្រាយបញ្ហាសង្គមក្នុងគោលដៅបង្កើនហានៈសង្គម និងសុជីវធម៌	95,000		x	x	x	x	x	x	x	x	x	MoSVY	(២៣)តួនាទីសំខាន់នៃកម្លាំងសេវាសង្គមកិច្ចដែលចូលរួមដោះស្រាយបញ្ហាសង្គមត្រូវបានលើកកម្ពស់

ល.រ	ចង្កោមសកម្មភាព	សកម្មភាព	ចំណាយ (USD)	រយៈពេលពីឆ្នាំ២០២២-២០៣១										ស្ថាប័នអនុវត្ត និងគាំទ្រ	សូចនាករ
				1	2	3	4	5	6	7	8	9	10		
		៣.៥.៦ រៀបចំបង្កើតឯកសណ្ឋាន និងប័ណ្ណសម្គាល់សម្រាប់អ្នកអាជីពសង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចវង	20,000			x	x	x	x	x	x	x	x	MoSVY	(២៤) ឯកសណ្ឋាន និងប័ណ្ណសម្គាល់សម្រាប់អ្នកអាជីពសង្គមកិច្ចត្រូវបានរៀបចំបង្កើតឡើង
សរុបថវិកាចំណាយសម្រាប់គោលដៅយុទ្ធសាស្ត្រទី៣			**2,610,000**												

តាំទ្រដោយ៖

USAID
ជំនួយពីពលរដ្ឋអាមេរិក

unicef
for every child

PLAN
INTERNATIONAL